**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Science Economiques

Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# កិច្ចស៊ើបសួរក្នុងរឿងព្រហ្មទណ្ឌ របស់ចៅក្រមស៊ើបសួរ

ស្រាវជ្រាវចាប់ពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ លោក **សរ ស៊ីណា**

លោក **ខ៊ែត ស៊ីហ្វុង**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២២

សាស្ត្រាចារ្យណែនាំ

លោក **មីន សំអុល**

ឆ្នាំចូលសិក្សា ២០១៨

ឆ្នាំសរសេរសារណា ២០២២

# **សេចក្តីថ្លែងអំណរគុណ**

ជាបឋមយើងខ្ញុំបាទឈ្មោះ **សរ ស៊ីណា** និងឈ្មោះ **ខ៉េត ស៊ីហ្វុង** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី២២ ក្នុងឆ្នាំសិក្សា ២០១៨-២០២២ សូមថ្លែងនូវកតញ្ញូ និងការដឹងគុណដ៏ជ្រាលជ្រៅមិនអាចកាត់ថ្លៃបានដល់ **លោកអ្នកមានគុណរបស់យើងខ្ញុំទាំងពីរ** ដែលបានផ្តល់កំណើតលះបង់នូវកម្លាំងកាយចិត្តពុះពារគ្រប់ឧបសគ្គដល់យើងខ្ញុំ និងចិញ្ចឹមបីបាច់ថែរក្សាព្រមទាំងបានផ្គត់ផ្គង់ចំពោះការ ស្នាក់នៅការរៀនសូត្រតាំងពីថ្នាក់មត្តេយ្យសិក្សា រហូតដល់កម្រិតបរិញ្ញាបត្រ និងបានចូលរួមចំណែកយ៉ាងពេញទំហឹងនូវការផ្តល់កម្លាំងកាយចិត្ត ការអប់រំ ប្រៀនប្រដៅព្រមទាំងផ្តល់នូវព្រហ្មវិហារធម៌ពីសំណាក់បុព្វញាតិ និងសាខាញាតិ។ សេចក្តីដឹងគុណទាំងអស់នេះពុំអាចកាត់ថ្លៃបាននិងមិនអាចរៀបរាប់ឱ្យអស់សេចក្តី នៅក្នុងសេចក្តីអំណរគុណនេះបានឡើយ។

យើងខ្ញុំសូមថ្លែងអំណរគុណដល់ **សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ជាទីកន្លែងដែលបានបណ្តុះបណ្តាលចំណេះដឹង ក៏ដូចជាការស្រាវជ្រាវក្នុងផ្នែកនីតិសាស្ត្រនេះ តាំងពីឆ្នាំទីមួយរហូតមកដល់ការបញ្ចប់ថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រប្រកបដោយភាពជោគជ័យ និងចំណេះដឹងផ្នែកច្បាប់យ៉ាងល្អប្រសើរ។

យើងខ្ញុំសូមថ្លែងអំណរគុណចំពោះ **ឯកឧត្តមបណ្ឌិត លុយ ចណ្ណា** សាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ថ្នាក់ដឹកនាំ គណៈគ្រប់គ្រង និងលោក-លោកស្រីសាស្ត្រាចារ្យទាំងអស់ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលលោក-លោកស្រីសាស្ត្រាចារ្យ បានផ្តល់នូវពុទ្ធិ ការអប់រំ និងសីលធម៌យ៉ាងល្អថ្លៃថ្លា ដល់យើងខ្ញុំទាំងពីរក្នុងរយៈពេល ៤ឆ្នាំកន្លងមកនេះ។

បន្ថែមពីនេះទៅទៀត យើងខ្ញុំសូមថ្លែងអំណរគុណចំពោះលោកសាស្ត្រាចារ្យ **ញឹក ឧត្តី** ជាប្រធានការិយាល័យស្រាវជ្រាវ ដែលបានអនុញ្ញាតឱ្យយើងខ្ញុំទាំងពីរធ្វើការស្រាវជ្រាវប្រធានបទនេះ បើទោះបីជាមានសិស្សច្បងជំនាន់មុនក៏ដូចជាមិត្តនិស្សិតរួមជំនាន់ជ្រើសរើសប្រធានបទនេះ ឬស្រដៀងនេះក៏ដោយក៏លោកតែងតែអនុគ្រោះ ព្រោះការស្រាវជ្រាវអត្ថបទ និងការឡើងការពារសារណានេះ មានសណ្ឋាន បច្ចេកទេសបកស្រាយខុសប្លែកពីគ្នា។

ជាចុងក្រោយ យើងខ្ញុំសូមថ្លែងអំណរគុណចំពោះលោកសាស្ត្រាចារ្យ **មីន សំអុល** ជាសាស្ត្រាចារ្យដែលណែនាំនិងដឹកនាំក្នុងការសរសេរសារណារបស់យើងខ្ញុំ ដោយលោកបានខិតខំទាំងកម្លាំងកាយ កម្លាំងចិត្ត និងពេលវេលាដ៏មានតម្លៃ ក្នុងការផ្តល់នូវដំបូន្មាន គំនិត ពុទ្ធិ យោបល់ ការលើកទឹកចិត្ត និងការបង្ហាញផ្លូវដល់យើងខ្ញុំចាប់ពីថ្ងៃចាប់ផ្តើមសរសេរសារណាបញ្ចប់ការសិក្សានេះ រហូតដល់ថ្ងៃទទួលបានស្នាដៃមួយនេះជាស្ថាពរ ដែលគុណទាំងនេះគឺពិតជាមានតម្លៃវិសេសវិសាលឥតកាត់កាត់ថ្លៃបានឡើយមកលើយើងខ្ញុំ។

# អារម្ភកថា

យើងខ្ញុំឈ្មោះ **សរ ស៊ីណា** និងឈ្មោះ **ខ៉ែត ស៊ីហ្វុង** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី២២ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ តាមរយៈការសិក្សារយៈ ៤ឆ្នាំនេះ ការសិក្សាបរិញ្ញាបត្រនីតិសាស្ត្រ ផ្នែកនីតិសាស្ត្រនេះ ពិតជាផ្តល់នូវសារៈសំខាន់យ៉ាងខ្លាំងសម្រាប់យើងខ្ញុំ ក្នុងនាមយើងខ្ញុំជាយុវជនជំនាន់ក្រោយ កាលៈទេសៈខ្លះយើងខ្ញុំបានជួបប្រទះនូវឧបសគ្គ និងការលំបាកយ៉ាងណាក៏ដោយក៏យើងខ្ញុំនៅតែព្យាយាមតស៊ូក្រេបយកចំណេះវិជ្ជា ដោយមិនព្រមបោះបង់នូវការសិក្សានេះឡើយក្នុងគោលបំណងដើម្បីបញ្ចប់ថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រនេះដោយជោគជ័យជាស្ថាពរ។ ទន្ទឹមនឹងនេះការបញ្ចប់បរិញ្ញាបត្រឱ្យបានជោគជ័យ យើងខ្ញុំក៏មានគោលបំណងក្នុងការបញ្ចប់ការសិក្សាដោយការសសេរសារណាផងដែរ ដើម្បីជាស្នាដៃសម្រាប់យើងខ្ញុំផ្ទាល់ បន្ទាប់ពីបានសិក្សាអស់រយៈពេល ៤ឆ្នាំកន្លងមកនេះ។

ដោយសារតែមានការឆ្លងកាត់ការសិក្សាកន្លងមកនូវមុខវិជ្ជាសំខាន់ៗជាច្រើនក្នុងបរិញ្ញាបត្រនីតិសាស្ត្រនេះ ទើបយើងខ្ញុំមានចំណាប់អារម្មណ៍ និងចង់ស្វែងយល់លម្អិតបន្ថែមលើមុខវិជ្ជានីតិវិធីព្រហ្មទណ្ឌ ព្រោះថាមុខវិជ្ជានេះ គឺជាមុខវិជ្ជាដែលសិក្សាទាក់ទងនឹងនីតិវិធីព្រហ្មទណ្ឌ និងជាវិធានច្បាប់មួយដ៏សំខាន់ក្នុងចំណោមវិធានច្បាប់ផ្សេងៗទៀតសម្រាប់គ្រប់គ្រងសង្គមជាតិឱ្យមានសណ្តាប់ធ្នាប់ឱ្យបានល្អប្រសើរ។ ពិសេសជាងនេះទៅទៀត ដោយសារតែយើងខ្ញុំបានសិក្សាអំពីនីតិវិធី និងដំណាក់កាលនីមួយៗក្នុងរឿងព្រហ្មទណ្ឌ ដើម្បីសិក្សាឱ្យបានលម្អិតបន្ថែមអំពីចំណាត់ការ និងនីតិវិធីនីមួយៗនៅក្នុងដំណើរការរឿងព្រហ្មទណ្ឌទើបយើងខ្ញុំសម្រេចចិត្តធ្វើការស្រាវជ្រាវប្រធានបទមួយមានចំណងជើងថា "**កិច្ចស៊ើបសួរក្នុងរឿងព្រហ្មទណ្ឌរបស់ចៅក្រមស៊ើបសួរ**" ។

គោលបំណង និងមូលហេតុដែលខ្ញុំសម្រេចចិត្តជ្រើសរើសយកប្រធានបទមួយនេះមកធ្វើការស្រាវជ្រាវ និងចងក្រងឡើងគឺចង់ស្វែងយល់បន្ថែម ទទួលយកបទពិសោធន៍ និងពុទ្ធិកាន់តែស៊ីជម្រៅអំពីដំណើរការ និងនីតិវិធីក្នុងរឿងព្រហ្មទណ្ឌ បើទោះបីជាប្រធានមួយនេះមានសិស្សច្បងជំនាន់មុនៗយកមកសរសេររួចក៏ដោយ ប៉ុន្តែយើងខ្ញុំសង្ឃឹមថាការស្រាវជ្រាវថ្មីនេះនឹងមានអ្វីល្អៗប្លែកថ្មីខុសពីការស្រាវជ្រាវមុនៗ។

ជាក់ស្តែង ដោយប្រធានបទ "**កិច្ចស៊ើបសួរក្នុងរឿងព្រហ្មទណ្ឌរបស់ចៅក្រមស៊ើបសួរ**" មានភាពធំទូលាយ ដូច្នេះយើងខ្ញុំសូមអភ័យទោសជាមុនប្រសិនបើមានការបកស្រាយមិនគ្រប់ជ្រុងជ្រោយ ឬខ្វះខាតត្រង់ចំណុចណាមួយ ដោយហេតុថាយើងជានិស្សិត ដែលពុំទាន់ឆ្លងកាត់ការអនុវត្តជាក់ស្តែងនូវឡើយទេ ទើបនាំឱ្យមានការស្រាវជ្រាវរបស់យើងខ្ញុំនៅមានកម្រិត។ ប៉ុន្តែ បើទោះបីជាយ៉ាងណាក៏ដោយ ក៏យើងខ្ញុំនៅសង្ឃឹមយ៉ាងមុតមាំថា ការស្រាវជ្រាវរបស់យើងខ្ញុំមួយនេះនឹងអាចផ្តល់នូវចំណេះដឹងបន្ថែមដល់អ្នកដែលមានបំណងចង់សិក្សា និងស្វែងយល់បន្ថែមពីនិតិវិធីនីមួយៗនៅក្នុងរឿងព្រហ្មទណ្ឌ ក៏ដូចជាអ្នកសិក្សាទូទៅជាពិសេសនិស្សិតដែលកំពុងសិក្សាផ្នែកនីតិសាស្ត្រផងដែរ។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម ៖** ........ ១

## ជំពូកទី១
## ចៅក្រមស៊ើបសួរ

**ផ្នែកទី១ ៖ លក្ខណៈសម្បត្តិទូទៅរបស់ចៅក្រមស៊ើបសួរ** ........ ៣

កថាខណ្ឌទី១ ៖ សញ្ញាណទូទៅ ........ ៣

កថាខណ្ឌទី២៖ លក្ខខណ្ឌក្នុងការជ្រើសរើស ........ ៣

កថាខណ្ឌទី៣៖ លក្ខខណ្ឌក្នុងការតែងតាំង ........ ៤

កថាខណ្ឌទី៤ ៖ ក្រមសីលធម៌ក្រមស៊ើបសួរ ........ ៥

១. គោលការណ៍ឯករាជភាព ........ ៥

២. គោលការណ៍អនាគតិ(ភាពមិនលម្អៀង) ........ ៦

៣. គោលការណ៍ភាពសុចរិត ........ ៦

៤. គោលការណ៍សេចក្តីថ្លៃថ្នូរ ........ ៦

៥. គោលការណ៍វិរិយភាព(ភាពលឿនរហ័ស) ........ ៦

**ផ្នែកទី២ ៖ ការចាត់តាំងសំណុំរឿងដោយប្រធានតុលាការ** ........ ៦

កថាខណ្ឌទី១ ៖ ការចាត់តាំងសំណុំរឿងដោយប្រធានតុលាការ ........ ៦

កថាខណ្ឌទី២ ៖ ការបែងចែកសំណុំរឿង ........ ៧

កថាខណ្ឌទី៣ ៖ ការដកហូតសំណុំរឿង ........ ៧

**ផ្នែកទី៣ ៖ តួនាទីរបស់ចៅក្រមស៊ើបសួរ** ........ ៧

កថាខណ្ឌទី១ ៖ គោលបំណងនៃការស៊ើបសួរ ........ ៧

កថាខណ្ឌទី២ ៖ ចិរវេលានៃការស៊ើបសួរ ........ ៨

កថាខណ្ឌទី៣ ៖ សមត្ថកិច្ចដែនដី ........ ៨

កថាខណ្ឌទី៤ ៖ សមត្ថកិច្ចសាច់រឿង ........ ៨

## ជំពូកទី២
## ដំណើរការស៊ើបសួររបស់មន្ទីរស៊ើបសួរ សាលាដំបូងរាជធានី/ខេត្ត

**ផ្នែកទី១ ៖ ដំណើរការបញ្ជូនរឿងឱ្យស៊ើបសួរ** ........ ១០

**កថាខណ្ឌទី១ ៖ លក្ខខណ្ឌនៃការចោទប្រកាន់របស់ព្រះរាជអាជ្ញា** ........ ១០
១. ការពិនិត្យទៅលើលក្ខខណ្ឌនៃបទល្មើស ........ ១១
១.១. បទល្មើសជាបទលហុ ........ ១១
១.២. បទល្មើសជាបទមជ្ឈិម ........ ១២
១.៣. បទល្មើសជាបទឧក្រិដ្ឋ ........ ១២
២. សិទ្ធសេរីភាពក្នុងការចោទប្រកាន់របស់ព្រះរាជអាជ្ញា ........ ១៣
**កថាខណ្ឌទី២ ៖ ការសម្រេចចោទប្រកាន់របស់ព្រះរាជអាជ្ញា** ........ ១៣
១. ការបញ្ជូនទៅជំនុំជម្រះផ្ទាល់ ........ ១៣
២. ការបង្ហាញខ្លួនភ្លាម ........ ១៥
៣. ធ្វើបណ្ដឹងទៅចៅក្រមស៊ើបសួរដើម្បីបើកការស៊ើបសួរ ........ ១៦
**ផ្នែកទី២ ៖ ការបើកការស៊ើបសួរដែលធ្វើដោយចៅក្រមស៊ើបសួរ** ........ ១៦
**កថាខណ្ឌទី១ ៖ លក្ខណៈទម្រង់ និងអានុភាពនៃបណ្ដឹងដើម្បីបើកការស៊ើបសួរ** ........ ១៦
១. ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ........ ១៦
២. ការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ........ ១៧
៣. អានុភាពនៃបណ្ដឹង ........ ១៨
៣.១. ភាពមិនអាចដកបណ្ដឹងបាន ........ ១៩
៣.២. កាតព្វកិច្ចស៊ើបសួរ ........ ១៩
៣.៣. វិសាលភាពនៃបណ្ដឹង ........ ២០
៣.៣.១. ការស៊ើបសួរនៃព្រំដែនបណ្ដឹងចំពោះអង្គហេតុ ........ ២០
៣.៣.២. ការស៊ើបសួរនៃព្រំដែនបណ្ដឹងចំពោះឯកត្តបុគ្គល ........ ២១
**កថាខណ្ឌទី២ ៖ អំណាចនៃវិធីសាស្ត្រស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ** ........ ២១
១. ការជូនដំណឹងអំពីការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យ ........ ២១
២.ការសួរចម្លើយជនត្រូវចោទ ........ ២២
៣. ការស្ដាប់ចម្លើយ ........ ២៣
៣.១. ការស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី ........ ២៣
៣.២. ការស្ដាប់ចម្លើយរបស់សាក្សី ........ ២៤
៤. ការសួរតទល់ ........ ២៥

៥. ការចុះទៅដល់ទីកន្លែងកើតហេតុ ..... ២៦
៦. ការឆែកឆេរ និងចាប់យកវត្ថុតាង ..... ២៦
៧. ការធ្វើកោសលវិច្ច័យ ..... ២៧
៨. ការស្តាប់ទូរស័ព្ទ ..... ៣០
**កថាខណ្ឌទី៣ ៖ ការផ្ទេរអំណាចក្នុងការស៊ើបសួរ ..... ៣១**
១.ដីកាចាត់ឱ្យស៊ើបសួរជំនួស ..... ៣១
**កថាខណ្ឌទី៤ ៖ វិធានការនិរន្តរាយ ..... ៣៣**
១. ដីកា ..... ៣៣
១.១. ដីកាបង្គាប់ឱ្យចូលខ្លួន ..... ៣៣
១.២. ដីកាបង្គាប់ឱ្យនាំខ្លួន ..... ៣៤
១.៣. ដីកាបង្គាប់ឱ្យចាប់ខ្លួន ..... ៣៤
១.៤. ដីកាបង្គាប់ឱ្យឃុំខ្លួន ..... ៣៦
២. ការឃុំខ្លួនបណ្តោះអាសន្ន ..... ៣៦
២.១. លក្ខខណ្ឌ និងមូលហេតុឃុំខ្លួនបណ្តោះអាសន្ន ..... ៣៧
២.២. ដីកាសម្រេចមិនឃុំខ្លួនបណ្តោះអាសន្ន ..... ៣៨
២.៣. ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ..... ៣៨
២.៤. ការដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំ ..... ៤១
២.៤.១. ការដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំដោយចៅក្រមស៊ើបសួរ ..... ៤១
២.៤.២. ការដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំតាមបណ្តឹងរបស់ព្រះរាជអាជ្ញា ..... ៤១
២.៤.៣. ការដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំតាមបណ្តឹងរបស់ជនត្រូវចោទ ..... ៤១
៣. ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការ ..... ៤២
៣.១. បុគ្គលដែលអាចត្រូវដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យរបស់តុលាការ ..... ៤៣
៣.២. បែបបទនៃការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យរបស់តុលាការ ..... ៤៣
៣.៣. អនុភាពនៃការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យរបស់តុលាការ ..... ៤៤
**ផ្នែកទី៣ ៖ អំណាចការស្រាវជ្រាវតាមការស្នើសុំ ..... ៤៥**
**កថាខណ្ឌទី១ ៖ ការស្នើសុំបំពេញកិច្ចដោយព្រះរាជអាជ្ញា ..... ៤៥**
**កថាខណ្ឌទី២ ៖ ការស្នើសុំឱ្យបំពេញកិច្ចដោយជនត្រូវចោទ ..... ៤៥**

**កថាខណ្ឌទី៣ ៖ ការស្នើសុំឱ្យបំពេញកិច្ចដោយដើមបណ្តឹងរដ្ឋប្បវេណី** ........ ៤៦
**ផ្នែកទី៤ ៖ ការបិទបញ្ចប់នីតិវិធីស៊ើបសួរនៅសាលាដំបូងរាជធានី/ខេត្ត** ........ ៤៦
**កថាខណ្ឌទី១ ៖ ដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញា** ........ ៤៦
**កថាខណ្ឌទី២ ៖ ដីកាដំណោះស្រាយ** ........ ៤៧
១. ដីកាសម្រេចឱ្យរក្សាទុកជនត្រូវចោទក្នុងឃុំជាបណ្តោះអាសន្ន ........ ៤៨
២. ដីកាសម្រេចឱ្យត្រួតពិនិត្យតាមផ្លូវតុលាការ ........ ៤៨
៣. ដីកាលើកលែងការចោទប្រកាន់ ........ ៤៨
៣.១. អំពើប្រព្រឹត្តិមិនមែនជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ........ ៤៩
៣.២. អំពើដែលប្រព្រឹត្តិអំពើនោះនៅតែមិនស្គាល់អត្តសញ្ញាណ ........ ៤៩
៣.៣. គ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនត្រូវចោទ ........ ៤៩
៣.៤. ករណីដែលបណ្តឹងអាជ្ញារលត់ ........ ៤៩
៤. ដីកាបញ្ជូនទៅជំនុំជម្រះ ........ ៥០
**កថាខណ្ឌទី៣ ៖ ការប្រគល់វត្ថុចាប់យកដែលចាប់បានឱ្យទៅម្ចាស់ដើមវិញ** ........ ៥១
**សេចក្តីសន្និដ្ឋាន** ........ ៥២
**អនុសាសន៍** ........ ៥១
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្ដីផ្ដើម

ទោះបីជានៅក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ មានដំណាក់កាលជាច្រើនក៏ដោយ ដំណាក់កាលស៊ើបសួររបស់យុត្តាធិការស៊ើបសួរ ជានីតិវិធីស្វែងរកការពិតមួយដែលមានសារៈសំខាន់ដោយហេតុថា ដំណាក់កាលនេះបង្ហាញពីស្មារតីនៃគោលការណ៍បែងចែកអំណាចក្នុងស្ថាប័នតុលាការក្នុងការស្វែងរក និងធានាយុត្តិធម៌ជូនប្រជាពលរដ្ឋស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងបទបញ្ញត្តិច្បាប់នានា។ ក្រមនីតិវិធីព្រហ្មទណ្ឌបានសបញ្ជាក់ពីការកំណត់សិទ្ធិអំណាច ពិសេសរបស់យុត្តាធិការស៊ើបសួររួមមាន សិទ្ធិក្នុងការស្រាវជ្រាវបទល្មើស និងបញ្ជាក់នូវការពិត ក្នុងរឿងហេតុដែលទាក់ទងនឹងអង្គហេតុដែលតំណាងអយ្យការបានរៀបចំសំណុំរឿងដាក់ប្ដឹងមកចៅក្រមស៊ើបសួរ និងមាននូវវិធានការមួយចំនួនដែលក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់ផងដែរ។ មិនតែប៉ុណ្ណោះ ចៅក្រមស៊ើបសួរក៏ត្រូវបានកំណត់ឱ្យមាននូវសមត្ថកិច្ចពីរគឺ សមត្ថកិច្ចដែនដី និងសមត្ថកិច្ចតាមរឿងក្ដី ជាពិសេសនោះក៏មាននូវអំណាចក្នុងការស្រាវជ្រាវចាប់យកវត្ថុតាង ការសួរចម្លើយ ការស្ដាប់ចម្លើយនូវបុគ្គលដែលពាក់ព័ន្ធ ការដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យ និងអំណាចពិសេសមួយទៀតនោះ គឺការប្រើប្រាស់នូវយន្តការនៃវិធានការនិរន្តរាយ ( ដីកាបង្គាប់ឱ្យចូលខ្លួន ដីកាបង្គាប់ឱ្យនាំខ្លួន ដីកាបង្គាប់ឱ្យចាប់ខ្លួន និងដីកាបង្គាប់ឱ្យឃុំខ្លួនបណ្ដោះអាសន្ន) ព្រមទាំងការលើកលែងការចោទប្រកាន់ទៅលើជនត្រូវចោទទៀតផង។ ទោះបីជាចៅក្រមស៊ើបសួរទទួលបានសិទ្ធិអំណាចនេះក៏ដោយ ប៉ុន្តែចៅក្រមស៊ើបសួរអាចបើកការស៊ើបសួរទៅបានលុះត្រាណាតែទទួលបាននូវដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរពីព្រះរាជអាជ្ញាដែលជាដំណាក់កាលដំបូងនៃការចាប់ផ្ដើមកិច្ចស៊ើបសួរ និងជាការផ្ដល់នូវសិទ្ធិអំណាចស្របច្បាប់ទៅឱ្យចៅក្រមស៊ើបសួរប្រើប្រាស់ដើម្បីស្វែងរកការពិតស្របតាមបញ្ញត្តិច្បាប់។

ម្យ៉ាងវិញទៀតក្រមនីតិវិធីព្រហ្មទណ្ឌ មិនបានកំណត់ចំពោះចៅក្រមស៊ើបសួរអំពីថិរវេលានៅក្នុងការស្រាវជ្រាវបទល្មើសនោះទេ ឬអាចនិយាយបានថារយៈពេលនៃការបិទបញ្ចប់ការស្រាវជ្រាវនៅពេលណាឡើយ ដោយច្បាប់ទុកសិទ្ធិឱ្យចៅក្រមស៊ើបសួរធ្វើបុរេវិនិច្ឆ័យក្នុងការបញ្ចប់កិច្ចស៊ើបសួរ ឬបញ្ចប់តាមរយៈការស្នើសុំរបស់ភាគី។ ការណ៍ដែលមិនកំណត់ពេលវេលាបញ្ចប់សម្រាប់កិច្ចរបស់ចៅក្រមស៊ើបសួរក្នុងការស្រាវជ្រាវបទល្មើស មានគោលដៅដើម្បីឱ្យចៅក្រមស៊ើបសួរមានពេលវេលាគ្រប់គ្រាន់ក្នុងការស្វែងរកភស្តុតាងដាក់បន្ទុក និងភស្តុតាងដោះបន្ទុក ។ នៅក្នុងនោះផងដែរ ការស៊ើបសួរមិនមែនមានតែនៅក្នុងដំណាក់កាលសាលាដំបូងនោះទេ ចំពោះនៅដំណាក់កាលសាលាឧទ្ធរណ៍ក៏មានផងដែរ ដែលហៅថាសភាស៊ើបសួរ។ ទោះបីជានីតិវិធីទាំងអស់បានបញ្ញត្តិនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ យ៉ាងណាក៏ដោយចំពោះចំណាត់ការ ទាំងឡាយរបស់ចៅក្រមស៊ើបសួរ និងសភាស៊ើបសួរ នៅក្នុងរឿងក្ដីព្រហ្មទណ្ឌនីមួយៗសង្កេតឃើញថាសាធារណៈជនទូទៅ និងប្រជាជនខ្មែរមួយចំនួននៅមិនទាន់យល់អំពីនីតិវិធីនេះឱ្យបានច្បាស់លាស់នៅឡើយទេ។ ដូចនេះទើបមានមតិ

មួយចំនួនតែងតែលើកឡើងនូវចម្ងល់មួយចំនួនថា ហេតុអ្វីបានជាចាប់ជនសង្ស័យបានហើយបែរទៅជាមានការដោះលែងឱ្យមានសេរីភាព ឬមួយក៏មិនត្រូវបានតុលាការជម្រះក្តីភ្លាមៗទៅវិញ? ហេតុអ្វីចាំបាច់មានការឃុំខ្លួនជាបណ្តោះអាសន្ន? ហេតុអ្វីបានជាតុលាការដោះលែងជនត្រូវចោទនោះឱ្យនៅក្រៅទៅវិញ? ហេតុដូចម្តេចទើបតុលាការ ប្រកាសលើកលែងការចោទប្រកាន់?

ដូច្នេះដើម្បីជ្រាបឱ្យកាន់តែច្បាស់នូវសំនួរបញ្ហាទាំងឡាយខាងលើដែលជាការប្រឈម ប្រធានបទនេះនឹងជួយធ្វើការដោះស្រាយនូវចម្ងល់ទាំងឡាយដែលកើតមានឡើង រួមទាំងបកស្រាយបំភ្លឺឱ្យកាន់តែច្បាស់លាស់ទៀតផង។ មិនតែប៉ុណ្ណោះ ក៏មានការបកស្រាយស៊ីជម្រៅពាក់ព័ន្ធទៅនឹងនីតិវិធីនៃការស៊ើបសួរក្នុងរឿងក្តីព្រហ្មទណ្ឌរបស់ចៅក្រមស៊ើបសួររបស់មន្ទីរស៊ើបសួរ សាលាដំបូងរាជធានី/ខេត្ត ដោយយើងខ្ញុំបានបែងចែកជារចនាបទដូចខាងក្រោម៖

**ជំពូកទី១៖ ចៅក្រមស៊ើបសួរ**

**ជំពូកទី២៖ ដំណើរការស៊ើបសួររបស់មន្ទីរស៊ើបសួរ សាលាដំបូងរាជធានី/ខេត្ត**

# ជំពូកទី១
# ចៅក្រមស៊ើបសួរ

# ជំពូកទី១

# ចៅក្រមស៊ើបសួរ

## ផ្នែកទី១៖ លក្ខណៈសម្បត្តិទូទៅរបស់ចៅក្រមស៊ើបសួរ

### កថាខណ្ឌទី១៖ សញ្ញាណទូទៅ

ជាទូទៅចៅក្រមស៊ើបសួរ គឺជាមន្ត្រីសាធារណៈដែលទទួលការជ្រើសតាំងឱ្យដឹកនាំនីតិវិធីក្នុងការស៊ើបសួរ ស្វែងរកភស្តុតាង និងការពិតដើម្បីឱ្យភាគីទាំងសងខាងទទួលបានយុត្តិធម៌រវាងភាគីដើមបណ្តឹងរដ្ឋប្បវេណី និងភាគីជនត្រូវចោទ។ ជាពិសេសចៅក្រមស៊ើបសួរត្រូវបំពេញភារកិច្ចនេះដោយគោរពយ៉ាងម៉ឺងម៉ាត់ឱ្យអស់ពីដួងចិត្ត និងសម្បជញ្ញៈរបស់ខ្លួន ។

ការស៊ើបសួរ គឺជាសិទ្ធិក្នុងការបំពេញកិច្ចរបស់ចៅក្រមស៊ើបសួរ ដើម្បីធ្វើការស្រាវជ្រាវចំពោះអង្គហេតុនៃបទល្មើសព្រហ្មទណ្ឌ ក្រោយពីបានទទួលដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញាដោយអនុលោមតាមមាត្រា ៤៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ចំពោះកិច្ចស៊ើបសួរទាំងអស់នេះត្រូវបានអនុវត្ត និងដឹកនាំដោយផ្ទាល់របស់ចៅក្រមស៊ើបសួរ ដើម្បីប្រមូលភស្តុតាងទាំងអស់ដែលពាក់ព័ន្ធបញ្ជាក់ពីការពិតនៃអង្គហេតុព្រហ្មទណ្ឌ ចាប់ពីការចាប់ផ្តើមស្រាវជ្រាវរហូតដល់បញ្ចប់ការស៊ើបសួរ ។ រាល់ការស្រាវជ្រាវរឿងក្តីព្រហ្មទណ្ឌរបស់ចៅក្រមស៊ើបសួរនៅក្នុងដំណាក់កាលស៊ើបសួរត្រូវតែរក្សាការសម្ងាត់ ។ ជាគោលការណ៍ដំណាក់កាលស៊ើបសួរ ចៅក្រមស៊ើបសួរត្រូវតែស្វែងរកភស្តុតាង ទាំងភស្តុតាងដាក់បន្ទុក និងភស្តុតាងដោះបន្ទុកដើម្បីស្វែងរកភាពយុត្តិធម៌ជូនជនដែលត្រូវបានចោទប្រកាន់ និងជនរងគ្រោះ ។

ចៅក្រមស៊ើបសួរដើរតួនាទីយ៉ាងសំខាន់ រាល់ការសម្រេចឃុំខ្លួនជនត្រូវចោទជាបណ្តោះអាសន្ន ដែលជាសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរអាចមានការប៉ះពាល់យ៉ាងខ្លាំងទៅនឹងសិទ្ធិសេរីភាពរបស់ជនត្រូវចោទ។ ក៏ប៉ុន្តែដើម្បីឱ្យការស៊ើបសួរប្រព្រឹត្តទៅបានល្អ ចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឱ្យឃុំខ្លួនបណ្តោះអាសន្ន ជាលាយលក្ខណ៍អក្សរទៅលើជនត្រូវចោទណាមួយបានដោយមានសំអាងហេតុ បើចៅក្រមស៊ើបសួរយល់ឃើញថាការឃុំខ្លួនជនត្រូវចោទនេះមានប្រយោជន៍សម្រាប់រឿងក្តីទាំងមូល។

### កថាខណ្ឌទី២៖ លក្ខខណ្ឌក្នុងការជ្រើសរើស

បុគ្គលដែលត្រូវការជ្រើសរើសសម្រាប់ឱ្យបំពេញមុខងារជាចៅក្រម ត្រូវតែជាអ្នកមានសមត្ថភាព និងជាបុគ្គលសុចរិតមានសីលធម៌ខ្ពស់។ បើយោងតាមមាត្រា១៩ នៃច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា បុគ្គលដែលត្រូវបានអនុញ្ញាតឱ្យប្រឡងជ្រើសរើសជាសិស្សចៅក្រម ចាំបាច់ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- ត្រូវមានសញ្ជាតិខ្មែរពីកំណើត
- មានអាយុ ៣៥ឆ្នាំយ៉ាងច្រើន ចំពោះបេក្ខជនជានិស្សិត និងមានអាយុ ៤០ឆ្នាំយ៉ាងច្រើនចំពោះបេក្ខជនជាមន្ត្រីរាជការ គិតដល់កាលបរិច្ឆេទប្រឡង

- ត្រូវមានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រច្បាប់ឡើងទៅ
- មិនដែលមានទោសពីបទមជ្ឈិម ឬបទឧក្រិដ្ឋណាមួយឡើយ
- និងត្រូវមានកាយសម្បទាគ្រប់គ្រាន់អាចបំពេញការងារបាន។

❖ បញ្ជាក់ៈ

ការជ្រើសរើសបញ្ចូលក្នុងក្របខណ្ឌចៅក្រម អាចធ្វើឡើងតាមរយៈការប្រឡងប្រជែងផ្ទៃក្នុងពីក្នុងចំណោមមន្ត្រីរាជការ និងក្រឡាបញ្ជី ដែលត្រូវគោរពតាមលក្ខខណ្ឌដូចខាងក្រោមៈ

- ត្រូវមានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រច្បាប់ឡើងទៅ
- មានបទពិសោធន៍ក្នុងវិស័យច្បាប់ ឬយុត្តិធម៌យ៉ាងតិច ៥ឆ្នាំ
- មានអាយុមិនលើសពី ៤៥ឆ្នាំ គិតដល់កាលបរិច្ឆេទប្រឡង។

ដោយឡែកចំពោះមេធាវី ក៏អាចប្រឡងចូលក្របខណ្ឌនេះបានដែរ ដោយត្រូវគោរពតាមគោលការណ៍ទាំង ៣ចំណុច ខាងលើនេះ។

ក្នុងករណីដែលប្រឡងជាប់ក្នុងក្របខណ្ឌចៅក្រមតាមបញ្ញត្តិនៃកថាខណ្ឌទី១ ខាងលើនេះ ត្រូវទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈដែលត្រូវរៀបចំដោយក្រសួងយុត្តិធម៌។ ហើយបែបបទ និងនីតិវិធីនៃការប្រឡងប្រជែងផ្ទៃក្នុងខាងលើ និងចំនួននៃការជ្រើសរើសបញ្ចូលក្នុងក្របខណ្ឌចៅក្រមស្របតាមមាត្រានេះ ព្រមទាំងការរៀបចំ និងការប្រព្រឹត្តទៅនៃការបណ្តុះបណ្តាលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយសមាជិកទាំងអស់នៃឧត្តមក្រុមប្រឹក្សាអង្គចៅក្រម[1] ។

**កថាខណ្ឌទី៣ៈ លក្ខខណ្ឌក្នុងការតែងតាំង**

ការតែងតាំងរបស់សិស្សចៅក្រម ដែលបានបញ្ចប់ការបណ្តុះបណ្តាលវិជ្ជាជីវៈប្រកបដោយជោគជ័យត្រូវតែងតាំងដោយព្រះរាជក្រឹត្យជាចៅក្រមកម្មសិក្សា ក្នុងឋានន្តរសក្តិជាអនុចៅក្រមថ្នាក់ដំបូងគេ[2] ។

បន្ទាប់ពីបានបំពេញកម្មសិក្សារយៈពេល ១ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការតែងតាំងសព្វគ្រប់ ចៅក្រមកម្មសិក្សាដែលបានបំពេញកម្មសិក្សាចប់ដោយជោគជ័យ ត្រូវតាំងស៊ុបក្នុងក្របខណ្ឌចៅក្រម និងមានឋានន្តរសក្តិជាអនុចៅក្រមថ្នាក់ដំបូងគេ។

ក្នុងករណីចៅក្រមបំពេញកម្មសិក្សាដោយពុំបានទទួលបានជោគជ័យ ឬមានការអាក់ខានមិនបានធ្វើកម្មសិក្សាសរុបលើសពី ៣០ថ្ងៃ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម អាចសម្រេចឱ្យចៅក្រមកម្មសិក្សាបន្តធ្វើកម្មសិក្សា ១ឆ្នាំបន្ថែមទៀតបាន។ ប៉ុន្តែប្រសិនបើចៅក្រមកម្មសិក្សាណាដែលឈប់សម្រាកលើសពី ៣០ថ្ងៃ ដោយ

[1] មាត្រា ២៣ នៃច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា លេខ១៤៧/០០១/២០១៤ កបធ.ច ចុះថ្ងៃទី០២ កក្កដា ២០១៤។

[2] មាត្រា ២៤ កថាខណ្ឌទី ១ នៃច្បាប់ស្តីអំពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា លេខ១៤៧/០០១/២០១៤ កបធ.ច ចុះថ្ងៃទី០២ កក្កដា ២០១៤។

គ្មានការអនុញ្ញាត ឬមិនទទួលបានជោគជ័យនៅកំឡុងពេលកម្មសិក្សាម្តងទៀត ត្រូវលុបឈ្មោះចេញពីក្របខណ្ឌចៅក្រម ដោយមានការសម្រេចពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម[3] ។

**កថាខណ្ឌទី៤៖ ក្រមសីលធម៌ចៅក្រមស៊ើបសួរ**

ក្រមសីលធម៌របស់ចៅក្រម គឺជាមូលដ្ឋានដ៏សំខាន់របស់ប្រព័ន្ធយុត្តាធិការនៃប្រទេសកម្ពុជា។ ក្រមសីលធម៌នេះ សម្រាប់កសាងសង្គមនីតិរដ្ឋក៏ដូចជាពង្រឹងឱ្យប្រព័ន្ធយុត្តាធិការ និងជម្រុញឱ្យមានការគោរពតួនាទីរបស់ចៅក្រមឱ្យកាន់តែប្រសើរ។ ក្រមសីលធម៌នេះជាវិធានសម្រាប់តម្រង់ទិសឱ្យចៅក្រមយុត្តាធិការ ហើយចៅក្រមត្រូវតែចងចាំថាក្រមសីលធម៌ គឺជាកម្លាំងដាស់សតិអារម្មណ៍ឱ្យចៅក្រមអាចបំពេញមុខងារមិនហួសព្រំដែន និងផ្តល់នូវភាពជឿជាក់អំពីសាធារណៈជនចំពោះប្រព័ន្ធច្បាប់របស់តុលាការនៅក្នុងប្រទេសកម្ពុជា។ ជាពិសេសទៅទៀត ការបង្កើតនូវក្រមសីលធម៌ត្រូវតែស្របតាមស្តង់ដារអន្តរជាតិ។

ក្រមសីលធម៌របស់ចៅក្រមស៊ើបសួរ គឺត្រូវគោរពតាមគោលការណ៍ទាំង ៥ គឺ ៖

- គោលការណ៍ឯករាជភាព
- គោលការណ៍អនាគតិ (ភាពមិនលម្អៀង)
- គោលការណ៍ភាពសុចរិត
- គោលការណ៍សេចក្តីថ្លៃថ្នូរ
- និងគោលការណ៍វិរិយភាព (ភាពលឿនរហ័ស)[4] ។

**១. គោលការណ៍ឯករាជភាព**

ចៅក្រមត្រូវបំពេញភារកិច្ចរបស់ខ្លួនដោយឯករាជ្យ ឈរលើមូលដ្ឋាននៃការវាយតម្លៃលើអង្គហេតុ និងផ្អែកលើចំណេះដឹងផ្នែកច្បាប់ ដោយមិនត្រូវទទួលរងនូវឥទ្ធិពលផ្សេងៗដូចជា ការអូសទាញ ការគាបសង្កត់ ការគំរាមកំហែង ឬការជ្រៀតជ្រែកពីសំណាក់ជនណាម្នាក់ ឬច្រើននាក់ ឬហេតុផលអ្វីមួយ ទោះដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី ដើម្បីបង្ហាញឱ្យគេមើលឃើញថា ជាបុគ្គលមានចរិតយុត្តិធម៌ និងមានមូលគតិច្បាស់លាស់ក្នុងការវិនិច្ឆ័យសេចក្តីរបស់ខ្លួន[5] ។

**២. គោលការណ៍អនាគតិ** (**ភាពមិនលម្អៀង**)

ចៅក្រមត្រូវមានអាកប្បកិរិយាទាំងក្នុង និងក្រៅតុលាការនូវលក្ខណៈអនាគតិរបស់ខ្លួនដើម្បីការពារថែរក្សា និងលើកកម្ពស់ជំនឿទុកចិត្តពីសំណាក់សាធារណជន អ្នកមានវិជ្ជាជីវៈច្បាប់ និងគូភាគីវិវាទ[6] ។

**៣. គោលការណ៍ភាពសុចរិត**

[3] មាត្រា ២៥ នៃច្បាប់ស្តីអំពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា លេខ១៤៧/០០១/២០១៤ កបធ.ច ចុះថ្ងៃទី០២ កក្កដា ២០១៤។

[4] ច្បាប់ស្តីពីក្រមសីលធម៌ចៅក្រម ២២ កុម្ភៈ ២០០៧។

[5] ប្រការ២ នៃច្បាប់ស្តីពីក្រមសីលធម៌ចៅក្រម ២២ កុម្ភៈ ២០០៧។

[6] ប្រការ ២ កថាខណ្ឌទី១ នៃច្បាប់ស្តីពីក្រមសីលធម៌ចៅក្រម ២២ កុម្ភៈ ២០០៧។

បុគ្គលសុចរិត គឺជាបុគ្គលដែលទៀងត្រង់មិនប្រព្រឹត្តអំពើពុករលួយ។ គោលការណ៍មូលដ្ឋាននៃសីលធម៌ដែលបុគ្គលសុចរិតត្រូវគោរពតាម និងមិនប្រែប្រួលឡើយ ទោះបីជាខ្លួននៅក្នុងតុលាការ ឬធ្វើសកម្មភាពផ្សេងនៅក្រៅតុលាការក៏ដោយ។ នោះគឺជាគុណភាពនៃភាពសុចរិត ដែលអាចធ្វើឱ្យចៅក្រមរក្សាបាននូវឯករាជភាព និងអនាគតិទាំងទិដ្ឋភាពខាងក្នុង និងទិដ្ឋភាពខាងក្រៅ[7] ។

**៤. គោលការណ៍សេចក្តីថ្លៃថ្នូរ**

ចៅក្រមត្រូវតែចងចាំថា ខ្លួនជាបុគ្គលដែលស្ថិតក្រោមការឃ្លាំមើលអចិន្ត្រៃយ៍ពីសាធារណជន។ ដូច្នេះ ចៅក្រមត្រូវតែទទួលយកការកាត់បន្ថយនូវសេរីភាព និងឆន្ទៈផ្ទាល់ខ្លួនខ្លះដើម្បីឱ្យប្រជាពលរដ្ឋមើលឃើញថាមានតម្លៃ[8] ។

**៥. គោលការណ៍វិរិយភាព ( ភាពលឿនរហ័ស )**

ចៅក្រមត្រូវធានាថា ខ្លួនបំពេញកិច្ចការតុលាការ ឬអយ្យការប្រកបដោយវិរិយភាព គឺត្រូវព្យាយាមខិតខំប្រឹងប្រែងបំពេញកិច្ចការតុលាការឱ្យបានឆាប់រហ័ស និងមានសុក្រឹតភាព ថែរក្សា និងបង្កើននូវចំណេះដឹងជំនាញរបស់ខ្លួន ដើម្បីបំពេញកិច្ចការតុលាការ ឬអយ្យការឱ្យបានសុក្រឹត្យ និងមានគុណភាព។ បន្ថែមពីនេះ ចៅក្រមមិនត្រូវធ្វើកិច្ចការអ្វីដែលមានវិសមិតភាពជាមួយនឹងការទទួលខុសត្រូវប្រកបដោយវិរិយភាពនៃកិច្ចការតុលាការ ឬអយ្យការឡើយ[9] ។

## ផ្នែកទី២៖ ការចាត់តាំងចៅក្រមស៊ើបសួរដោយប្រធានតុលាការ

### កថាខណ្ឌទី១៖ ការចាត់តាំងសំណុំរឿងដោយប្រធានតុលាការ

ចៅក្រមស៊ើបសួរត្រូវបានតែងតាំងដើម្បីធ្វើការស៊ើបសួររឿងក្តីព្រហ្មទណ្ឌណាមួយ តាមសេចក្តីសម្រេចរបស់ប្រធានតុលាការរាជធានី/ខេត្ត។ ក៏ប៉ុន្តែប្រសិនបើចៅក្រមស៊ើបសួរមានបញ្ហាដោយសារការឈប់សម្រាក ឬដោយមានជម្ងឺ ឬដោយមូលហេតុដទៃទៀតពុំអាចបំពេញមុខងាររបស់ខ្លួនបាននោះ តុលាការមានសិទ្ធិចាត់តាំងជាបណ្តោះអាសន្នទៅឱ្យចៅក្រមស៊ើបសួរផ្សេងទៀត ឱ្យមកបំពេញមុខងារនេះហើយចំពោះដីកាចាត់តាំងនេះគឺមិនអាចធ្វើការបើកផ្លូវតវ៉ាឡើយ[10] ។

### កថាខណ្ឌទី២៖ ការបែងចែកសំណុំរឿង

ការបែងចែកសំណុំរឿងរបស់ចៅក្រមស៊ើបសួរគឺប្រព្រឹត្តទៅដោយ កាលណាមានចៅក្រមស៊ើបសួរច្រើនរូបនៅក្នុងតុលាការមួយ សំណុំរឿងទាំងឡាយត្រូវធ្វើការបែងចែកដោយ ប្រធានតុលាការដែលធ្វើការបែងចែករឿង

[7] ប្រការ ១៨ នៃច្បាប់ស្តីពីក្រមសីលធម៌ចៅក្រម ២២ កុម្ភៈ ២០០៧។
[8] ប្រការ ២៤ នៃច្បាប់ស្តីពីក្រមសីលធម៌ចៅក្រម ២២ កុម្ភៈ ២០០៧។
[9] ប្រការ ២៩ នៃច្បាប់ស្តីពីក្រមសីលធម៌ចៅក្រម ២២ កុម្ភៈ ២០០៧។
[10] មាត្រា ៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។

រាល់ឆ្នាំម្តង[11] ។ មានន័យថា នៅក្នុងតុលាការរាជធានី/ខេត្តមួយអាចមានចៅក្រមស៊ើបសួរច្រើនរូប ដើម្បីឱ្យរឿងក្តីមួយមានភាពលឿនរហ័សរលូន និងយុត្តិធម៌ជូនគូភាគី ប្រធានតុលាការធ្វើការបែងចែកសំណុំរឿងទៅឱ្យចៅក្រមស៊ើបសួរនីមួយៗនៅក្នុងតុលាការរាជធានី/ខេត្ត តាមការយល់ឃើញរបស់ខ្លួនដោយការបែងចែកសំណុំរឿងនេះធ្វើឡើងក្នុងរយៈពេលមួយឆ្នាំធ្វើការបែងចែកម្តង។

ការបែងចែកសំណុំរឿងនេះ គឺត្រូវធ្វើឡើងទៅតាមលំដាប់លេខរៀងរបស់ចៅក្រមម្នាក់ៗ ដោយលេខរៀងរបស់ចៅក្រមម្នាក់ៗពុំមានសិទ្ធិធ្វើការផ្លាស់ប្តូរនៅក្នុងឆ្នាំនោះឡើយ។ ក៏ប៉ុន្តែមានករណីខ្លះលើកលែងអាចធ្វើការប្តូរលេខរៀងបានដោយមូលហេតុថា ចៅក្រមស៊ើបសួររូបនោះមានការងារច្រើនពេក ឬក៏ត្រូវប្តូរទៅតុលាការផ្សេងទៀត។ នៅក្នុងករណីនេះប្រធានតុលាការត្រូវចេញដីកាចាត់តាំងមួយថ្មីទៀតដើម្បីចាត់តាំងចៅក្រមស៊ើបសួរមួយផ្សេងទៀតឱ្យបំពេញការងារនេះជំនួសចៅក្រមដែលមានធុរៈមិនអាចបំពេញការងារនេះបាន។

**កថាខណ្ឌទី៣៖ ការដកហូតសំណុំរឿង**

យោងតាមមាត្រា ៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌការដកហូតសំណុំរឿងរបស់ចៅក្រមស៊ើបសួរទៅឱ្យចៅក្រមស៊ើបសួរណាម្នាក់ផ្សេងទៀតគឺត្រូវតែធ្វើពាក្យស្នើសុំទៅប្រធានតុលាការ ដោយការស្នើសុំនេះតម្រូវឱ្យធ្វើឡើងដោយមានពាក្យសុំជាលាយលក្ខណ៍អក្សរដែលជាសំអាងហេតុរបស់ព្រះរាជអាជ្ញា (ចៅក្រមអយ្យការ) ។ បន្ថែមពីនេះការដកហូតសំណុំរឿងត្រូវតែមានការបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់ដូចជា ចៅក្រមស៊ើបសួរ ឬសហព័ទ្ធរបស់ចៅក្រម ឬចៅក្រមជាញាតិលោហិតរបស់ភាគីណាមួយ[12] ។

**ផ្នែកទី៣៖ តួនាទីរបស់ចៅក្រមស៊ើបសួរ**

**កថាខណ្ឌទី១៖ គោលបំណងនៃការបើកការស៊ើបសួរ**

គោលបំណងនៃការបើកការស៊ើបសួរ គឺដើម្បីស្រាវជ្រាវរកភស្តុតាងឱ្យបានគ្រប់គ្រាន់តាមរយៈការស៊ើបសួររបស់មន្ត្រីនគរបាលយុត្តិធម៌ក្រោមការដឹកនាំពីព្រះរាជអាជ្ញា។ ជាទូទៅនៅក្នុងរឿងក្តីព្រហ្មទណ្ឌការបើកការស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ និងការសាកសួរនៅក្នុងដំណាក់កាលអយ្យការពុំទាន់អាចប្រមូលបានអង្គហេតុ និងភស្តុតាងបានពេញលេញដែលអាចបញ្ជូនជនសង្ស័យនោះទៅជំនុំជម្រះបាននៅឡើយទេ ពីព្រោះគេចាត់ទុកថាដំណាក់កាលចោទប្រកាន់នេះជាដំណាក់កាលស៊ើបអង្កេតបឋម។ ដូច្នេះហើយទើបនីតិវិធីច្បាប់តម្រូវឱ្យមានការបើកការស៊ើបសួរ ដើម្បីធ្វើយ៉ាងណាស្វែងរកការពិត និងភាពយុត្តិធម៌ដល់ជនដែលត្រូវបានចោទប្រកាន់ និងជនទាំងឡាយដែលពាក់ព័ន្ធដទៃទៀត ដោយការចោទសួរនោះគឺដើម្បីចង់ដឹងថាជនត្រូវចោទបានប្រព្រឹត្តបទល្មើសដូចការចោទប្រកាន់មែន ឬមិនមែន និងដើម្បីស្វែងរកការពិតឱ្យលឿនរហ័សចំពោះជនដែលត្រូវបានចោទប្រកាន់ប្រសិនបើជនដែលត្រូវបានចោទប្រកាន់ នោះមិនមានភស្តុតាងគ្រប់គ្រាន់ក្នុង

[11] មាត្រា ៥២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។

[12] មាត្រា ៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។

ការដាក់បន្ទុក ឬមានភស្តុតាងចង្អុលបង្ហាញឃើញថា គ្មានជាប់ពាក់ព័ន្ធក្នុងរឿងក្តីនោះក្រោយការស៊ើបសួររបស់ចៅក្រមស៊ើបសួរ ដែលត្រូវបានចោទប្រកាន់នោះនឹងត្រូវដោះលែងឱ្យមានសេរីភាពវិញ ដោយដីកាដំណោះស្រាយដែលចេញដោយចៅក្រមស៊ើបសួរ ស្របតាមតាមមាត្រា ២៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**កថាខណ្ឌទី២៖ ថិរវេលានៃការស៊ើបសួរ**

ថិរវេលានៃការស៊ើបសួរ គឺមិនមានច្បាប់ណាដែលបានចែងច្បាស់លាស់អំពីថិរវេលានៃការស៊ើបសួរជាក់លាក់ឡើយ។ ក៏ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយដើម្បីធានាឱ្យបាននូវសិទ្ធិរបស់ជនត្រូវចោទ ច្បាប់ក៏បានផ្តល់សិទ្ធិឱ្យជនត្រូវចោទដែលស្ថិតនៅក្នុងការឃុំខ្លួនបណ្តោះអាសន្នក្នុងករណីការប្តឹងមកចៅក្រមស៊ើបសួរក្នុងគោលបំណងចង់ឱ្យសម្រេចបិទបញ្ចប់នៃការស៊ើបសួរនេះ ប្រសិនបើផុតរយៈពេលកំណត់ ១ឆ្នាំ (បណ្តឹងសុំបិទសំណុំរឿង) ស្របតាមមាត្រា ២៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ[13] ។

**កថាខណ្ឌទី៣៖ សមត្ថកិច្ចដែនដី**

ក្នុងនីតិវិធីនៃការស៊ើបសួរ ចៅក្រមស៊ើបសួរ ដែលមានសមត្ថកិច្ចដែនដីដើម្បីបំពេញតួនាទីរបស់ខ្លួនស្របតាមមាត្រា ១២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌដូចខាងក្រោម៖

- ចៅក្រមស៊ើបសួរនាទីកន្លែងដែលបទល្មើសបានកើតឡើង
- ចៅក្រមស៊ើបសួរនាទីលំនៅឋាន ឬទីសំណាក់របស់បុគ្គលដែលសង្ស័យថាបានប្រព្រឹត្តបទល្មើស
- ចៅក្រមស៊ើបសួរនៅទីកន្លែងដែលចាប់ខ្លួនបុគ្គលដែលសង្ស័យថាបានប្រព្រឹត្តបទល្មើស។

ប្រសិនបើមានទំនាស់សមត្ថកិច្ចរវាងចៅក្រមស៊ើបសួរនៃសាលាដំបូងខុសគ្នាដែលទទួលបណ្តឹងទាំងអស់នោះ អំពីរឿងព្រហ្មទណ្ឌតែមួយដូចគ្នាត្រូវជូនដំណឹងទៅ ប្រធានសភាស៊ើបសួរដើម្បីសម្រេច។

ករណីសមត្ថកិច្ចដែនដីសភាស៊ើបសួរច្រើន ខុសគ្នា ត្រូវសម្រេចដោយប្រធានតុលាការកំពូល ដោយការសម្រេចនេះបិទផ្លូវតវ៉ា[14] ។

**កថាខណ្ឌទី៤៖ សមត្ថកិច្ចសាច់រឿង**

ចៅក្រមស៊ើបសួរ អាចធ្វើការស៊ើបសួរទៅបានដោយមានដែនសមត្ថកិច្ចរបស់ខ្លួន ក៏ដូចជាទៅតាមប្រភេទនៃរឿងក្តីផងដែរ។ ក្នុងករណីមានបណ្តឹងពីព្រះរាជអាជ្ញា ឬពីជនរងគ្រោះតាមរយៈបណ្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទៅចៅក្រមស៊ើបសួរ ឬចំពោះបទឧក្រិដ្ឋ ចៅក្រមស៊ើបសួរត្រូវតែធ្វើការស៊ើបសួរជាដាច់ខាតដោយស្របតាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរពីព្រះរាជអាជ្ញា និងចំពោះការស៊ើបសួរបទមជ្ឈិមវិញអាចត្រូវធ្វើ ឬមិនធ្វើក៏បានដែរ[15] ។

---

[13] មាត្រា ២៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។

[14] មាត្រា ១២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។

[15] មាត្រា ១២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។

ចៅក្រមស៊ើបសួរមិនអាចបំពេញកិច្ចស៊ើបសួរណាមួយបានដោយគ្មានដីកាបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញាបានទេ។ កាលណាចៅក្រមស៊ើបសួរ ទទួលពាក្យបណ្ដឹងដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ចៅក្រមស៊ើបសួរត្រូវតែធ្វើតាមនីតិវិធី ដោយស្របទៅតាមមាត្រា ១៣៩ (ការបញ្ជូនបណ្ដឹងទៅព្រះរាជអាជ្ញា) និងមាត្រា ១៤០ (ការបង់ប្រាក់តម្កល់ទុក) នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ កាលណាទទួលពាក្យបណ្ដឹងសាមញ្ញចៅក្រមស៊ើបសួរត្រូវតែបញ្ជូនបណ្ដឹងនោះទៅព្រះរាជអាជ្ញា[16] ។

[16] មាត្រា ១២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។

# ជំពូកទី២

# ដំណើរការស៊ើបសួររបស់មន្ទីរ
# ស៊ើបសួរក្នុងរឿងព្រហ្មទណ្ឌ

# ជំពូកទី២

# ដំណើរការស៊ើបសួររបស់មន្ទីរស៊ើបសួរ សាលាដំបូងរាជធានី/ខេត្ត

## ផ្នែកទី១ ៖ ការបញ្ជូនរឿងឱ្យស៊ើបសួរ

### កថាខណ្ឌទី ១ ៖ លក្ខខណ្ឌនៃការចោទប្រកាន់របស់ព្រះរាជអាជ្ញា

នៅតាមសាលាដំបូងរាជធានី/ខេត្តនីមួយៗ មានស្ថាប័នអយ្យការអមសាលាដំបូងរាជធានី/ខេត្ត ដែលមានសមត្ថកិច្ច ភូមិសាស្ត្រដូចគ្នាបានសេចក្ដីថាលើផ្ទៃដីរាជធានី/ខេត្តដែលមានអង្គការតុលាការនោះស្ថិតនៅ ក៏មានស្ថាប័នអយ្យការអមសាលាដំបូងរាជធានី/ខេត្តដែរ។ ស្ថាប័នអយ្យការមានសមត្ថកិច្ចលើបទល្មើសព្រហ្មទណ្ឌមួយដែលកើតឡើងនៅក្នុងរាជធានី/ខេត្តនោះដែលជាដែនសមត្ថកិច្ច។ ហើយនៅពេលដែលមានបទល្មើសកើតឡើងដល់ដំណាក់កាលចោទប្រកាន់ គឺជាដំណាក់កាលមួយដែលធ្វើឡើងដោយតំណាងអង្គការអយ្យការ។ អង្គការអយ្យការគឺជាស្ថាប័នមួយដែលមាននៅអមគ្រប់សាលាជម្រះក្ដីទាំងអស់ដែលជាអ្នកតំណាងឱ្យសង្គម និងជាអ្នកតំណាងឱ្យផលប្រយោជន៍ទូទៅ ហើយមានតួនាទីជាអ្នកធ្វើការចោទប្រកាន់ខាងផ្នែកបទល្មើសព្រហ្មទណ្ឌ (អ្នកធ្វើបណ្ដឹងអាជ្ញា)[17] និងសន្និដ្ឋានឱ្យតុលាការអនុវត្តច្បាប់ ព្រមទាំងជាអ្នកធានារ៉ាប់រងការអនុវត្តនូវសេចក្ដីសម្រេចខាងព្រហ្មទណ្ឌ និងធានាយកចិត្តទុកដាក់លើការផ្សព្វផ្សាយដីកាបង្គាប់ឱ្យចាប់ខ្លួន និងនីតិវិធីផ្សេងទៀត។ ព្រះរាជអាជ្ញាត្រូវធានាឱ្យបានថា ធាតុផ្សំនៃបទល្មើសព្រហ្មទណ្ឌដូចដែលមានសព្វគ្រប់ហើយ ត្រូវវាយតម្លៃកំណត់សមស្របទៅនឹងអំពើដោយពិនិត្យទៅលើធាតុផ្សំសត្យានុម័ត ធាតុផ្សំអត្តនោម័ត និងពិនិត្យទៅលើករណីមានអភ័យឯកសិទ្ធដែរឬទេ ជនល្មើសត្រូវចោទប្រកាន់ក្នុងនាមជាអ្វីមួយ (ចារី សហចារី អ្នកសមគំនិត ឬអ្នកផ្ដើមគំនិត) ជាដើម។ មុននឹងសម្រេចការចោទប្រកាន់ ព្រះរាជអាជ្ញាបើកការស៊ើបអង្កេតបឋម ឬបង្គាប់ឱ្យធ្វើការស្រាវជ្រាវបន្ថែម[18] ។ នៅពេលដែលព្រះរាជអាជ្ញាបានអនុវត្តតាមទៅតាមនីតិវិធីរួមមក ព្រះរាជអាជ្ញាអាចធ្វើការសម្រេច តម្កល់រឿងទុកឥតចាត់ការ និងធ្វើការចោទប្រកាន់។ មកដល់ដំណាក់កាលចោទប្រកាន់នេះដែរ ព្រះរាជអាជ្ញាអាចនឹងត្រូវធ្វើតាម ៣វិធីមាន ការបើកធ្វើការស៊ើបសួរ ការបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬតាមនីតិវិធីឱ្យចូលបង្ហាញខ្លួន[19] ។ នៅពេលស្របគ្នាក្នុងដំណាក់កាលចោទប្រកាន់នេះដែរ ព្រះរាជអាជ្ញា ត្រូវធ្វើការត្រួតពិនិត្យលើ (ការពិនិត្យលើព្យសនកម្មនៃបទល្មើស និងសិទ្ធិសេរីភាពក្នុងការចោទប្រកាន់របស់ព្រះរាជអាជ្ញា) ដើម្បីឱ្យកាន់តែច្បាស់លាស់ក្នុងនីតិវិធីនោះ ។

[17] មាត្រា ១៣១ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ២៤ កញ្ញា ១៩៩៣។

[18] មាត្រា ៤០ កថាខណ្ឌទី ២ វាក្យខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។

[19] មាត្រា ៤៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។

**១. ការពិនិត្យនៅលើលក្ខខណ្ឌនៃបទល្មើស**

ជាក់ស្ដែងការវាយតម្លៃស្ថានភាពព្យសនកម្មនៃបទល្មើសឬលក្ខខណ្ឌនៃបទល្មើស ទៅតាមសំណុំរឿង ឬនីតិវិធីដែលអាចធ្វើឱ្យព្រះរាជអាជ្ញាយល់ពីភាពចាំបាច់ ក្នុងការស្រាវជ្រាវបន្ថែម និងការស៊ើបអង្កេតបឋម ដើម្បីទទួលបានភស្តុតាងដែលអនុវត្តបណ្ដឹងអាជ្ញាដោយភាពសមហេតុផល។ នៅក្នុងនោះផងដែរព្រះរាជអាជ្ញាមានផ្លូវពីរ បន្តការស៊ើបអង្កេត និងធ្វើបណ្ដឹងទៅចៅក្រមស៊ើបសួរ ក៏ប៉ុន្តែការប្ដឹងទៅយុត្តាធិការស៊ើបសួរ ត្រូវធ្វើឡើងតាមរយៈសេចក្ដីសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ[20] ។ ក្របខណ្ឌនៃការត្រួតពិនិត្យរបស់ព្រះរាជអាជ្ញា ចាំបាច់ត្រូវការត្រួតពិនិត្យទៅលើប្រភេទនៃបទល្មើសព្រហ្មទណ្ឌជាមុនសិន មុននឹងធ្វើការចោទប្រកាន់ដែលក្នុងនោះរួមមានបទល្មើស ៣ប្រភេទ បទលហុ បទមជ្ឈិម និងបទឧក្រិដ្ឋ។ ប៉ុន្តែក្នុងករណីបទឧក្រិដ្ឋ ព្រះរាជអាជ្ញាត្រូវតែបើកការស៊ើបសួរជាដាច់ខាត។ ការស៊ើបសួរត្រូវបានបើកតាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដែលត្រូវបានប្ដឹងទៅចៅក្រមស៊ើបសួរ។ ការស៊ើបសួរអាចប្រឆាំងលើបុគ្គលម្នាក់ ឬច្រើននាក់ ដោយមានចង្អុលប្រាប់ឈ្មោះ ឬប្រឆាំងទៅលើអញ្ញាតជន[21] ។ ចំពោះការស៊ើបសួរក៏មិនមានលក្ខណៈដាច់ខាតទេ ក្នុងករណីដែលមានបទល្មើសជាបទមជ្ឈិម ព្រះរាជអាជ្ញា អាចបើកការស៊ើបសួរក៏បានដែរ[22] ។ ក៏ប៉ុន្តែបើជាបទលហុ ការបើកការស៊ើបសួរមិនអាចធ្វើបានទេ។ ដើម្បីឱ្យកាន់តែច្បាប់អំពីលក្ខខណ្ឌចំពោះបទល្មើសនីមួយៗដែលអាចត្រូវបានបើកការស៊ើបសួរបានដូចខាងក្រោម៖

**១.១. បទល្មើសជាបទលហុ**

កាលណាគេរកឃើញបទល្មើសជាបទលហុ មិនត្រូវមានការបើកការស៊ើបសួរទេពីព្រោះថាបទលហុគឺជាប្រភេទបទល្មើសដែលកម្រិតទោសអតិបរមាទោសដាក់ពន្ធនាគារដែលត្រូវរងនោះមានរយៈពេលមិនក្រោម ឬស្មើនឹង ៦ (ប្រាំមួយ) ថ្ងៃ។ ទោសដាក់ពន្ធនាគារអាចត្រូវបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ។ បទល្មើសត្រូវផ្ដន្ទាទោសត្រឹមតែពិន័យប្រាក់ប៉ុណ្ណោះ[23] ។ ដោយសារតែមានកម្រិតទោសមានលក្ខណៈស្រាលក្រោយពេលដែលព្រះរាជអាជ្ញាធ្វើការស៊ើបអង្កេត និងស្រាវជ្រាវមានភាពច្បាប់លាស់រួចរាល់ ព្រះរាជអាជ្ញាអាចបញ្ជូនរឿងនេះទៅជំនុំជម្រះផ្ទាល់ នៅមុខសាលាដំបូងនៃសាលាជម្រះក្ដីបានតែម្ដង។ ជនជាប់ចោទដែលប្រព្រឹត្តនូវបទល្មើសជាបទលហុក៏មានសិទ្ធិក្នុងការធ្វើការពឹងពាក់មេធាវីឱ្យការពារក្ដីរបស់ខ្លួន ឬអមខ្លួនផងដែរ នៅពេលតុលាការបានធ្វើការកោះហៅតាមដីកាកោះបញ្ជូនរឿងទៅជំនុំជម្រះ។

ឧទាហរណ៍៖ ការបើកបរដោយមិនគោរពច្បាប់ចរាចរណ៍, ការជេរប្រមាថមន្ត្រីរាជការសាធារណៈ, ការបរិហាកេរ្តិ៍ ឬជេរប្រមាថជាសាធារណៈ, ការបង្ហាញនូវភាពស្រវឹងនៅទីសាធារណៈ......។ល។

---

[20] ឧបសម្ព័ន្ធ

[21] មាត្រា៤៤ កថាខណ្ឌទី១ និងកថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌលេខ, នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។

[22] មាត្រា៤៥ កថាខណ្ឌទី១ និងចំណុចទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។

[23] មាត្រា៤៨ កថាខណ្ឌទី១ និងកថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។

**១.២. បទល្មើសជាបទមជ្ឈិម**

នៅពេលព្រះរាជអាជ្ញាបានទទួលនូវពាក្យបណ្ដឹងពីជនរងគ្រោះ ឬមន្ត្រីនគរបាលយុត្តិធម៌ ដែលបានពិនិត្យស្រាវជ្រាវ ឬស៊ើបអង្កេតបឋម មានបទល្មើសកើតឡើងដែលបានរកឃើញថា ជាបទមជ្ឈិម ច្បាប់បានចែងថា បទល្មើសជាបទមជ្ឈិម នៅក្នុងករណីដែលអតិបរមានៃទោសដាក់ពន្ធនាគារលើសពី ៦ (ប្រាំមួយ) ថ្ងៃ និងក្រោម ឬស្មើនឹង ៥ (ប្រាំ) ឆ្នាំ។ ទោសដាក់ពន្ធនាគារ អាចត្រូវបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ[24] ។ ក៏ប៉ុន្តែនៅក្នុងច្បាប់បានចែង ក្នុងករណីបទឧក្រិដ្ឋ ព្រះរាជអាជ្ញា ត្រូវតែបើការស៊ើបសួរ[25] ។ ដូច្នេះបានជាក្នុងករណីមួយចំនួន បទល្មើសជាបទមជ្ឈិម ព្រះរាជអាជ្ញាអាចបើកការស៊ើបសួរ[26] ។ ការបើកការស៊ើបសួរចំពោះបទមជ្ឈិមជាក់ស្តែង ការបើកការស៊ើបសួរទៅលើសំណុំរឿងដែលមានភាពស្មុគស្មាញ មានភាពសាំញ៉ាំ និងកង្វះភស្តុតាង ត្រូវចេញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដោយព្រះរាជអាជ្ញា។ ដោយហេតុថា បទល្មើសជាបទមជ្ឈិម ដែលមានលក្ខណៈស្មុគស្មាញមិនមាននៅភស្តុតាងគ្រប់គ្រាន់ការចោទប្រកាន់ស្ថិតនៅក្នុងស្ថានភាពជា អញ្ញតជន ដែលគេអាចហៅម្យ៉ាងទៀតបានថា សំណុំរឿងមិនទាន់មូល ព្រះរាជអាជ្ញាតម្រូវឱ្យមានការបើកការស៊ើបសួរដើម្បីបញ្ចៀសអំពីកំហុសនៃការចោទប្រកាន់ (ធាតុផ្សំបទល្មើសមិនច្បាស់លាស់) ដោយបញ្ជូនសំណុំរឿងឱ្យស៊ើបសួរតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។

ឧទាហរណ៍៖ បទមនុស្សឃាតដោយអចេតនា, លួច, បង្ករបួសស្នាម (ហិង្សាដោយចេតនា), បទឆបោក បទរំលោភលើទំនុកចិត្ត , បទទទួលផលចោទកម្ម និងបទល្មើសគំរាមកំហែងកេរ្តិ៍ជាដើម....។ល។

**១.៣. បទល្មើសជាបទឧក្រិដ្ឋ**

បទល្មើសជាបទឧក្រិដ្ឋ នៅក្នុងករណីដែលអតិបរមានៃទោសពន្ធនាគារដែលត្រូវមាន ជាទោសដាក់ពន្ធនាគារអស់មួយជីវិត និងបទល្មើសដាក់ពន្ធធនាគារមានរយៈពេលលើសពី ៥ (ប្រាំ) ឆ្នាំ និងក្រោមឬស្មើ ៣០ (សាមសិប)ឆ្នាំ និងអាចត្រូវបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ[27] ។ នៅក្នុងករណីបទល្មើសជាបទឧក្រិដ្ឋ ព្រះរាជអាជ្ញាត្រូវតែបញ្ជូនសំណុំរឿង ធ្វើការស៊ើបសួរដោយខានពុំបាន។ ការបើកការស៊ើបសួរត្រូវធ្វើឡើងតាមដីកាសន្និដ្ឋានបញ្ជូនរឿងទៅស៊ើបសួរ។ ព្រះរាជអាជ្ញា មិនអាចធ្វើការចោទប្រកាន់ដោយពុំបានការឆ្លងកាត់នូវនីតិវិធីស៊ើបសួរបានឡើយ។ ដោយសារតែបទឧក្រិដ្ឋជាប្រភេទបទល្មើសដែលមានអតិបរមានៃទោសពន្ធនាគារមានភាពធ្ងន់ធ្ងរ និងជៀសវាងមានការភាន់ច្រឡំនៅត្រង់ចំណុចណាមួយ ដែលអាចប៉ះពាល់ដល់ជនជាប់ចោទផងដែរ។ ការស៊ើបសួរត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរ។ ការស៊ើបសួររួមមានទាំងភស្តុតាងដាក់

[24] មាត្រា៤៧ កថាខណ្ឌទី១ និងកថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។
[25] មាត្រា៤៤ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។
[26] មាត្រា៤៥ កថាខណ្ឌទី១ វាក្យខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។
[27] មាត្រា៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។

បន្ទុក និងភស្តុតាងដោះបន្ទុក ដើម្បីពិនិត្យឱ្យបានជាក់លាក់នូវអំពើដែលបានស្តែងចេញដឹងពីការពិត និងបង្ហាញឱ្យបានដឹងពីប្រព័ន្ធយុត្តាធិការតុលាការប្រកបដោយភាពយុត្តិធម៌ជូនអ្នកដែលបានរងគ្រោះពិតប្រាកដ។

ឧទាហរណ៍៖ បទឃាតកម្ម , បទឃាតកម្មគិតទុកជាមុន , បទធ្វើទារុណកម្ម , អំពើឃោរឃៅ , និងបទរំលោភសេពសន្ថវៈជាដើម..... ។ល។

ក្រោយពីព្រះរាជអាជ្ញាបានពិនិត្យចប់សព្វគ្រប់ទៅតាមដំណើរការនីតិវិធីរួចមក ព្រះរាជអាជ្ញាក៏មានសិទ្ធិមួយទៀតដែរ គឺសិទ្ធិសេរីភាពក្នុងការចោទប្រកាន់របស់ព្រះរាជអាជ្ញា។

**២. សិទ្ធិសេរីភាពក្នុងការចោទប្រកាន់របស់ព្រះរាជអាជ្ញា**

ជាគោលការណ៍នៃច្បាប់ ព្រះរាជអាជ្ញាមានសិទ្ធិពេញលេញក្នុងការចោទប្រកាន់ ឬមិនចោទប្រកាន់លើបទល្មើសព្រហ្មទណ្ឌ។ ដោយអនុលោមតាមមាត្រា ២៣២ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា បានកំណត់ថាមានតែអង្គការអយ្យការទេ ដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា។ ដោយហេតុថាព្រះរាជអាជ្ញា ស្ថិតនៅក្នុងអង្គការអយ្យការដែលមានឋានានុក្រម ដូច្នេះព្រះរាជអាជ្ញាត្រូវធ្វើតាមបង្គាប់របស់ថ្នាក់លើ តាមឋានានុក្រមរបស់ខ្លួនដែលបង្គាប់បញ្ជាឱ្យធ្វើការចោទប្រកាន់លើបទល្មើសអ្វីមួយ ទោះបីជាព្រះរាជអាជ្ញាយល់ឃើញថាពុំត្រូវចោទប្រកាន់ក៏ដោយក៏ត្រូវមានការកត់ចំណាំផងដែរថាមានតែបញ្ជាឱ្យធ្វើការចោទប្រកាន់តែប៉ុណ្ណោះដែលព្រះរាជអាជ្ញាត្រូវអនុវត្តតាម តែបើមានបញ្ជាមិនឱ្យមានការមិនចោទប្រកាន់ហើយ គឺព្រះរាជអាជ្ញាពុំអាចដកការចោទប្រកាន់របស់ខ្លួនបានឡើយ។

**កថាខណ្ឌទី២ ៖ ការសម្រេចចោទប្រកាន់របស់ព្រះរាជអាជ្ញា**

កាលណាព្រះរាជអាជ្ញាធ្វើការស្រាវជ្រាវបឋម និងធ្វើការស៊ើបអង្កេតដែលទទួលបានភស្តុតាងធ្ងន់ល្មមអាចជឿបានថាជនសង្ស័យអាចនឹងប្រព្រឹត្តអំពើនោះមែន ព្រះរាជអាជ្ញាអាចធ្វើការចោទប្រកាន់ធ្វើឡើងតាមរយៈការជ្រើសរើសនៃនីតិវិធីដូចខាងក្រោម៖

**១. ការបញ្ជូនទៅជំនុំជម្រះដោយផ្ទាល់**

ការបញ្ជូនទៅជំនុំជម្រះដោយផ្ទាល់ គឺត្រូវបានធ្វើឡើងតាមដីកាកោះហៅបញ្ជូនទៅជំនុំជម្រះដោយផ្ទាល់[28] គឺជាបញ្ជាឱ្យជនជាប់ចោទចូលទៅបង្ហាញខ្លួន មុខតុលាការជាន់ដំបូង ដោយពុំចាំបាច់មានការស្រាវជ្រាវផ្សេងទៀតនោះទេ។ នីតិវិធីនេះគឺគ្រប់បទលហុទាំងអស់តុលាការត្រូវប្រើប្រាស់វិធីនេះ។ ក៏ប៉ុន្តែចំពោះ បទមជ្ឈិមមួយចំនួនតុលាការក៏អាចប្រើប្រាស់វិធីនេះបានដែរ។ នៅក្នុងដីកាកោះហៅបញ្ជូនទៅជំនុំជម្រះដោយផ្ទាល់រួមមាន៖

- អត្តសញ្ញាណនៃជនជាប់ចោទ
- សេចក្តីសង្ខេបនៃអង្គហេតុ

[28] ឧបសម្ព័ន្ធ

- ឈ្មោះបទល្មើស
- អត្ថបទច្បាប់ដែលបានកំណត់ និងបង្ក្រាបបទល្មើស

ដីកានេះត្រូវបានចង្អុលប្រាប់ពីតុលាការ ព្រមទាំងទីកន្លែងកាលបរិច្ឆេទ និងម៉ោងពេលនៃសវនាការ។

ដីកានេះត្រូវបញ្ជាក់ថា ជនជាប់ចោទអាចពឹងមេធាវីឱ្យអមខ្លួនបាន[29] ។ ការចេញដីកាកោះហៅក៏មានរយៈពេលដែលត្រូវគោរពសម្រាប់ការប្រគល់ទៅជនជាប់ចោទ នូវដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ត្រូវចូលបង្ហាញខ្លួននៅមុខតុលាការតាមការកំណត់ដូចតទៅ៖

- ១៥ (ដប់ប្រាំ) ថ្ងៃ ប្រសិនបើជនជាប់ចោទរស់នៅក្នុងដែនដីនៃតុលាការជាន់ដំបូង
- ២០ (ម្ភៃ) ថ្ងៃ ប្រសិនបើជនជាប់ចោទរស់នៅកន្លែងមួយផ្សេងទៀតនៃដែនដីជាតិ
- ២ (ពីរ) ខែ ប្រសិនបើជនជាប់ចោទរស់នៅក្នុងរដ្ឋមួយជាប់ព្រំដែនព្រះរាជាណាចក្រកម្ពុជា
- ៣ (បី) ខែ ប្រសិនបើជនជាប់ចោទរស់នៅកន្លែងមួយផ្សេងទៀត[30] ។

ក៏ប៉ុន្តែក្នុងករណីជនជាប់ចោទត្រូវឃុំខ្លួន គ្មានរយៈពេលណាមួយត្រូវទាមទារឡើយ រវាងការប្រគល់ដីកាដល់ជនជាប់ចោទ និងថ្ងៃកំណត់ឱ្យចូលខ្លួននៅមុខតុលាការ[31] ។

ការប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះដោយផ្ទាល់ ធ្វើឡើងដោយព្រះរាជអាជ្ញា។ ព្រះរាជអាជ្ញាក៏អាចសុំឱ្យអាជ្ញាសាលា អាជ្ញាធររដ្ឋបាល អាជ្ញាធរពន្ធនាគារ មន្ត្រីនគរបាល ឬកងរាជអាវុធហត្ថ ប្រគល់ដីកាកោះនេះជំនួសខ្លួនបានដែរ ហើយអ្នកទាំងនោះត្រូវគោរពតាមបញ្ជារបស់ព្រះរាជអាជ្ញា។ ក្នុងករណីដែលអាជ្ញាសាលាជាអ្នកយកដីកាកោះហៅទៅបានជួបប្រទះនឹងជនជាប់ចោទនៅក្នុងលំនៅឋាន ឬនៅកន្លែងដទៃទៀត អាជ្ញាសាលាប្រគល់ចុងដីកាកោះហៅឱ្យដល់ជនជាប់ចោទនេះ។ អាជ្ញាសាលាត្រូវចារនៅលើដើមដីកា ហៅថាចុងដីកាត្រូវបានប្រគល់ឱ្យដល់ជនជាប់ចោទដោយផ្ទាល់[32] ។ អាជ្ញាសាលាចុះនិទ្ទេសអំពីកាលបរិច្ឆេទ និងទីកន្លែងដែលប្រគល់ដីកាកោះហៅ។ ជនជាប់ចោទចុះហត្ថលេខានៅលើដើមដីកា។ ដើមដីកាកោះហៅនេះ ត្រូវបង្វិលជូនមកព្រះរាជអាជ្ញាវិញភ្លាម[33] ។ ប្រសិនបើជនជាប់ចោទអវត្តមានពីលំនៅឋាន អាជ្ញាសាលាប្រគល់ចុងដីកាកោះដល់បុគ្គលទាំងឡាយណាជានីតិជន ដែលមានវត្តមានក្នុងលំនៅឋាន[34] ។ បុគ្គលដែលទទួលដីកាកោះត្រូវសន្យាថានឹងប្រគល់ដីកានេះដល់ជនជាប់ចោទក្នុងរយៈពេលខ្លីបំផុត[35] ។ នៅករណីដែលជនជាប់ចោទ មិនព្រមទទួល

---

[29] មាត្រា៤៦ កថាខណ្ឌទី១ វាក្យខណ្ឌទី១ ទី២ ទី៣ ទី៤និងកថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។

[30] មាត្រា៤៦៦ វាក្យខណ្ឌទី១ ទី២ ទី៣ និងវាក្យខណ្ឌទី៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។

[31] មាត្រា៤៦៦ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។

[32] មាត្រា៤៦៩ កថាខណ្ឌទី១ និងកថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។

[33] មាត្រា៤៦៩ កថាខណ្ឌទី៣ កថាខណ្ឌទី៤ និងកថាខណ្ឌទី៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។

[34] មាត្រា៤៧០ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។

[35] មាត្រា៤៧០ កថាខណ្ឌទី៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។

ដីកាកោះមិនមានអ្នកនៅក្នុងលំនៅឋាន ឬមិនមានបុគ្គលណាម្នាក់នៅក្នុងលំនៅឋានដើម្បីទទួលដីកាកោះទេ អាជ្ញាសាលាប្រគល់ចុងដីកាកោះឱ្យដល់មេឃុំ ឬចៅសង្កាត់ ឬចៅសង្កាត់រង ក៏បានដែរ[36] ។ ចំពោះបទឧក្រិដ្ឋ ព្រះរាជអាជ្ញាត្រូវធ្វើបណ្តឹងទៅមន្ទីរស៊ើបសួរ ដើម្បីបើកការស៊ើបសួរជាដាច់ខាត។

**២. ការបង្ហាញខ្លួនភ្លាម**

ព្រះរាជអាជ្ញាអាចបង្គាប់ឱ្យនាំខ្លួនជនជាប់ចោទចូលបង្ហាញខ្លួនភ្លាម នៅមុខតុលាការជាន់ដំបូង។ វិធាននៃនីតិវិធីបែបនេះមិនត្រូវបានអនុវត្តចំពោះបទឧក្រិដ្ឋ និងបទលហុទេ។ លើសពីនេះនីតិវិធីនេះអាចអនុវត្តបានលុះត្រាតែគោរពលក្ខខណ្ឌមួយចំនួន។ ប្រភេទចំណាត់ការសំណុំរឿងនេះអាចធ្វើបានតែក្នុងករណី បទមជ្ឈិមជាក់ស្តែង តែប៉ុណ្ណោះ។ ក្នុងករណីផ្សេងទៀត គេកំណត់ពីបទមជ្ឈិមដែលអនុញ្ញាតឱ្យអនុវត្តនីតិវិធីបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម ដោយផ្អែកទៅលើទោសដាក់ពន្ធនាគារដែលសម្រេចដោយតុលាការ។ ការបង្ហាញខ្លួនភ្លាមនេះប្រសិនបើមានគ្រប់លក្ខខណ្ឌដូចខាងក្រោម៖

- បទល្មើសជាបទល្មើសជាក់ស្តែង
- បទល្មើសត្រូវផ្តន្ទាទោសជាប់ពន្ធនាគារយ៉ាងតិច ១ (មួយ) ឆ្នាំ និងយ៉ាងច្រើន ៥ (ប្រាំ) ឆ្នាំ
- រឿងក្តីមានលក្ខណៈគ្រប់គ្រាន់ល្មមជំនុំជម្រះបាន[37] ។

កាលណាសម្រេចថា ត្រូវប្រើនីតិវិធីបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាមព្រះរាជអាជ្ញាត្រូវ៖

- ពិនិត្យអត្តសញ្ញាណបុគ្គលដែលគេបញ្ជូនមកឱ្យខ្លួន
- ផ្តល់ដំណឹងដល់ជននេះ អំពីរឿងរ៉ាវដែលត្រូវចោទប្រកាន់ និងឈ្មោះបទល្មើស
- ទទួលចម្លើយបុគ្គលនោះ បើសាមីខ្លួនចង់និយាយ
- ធ្វើកំណត់ហេតុស្តីពីការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម។

ដោយប្រាប់ជនជាប់ចោទថា ខ្លួនមានសិទ្ធិសុំពឹងពាក់មេធាវីតាមការជ្រើសរើសរបស់ខ្លួន ឬតាមការចាត់តាំងឡើងដោយអនុលោមតាមច្បាប់ស្តីពីច្បាប់លក្ខន្តិកៈមេធាវី[38] ។

ក៏ប៉ុន្តែក្នុងករណីបទមជ្ឈិមដែលប្រព្រឹត្តដោយអនីតិជន មិនអាចត្រូវចោទប្រកាន់តាមបែបបង្ហាញខ្លួនភ្លាមនោះទេ ( មាត្រា ៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

**៣. ការធ្វើបណ្តឹងទៅចៅក្រមស៊ើបសួរដើម្បីបើកការស៊ើបសួរ**

ការបើកការស៊ើបសួរគឺជាការវាយតម្លៃស្ថានភាពសំណុំរឿងនីតិវិធីអាចធ្វើព្រះរាជអាជ្ញាយល់ពីភាពចាំបាច់ក្នុងការស្រាវជ្រាវបន្ថែមដើម្បីទទួលបានភស្តុតាងដែលអនុញ្ញាតឱ្យអនុវត្តបណ្តឹងអាជ្ញាភាពសមហេតុផល។

---

[36] មាត្រា៤៧១ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។

[37] មាត្រា៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។

[38] មាត្រា៤៨ កថាខណ្ឌទី១ វាក្យខណ្ឌទី១ ទី២ ទី៣ ទី៤ និងកថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,នស/រកម/០៨០៧/០២៤ ឆ្នាំ២០០៧។

ក្នុងទស្សនៈវិស័យនេះព្រះរាជអាជ្ញាមានផ្លូវពីរ គឺបន្តការស៊ើបអង្កេត និងធ្វើបណ្តឹងទៅចៅក្រមស៊ើបសួរ។ ការប្តឹងទៅយុត្តាធិកាស៊ើបសួរ ត្រូវធ្វើឡើងតាមរយៈ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ[39] ។

ក្នុងករណីបទឧក្រិដ្ឋ ព្រះរាជអាជ្ញាត្រូវតែបើកការស៊ើបសួរ។ ការបើកការស៊ើបសួរត្រូវធ្វើបានតាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដែលត្រូវប្តឹងទៅចៅក្រមស៊ើបសួរ។ ការស៊ើបសួរអាចបើកប្រឆាំងលើបុគ្គលម្នាក់ ឬច្រើននាក់ ដោយមានចង្អុលប្រាប់ឈ្មោះ ឬប្រឆាំងទៅលើអញ្ញាតជន[40] ។

គួរកត់សម្គាល់បានដែរថា ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ គឺជាលិខិតដែលបើកឱ្យមានបណ្តឹងអាជ្ញា ដែលព្រះរាជអាជ្ញាប្តឹងទៅចៅក្រមស៊ើបសួរលើរឿងរ៉ាវមួយជាកំណត់ដែលអាចផ្តន្ទាទោសដាក់ពន្ធនាគារបាន។

## ផ្នែកទី២ ៖ ការបើកការស៊ើបសួរដែលធ្វើឡើងដោយចៅក្រមស៊ើបសួរ

ការស៊ើបសួរ គឺជាដំណាក់កាលដែលចៅក្រមស៊ើបសួរជាយថាហេតុរបស់មន្ទីរស៊ើបសួរ និងសភាស៊ើបសួរ ដែលស្ថិតក្នុងការប្រមូលផ្តុំធាតុចាំបាច់សម្រាប់ការកាត់សេចក្តី និងសម្រេចចំពោះការចោទប្រកាន់។ យោងតាម មាត្រា ១២៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌចែងថា ចៅក្រមស៊ើបសួរបំពេញកិច្ចស៊ើបសួរទាំងអស់ដែលខ្លួនយល់ឃើញថាមានប្រយោជន៍សម្រាប់បង្ហាញឱ្យឃើញការពិតដោយអនុលោមតាមច្បាប់។ ចៅក្រមស៊ើបសួរមានករណីយកិច្ចស៊ើបសួរទាំងដាក់បន្ទុក និងដោះបន្ទុក។ ការស៊ើបសួរពុំមានលក្ខណៈបង្ខំ ដូចក្នុងករណីបទមជ្ឈិម និងបទលហុទេ។ ក៏ប៉ុន្តែវាត្រូវតែធ្វើជាដាច់ខាត ចំពោះបទឧក្រិដ្ឋ។ ការស៊ើបសួរត្រូវធ្វើឡើយដោយសម្ងាត់ ហើយកាលណាមានការបំពានលើការសម្ងាត់នៃការស៊ើបសួរ គឺជាបទល្មើសដែលត្រូវផ្តន្ទាទោសបទមជ្ឈិម ទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ថ្ងៃ ស្មើ ឬក្រោម ៥ (ប្រាំ) ឆ្នាំ មានចែងក្នុងក្រមព្រហ្មទណ្ឌជាធរមាន។ ការបើកការស៊ើបសួរត្រូវធ្វើឡើងតាមពាក្យបណ្តឹងរបស់ព្រះរាជអាជ្ញា និងការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។

### កថាខណ្ឌទី១ ៖ លក្ខណៈទម្រង់ និងអានុភាពនៃបណ្តឹងដើម្បីបើកការស៊ើបសួរ

#### ១. ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ[41]

ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរគឺជាដីកាដែលព្រះរាជអាជ្ញាប្តឹងទៅចៅក្រមស៊ើបសួរ ឱ្យធ្វើការស៊ើបសួរលើអង្គហេតុដែលមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដីកាបញ្ជូនរឿងឱ្យស៊ើបសួរត្រូវមាននិទ្ទេសដូចកំណត់ហេតុក្នុងមាត្រា ៤៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌដូចតទៅ៖

- សេចក្តីសង្ខេបនៃអង្គហេតុ
- ការកំណត់ឈ្មោះបទល្មើស
- ការបង្ហាញអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស

[39] ឧបសម្ព័ន្ធ

[40] មាត្រា ៤៤ កថាខណ្ឌទី១ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។

[41] ឧបសម្ព័ន្ធ

- និងឈ្មោះបុគ្គលដែលត្រូវធ្វើការស៊ើបសួរ ប្រសិនបើអាចកំណត់បាន។

ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរត្រូវចុះកាលបរិច្ឆេទ និងចុះហត្ថលេខា។ ទម្រង់ដីកានេះមានលក្ខណៈដាច់ខាតត្រូវតែគោរពបើពុំដូច្នេះទេ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ នេះត្រូវទុកជាមោឃៈ[42] ។

ព្រះរាជអាជ្ញា មានកាតព្វកិច្ចចេញដីកានេះបញ្ជូនទៅចៅក្រមស៊ើបសួរធ្វើការស៊ើបសួរក្នុងករណីបទល្មើសឧក្រិដ្ឋជាក់ស្តែង ឬមិនជាក់ស្តែង។ ចំពោះបទល្មើសមជ្ឈិមមួយចំនួន ប្រសិនបើព្រះរាជអាជ្ញាយល់ឃើញថាត្រូវបើកការស៊ើបសួរ បទល្មើសនោះត្រូវតែធ្វើការស៊ើបសួរ។

ចៅក្រមស៊ើបសួរ មិនអាចបំពេញកិច្ចស៊ើបសួរណាមួយបាន ដោយគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជាអាជ្ញាបានទេ[43] ។ លិខិតដែលត្រូវភ្ជាប់មកជាមួយដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ គឺជាលិខិតដែលចេញពេលស៊ើបអង្កេតជាក់ស្តែង ឬពេលស៊ើបអង្កេតបឋម ។

**២. ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី**

កាលណាការស៊ើបសួរបានបើក បុគ្គលគ្រប់រូបដែលបានប្រកាសខ្លួនថាជាជនរងគ្រោះអាចតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅចំពោះមុខចៅក្រមស៊ើបសួរបានគ្រប់ពេលវេលា[44] ។

ចៅក្រមស៊ើបសួរទទួលបានពាក្យបណ្តឹង តាមរយៈបណ្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលធ្វើឡើងដោយជនរងគ្រោះនៃបទឧក្រិដ្ឋ ឬបទមជ្ឈិម អាចដាក់ពាក្យបណ្តឹងជូនចៅក្រមស៊ើបសួរមានសមត្ថកិច្ចជនរងគ្រោះខ្លួនឯងផ្ទាល់ ឬដោយមេធាវីក្នុងនាមជនរងគ្រោះ[45] ។

ក្រោយពីបានឃើញពាក្យបណ្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរួចមក។ ចៅក្រមស៊ើបសួរបញ្ជូនបណ្តឹងនោះទៅព្រះរាជអាជ្ញា។ ក្រោយពីបានឃើញពាក្យបណ្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីព្រះរាជអាជ្ញាប្តឹងទៅចៅក្រមស៊ើបសួរវិញតាម ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរអាចធ្វើប្រឆាំងនឹងអញ្ញតជន ទោះបីជាបណ្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចោទទៅលើបុគ្គលម្នាក់ ឬច្រើននាក់ក៏ដោយ។ ព្រះរាជអាជ្ញាអាចសុំដល់ចៅក្រមស៊ើបសួរធ្វើការកុំឱ្យស៊ើបសួរប្រសិនបើបណ្តឹងអាជ្ញារលត់ ឬប្រសិនបើអំពើនោះមិនមែនជា បទល្មើសព្រហ្មទណ្ឌទេ[46] ។

ក្នុងករណីអំពើដែលបរិហារដោយជនរងគ្រោះមិនអាចត្រូវស្តីបន្ទោសទេ។ ប្រសិនបើចៅក្រមស៊ើបសួរសម្រេចមិនស៊ើបសួរ ចៅក្រមរូបនេះត្រូវចេញដីកាសម្រេចដោយមានសម្អាងហេតុ ដែលត្រូវជូនដំណឹងជាបន្ទាន់

[42] មាត្រា ៨៤ កថាខណ្ឌទី៣ កថាខណ្ឌទី៤ និងកថាខណ្ឌទី៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។
[43] មាត្រា ១២៤ កថាខណ្ឌទី៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។
[44] មាត្រា ១៣៧ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។
[45] មាត្រា ១៣៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។
[46] មាត្រា ១៣៩ កថាខណ្ឌទី១ កថាខណ្ឌទី២ និងកថាខណ្ឌទី៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។

ដល់ដើមបណ្ដឹងរដ្ឋប្បវេណី។ ផ្ទុយទៅវិញនៅក្នុងករណីដែលចៅក្រមស៊ើបសួរនៅតែសម្រេចស៊ើបសួរចៅក្រមរូបនោះត្រូវចេញដីកាដោយមានសម្អាងហេតុ ហើយជូនដំណឹងជាបន្ទាន់ដល់ព្រះរាជអាជ្ញា[47] ។

ដើម្បីការពារកុំឱ្យមានពាក្យបណ្ដឹងដោយបំពាន ចៅក្រមស៊ើបសួរកំណត់ឱ្យដើមបណ្ដឹងរដ្ឋប្បវេណី បង់ប្រាក់កក់ដែលគាត់កំណត់ដោយផ្អែកទៅលើធនធាន និងការលំបាកនៃរឿងក្ដីដែលអាចស្មានដឹងជាមុន។ ចៅក្រមស៊ើបសួរក៏កំណត់ពីរយៈពេលដែលត្រូវបង់ប្រាក់ផងដែរ។ ប្រសិនបើដើមបណ្ដឹងរដ្ឋប្បវេណីពុំមានលទ្ធភាពអាចបង់ប្រាក់តម្កល់ទុកបានទេ ចៅក្រមស៊ើបសួរអាចលើកលែងមិនឱ្យបង់ប្រាក់តម្កល់ទុកនេះបាន។ ដីកានេះត្រូវជូនដំណឹងជាបន្ទាន់ដល់ដើមបណ្ដឹងរដ្ឋប្បវេណីវិញផងដែរ[48] ។

នៅពេលដែលចៅក្រមស៊ើបសួរទទួលពាក្យបណ្ដឹង ដោយពុំមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី គាត់ត្រូវបញ្ជូនពាក្យបណ្ដឹងនោះទៅព្រះរាជអាជ្ញា។ ពាក្យបណ្ដឹងនោះ ត្រូវដោះស្រាយដូចជាបណ្ដឹងដទៃទៀតដោយមានការពិនិត្យ និងវាយតម្លៃដោយសេរីរបស់ព្រះរាជអាជ្ញាទៅលើចំណាត់ការបន្តទៀត។

គ្រប់ជនរងគ្រោះនៃបទល្មើសដែលបានប្ដឹងទៅចៅក្រមស៊ើបសួរ អាចតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីបានគ្រប់ពេលវេលានៃនីតិវិធីការតាំងខ្លួននេះធ្វើឡើងដោយគ្មានទម្រង់អ្វីទេ គឺវាអាចធ្វើឡើងដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ។

### ៣ . អានុភាពនៃបណ្ដឹង

កាលណាចៅក្រមស៊ើបសួរទទួលបណ្ដឹងអំពីអង្គហេតុដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរ ត្រូវស៊ើបសួរតែអំពីអង្គហេតុនោះតែប៉ុណ្ណោះ។ ប្រសិនបើមានលេចនូវអង្គហេតុថ្មីដែលអាចជាបទល្មើសព្រហ្មទណ្ឌនៅក្នុងពេលស៊ើបសួរ ចៅក្រមស៊ើបសួរត្រូវជូនព័ត៌មានអំពីអង្គហេតុថ្មីនេះ ទៅព្រះរាជអាជ្ញា។ ព្រះរាជអាជ្ញាអាចប្ដឹងសុំឱ្យចៅក្រមស៊ើបសួរធ្វើការស៊ើបសួរអំពីអង្គហេតុថ្មីនេះ តាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។ បើគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទេ ចៅក្រមស៊ើបសួរគ្មានអំណាច ស៊ើបសួរអំពីអង្គហេតុថ្មីនោះឡើយ។ ក្នុងករណីខ្លះចៅក្រមស៊ើបសួរមិនចាំបាច់សុំដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទេ ប្រសិនបើអង្គហេតុថ្មីនោះជាស្ថានទម្ងន់ទោសទៅលើអង្គហេតុដែលចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដំបូង[49] ។

#### ៣.១. ភាពមិនអាចដកបណ្ដឹងបាន

កាលណាចៅក្រមស៊ើបសួរទទួលពាក្យបណ្ដឹង ហើយចៅក្រមស៊ើបសួរមិនអាចដកវិញបានទេ ពីអំពើដែលចែងក្នុងសេចក្ដីសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ ហេតុដូច្នេះ ព្រះរាជអាជ្ញា បាត់បង់នូវសិទ្ធិសម្រេចចំពោះ

[47] មាត្រា ១៣៩ កថាខណ្ឌទី៤ និងកថាខណ្ឌទី៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។

[48] មាត្រា ១៤០ កថាខណ្ឌទី១ នឹងកថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។

[49] មាត្រា ១២៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។

អំពើខាងលើនេះ។ ចៅក្រមស៊ើបសួរ ពុំអាចតម្កល់រឿងទុកឥតចាត់ការទៀតបានទេ។ ម៉្យាងទៀតចៅក្រមស៊ើបសួរក៏លែងមានសិទ្ធិបញ្ជានគរបាល ឬកងរាជអាវុធហត្ថ ឱ្យធ្វើការស៊ើបអង្កេតទៅលើអំពើមួយនេះទៀតដែរ។ ទាញចេញពីគោលការណ៍នេះ ព្រះរាជអាជ្ញាមិនអាចព្យាយាមធ្វើឱ្យប៉ះពាល់ដល់វិសាលភាពនៃបណ្តឹង ក្នុងពេលដែលកំពុងស៊ើបសួរបានទេ។ ដូច្នេះសេចក្តីសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមដែលធ្វើឡើងក្នុងគោលបំណងនេះមិនអាចត្រូវបានអនុវត្តបានទេ។ ហើយទាក់ទងទៅនឹងបុគ្គល ព្រះរាជអាជ្ញា ជនរងគ្រោះ ដែលបានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមិនអាចចង្អុលបង្ហាញបុគ្គលណាមួយដោយផ្ទាល់នៅចំពោះមុខសាលាវិនិច្ឆ័យ ក្នុងអំឡុងពេលស៊ើបអង្កេត ឬបន្ទាប់ពីពេលដែលចៅក្រមស៊ើបសួរបានចេញដីកាលើកលែងចោទប្រកាន់នោះបានទេ។

**៣.២. ភាតព្វកិច្ចស៊ើបសួរ**

ចៅក្រមស៊ើបសួរ ដែលទទួលពាក្យបណ្តឹងដោយត្រឹមត្រូវ គឺមានករណីយកិច្ចត្រូវបើកការស៊ើបសួរ។ ដូច្នេះចៅក្រមស៊ើបសួរមិនអាចបដិសេធការស៊ើបសួររឿងអ្វីមួយដោយសំអាងថា ការស៊ើបសួរពុំមានប្រយោជន៍ដោយរឿងក្តីនេះស៊ើបសួររួចហើយ។ ចៅក្រមស៊ើបសួរពុំអាចបដិសេធមិនស៊ើបសួរដោយយកលេសថា ការស៊ើបសួរពុំអាចទទួលលទ្ធផល ព្រោះអំពើនោះមិនមែនជាបទល្មើសដែលចែងក្នុងសេចក្តីសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ទោះបីវាជាអំពើល្មើសក៏ដោយ។

កាតព្វកិច្ចនេះមានកំណត់ចៅក្រមស៊ើបសួរមានកាតព្វកិច្ចផ្ទៀងផ្ទាត់សមត្ថកិច្ចសម្ភារ និងសមត្ថកិច្ចដែនដី។ ចៅក្រមស៊ើបសួរមិនអាចប្រកាសថាខ្លួនពុំមានសមត្ថកិច្ចខាងដែនដី ដរាបណាគាត់មិនទាន់បានធ្វើការស្រាវជ្រាវចាំបាច់នានា ដើម្បីផ្ទៀងផ្ទាត់សមត្ថកិច្ចរបស់ខ្លួនជាពិសេសប្រសិនបើគាត់ទទួលបណ្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលសរសេរថា ម្នាក់ក្នុងចំណោមជនសង្ស័យដែលត្រូវបរិហាររស់នៅក្នុងដែនសមត្ថកិច្ចរបស់គាត់។ ប្រសិនបើចៅក្រមស៊ើបសួរយល់ឃើញថា ខ្លួនពុំមានសមត្ថកិច្ចស៊ើបសួរទេ ចៅក្រមស៊ើបសួរនោះត្រូវចេញដីកាអសមត្ថកិច្ច។ ក្នុងករណីចៅក្រមស៊ើបសួរទទួលពាក្យបណ្តឹងពីដើមបណ្តឹងរដ្ឋប្បវេណី ចៅក្រមស៊ើបសួរត្រូវតែសម្រេចដោយយោងតាម សេចក្តីសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់អយ្យការ។

ក្នុងករណីផ្សេងទៀត ថ្វីបើជាសមត្ថកិច្ចតាមសាច់រឿង និងតាមដែនដីរបស់ចៅក្រមស៊ើបសួរក៏ពិតមែន ប៉ុន្តែចៅក្រមស៊ើបសួរអាចបដិសេធមិនស៊ើបសួរបាន។ ចៅក្រមស៊ើបសួរត្រូវបដិសេធមិនស៊ើបសួរ ដោយចេញដីកាដោយមានសម្អាងហេតុក្នុងខណៈដែលការចោទប្រកាន់ហាក់មិនអាចធ្វើទៅបាន។

ឧទាហរណ៍ៈ ករណីរឿងមួយ មិនអនុញ្ញាតឱ្យមានការស៊ើបសួរទេ ប្រសិនបើអំពើមិនអាចចាត់ទុកជាបទល្មើសអាជ្ញាយុកាលនៃបណ្តឹងអាជ្ញាផុតរលត់ ឬរឿងរ៉ាវត្រូវបានវិនិច្ឆ័យរួចហើយ។

យោងទៅលើមូលហេតុទាក់ទងនឹងបណ្តឹងអាជ្ញាខ្លួនឯងផ្ទាល់ ព្រះរាជអាជ្ញា អាចប្តឹងទៅចៅក្រមស៊ើបសួរនូវសេចក្តីសន្និដ្ឋានមិនស៊ើបសួរ ប្រសិនបើអំពើមិនអនុញ្ញាតឱ្យមានការចោទប្រកាន់ស្របច្បាប់ណាមួយ ឬ

ដោយសន្មត់ថា អំពើនេះត្រូវបានបង្ហាញប៉ុន្តែវាមិនមែនជាបទល្មើសព្រហ្មទណ្ឌ។ ក្នុងករណីដែលចៅក្រមស៊ើបសួរសម្រេចផ្សេងពីនេះ គាត់ត្រូវចេញដីកាដោយមានសំអាងហេតុ។

### ៣.៣. វិសាលភាពនៃបណ្តឹង

#### ៣.៣.១. ការស៊ើបសួរនៃព្រំដែនបណ្តឹងចំពោះអង្គហេតុ

អង្គហេតុ គឺជាចំណុចចាំបាច់បំផុតដែលត្រូវតែមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ព្រោះកាលណាមិនបំពេញគ្រប់លក្ខខណ្ឌនៃទម្រង់ការរបស់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទេ ធ្វើឱ្យដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនោះត្រូវទុកជាមោឃៈ។ នៅក្នុងអង្គហេតុនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ត្រូវកំណត់ឱ្យច្បាស់លាស់ពីទីតាំង និងពេលវេលានៃការប្រព្រឹត្តបទល្មើសនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ ដើម្បីអាចកំណត់ពីព្រំដែននៃសិទ្ធិក្នុងការស៊ើបសួររបស់ចៅក្រមស៊ើបសួរទៅលើអង្គហេតុ ដើម្បីបញ្ចៀសការស៊ើបសួរហួសដែនកំណត់ដែលអាចនាំឱ្យមានការយឺតយ៉ាវក្នុងនីតិវិធីផងដែរ។ ចៅក្រមស៊ើបសួរទទួលបណ្តឹងអំពីអង្គហេតុដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា។ ចៅក្រមស៊ើបសួរ ត្រូវស៊ើបសួរតែទៅលើអំពីនៃអង្គហេតុដែលមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនោះតែប៉ុណ្ណោះ។ ក៏ប៉ុន្តែការស៊ើបសួរខ្លះដែលចៅក្រមស៊ើបសួរមិនចាំបាច់សុំដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទេប្រសិនបើអង្គហេតុថ្មីនោះ ជាស្ថានទម្ងន់ទោសទៅលើអង្គហេតុដែលចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដំបូង[50] ។ បើសិនចំពោះការស្នើសុំស៊ើបសួរបន្ថែម ចំពោះអង្គហេតុថ្មីត្រូវស្នើសុំទៅអយ្យការ ចៅក្រមស៊ើបសួរមិនអាចធ្វើការស៊ើបសួរដោយគ្មានការឯកភាពជាមុនពីព្រះរាជអាជ្ញាបានទេ។ ក្នុងករណីដែលមានអង្គហេតុថ្មីមិនមានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទេ ចៅក្រមស៊ើបសួរអាចស្នើសុំធ្វើការស៊ើបសួរបន្ថែម ដើម្បីឱ្យមានភាពកាន់តែច្បាស់លាស់បន្ថែមទៀត។ យន្តការនេះដែលតម្រូវឱ្យព្រះរាជអាជ្ញា ធ្វើការចោទប្រកាន់ថ្មីមួយនៅក្នុងករណីដែលលេចចេញនូវអង្គហេតុថ្មីដែលអាចជាបទល្មើសព្រហ្មទណ្ឌនៅក្នុងកិច្ចស៊ើបសួរដោយចៅក្រមស៊ើបសួរ ត្រូវជូនព័ត៌មានអំពីអង្គហេតុថ្មីទៅព្រះរាជអាជ្ញា។ ប្រសិនបើព្រះរាអាជ្ញាមិនបានចេញដីកាបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទេ ចៅក្រមស៊ើបសួរគ្មានអំណាចស៊ើបសួរ អំពីអង្គហេតុថ្មីនោះឡើយ។

#### ៣.៣.២. ការស៊ើបសួរនៃព្រំដែនបណ្តឹងចំពោះឯកត្តបុគ្គល

ការស៊ើបសួរដែលមានកំណត់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញាមានវិសាលភាពអាចប្រឆាំងទៅលើបុគ្គលម្នាក់ ឬច្រើនដែលមានចង្អុលប្រាប់ឈ្មោះ ប្រឆាំងទៅលើអញ្ញាតជន[51] ។ ព្រះរាជអាជ្ញាជាម្ចាស់នៃបណ្តឹងអាជ្ញា ជាអ្នកកំណត់បទល្មើស និងធ្វើការចោទប្រកាន់ចំពោះអង្គហេតុដែលកំណត់ឱ្យចៅក្រម

[50] មាត្រា ១២៥ កថាខណ្ឌទី៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។

[51] មាត្រា១២៥ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។

ស៊ើបសួរកម្រិតចំពោះអង្គហេតុដែលស៊ើបសួរ។ ការចោទប្រកាន់នេះ មិនត្រូវអនុវត្តចំពោះការស៊ើបសួរទៅលើបុគ្គល និងដំណើរការស៊ើបសួររបស់ចៅក្រមស៊ើបសួរទេ។

ការស៊ើបសួរទៅលើគ្រប់បុគ្គលពាក់ព័ន្ធនឹងអង្គហេតុដែលត្រូវបានទទួលស្គាល់នៅក្នុងដំណាក់កាលស៊ើបសួរដែលខុសគ្នាពីដំណាក់កាលចោទប្រកាន់របស់ព្រះរាជអាជ្ញា ចំពោះបុគ្គលដែលបានចោទប្រកាន់ច្បាស់ៗក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរត្រូវកម្រិតសិទ្ធិនៃការស៊ើបសួរទៅលើបុគ្គលដែលបានកំណត់នោះ។ ប៉ុន្តែក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បានបង្កើតនូវសិទ្ធិស្វែងរកមូលភាពនៃបទល្មើស ដោយមិនចងកាតព្វកិច្ចចៅក្រមស៊ើបសួរទៅនឹងប្រព័ន្ធចោទប្រកាន់ចំពោះបុគ្គល ដែលជាអំណាចផ្តាច់មុខរបស់ព្រះរាជអាជ្ញាឡើយ និងដើម្បីធានាឱ្យបាននូវសុក្រឹតភាព យុត្តិធម៌ ជូនជនរងគ្រោះ ក្រមនីតិវិធីព្រហ្មទណ្ឌបានផ្តល់សិទ្ធិយ៉ាងពេញលេញក្នុងការស៊ើបសួរ ទៅលើគ្រប់បុគ្គលទាំងអស់ ក្រៅពីជនដែលត្រូវបានចង្អុលបង្ហាញដោយព្រះរាជអាជ្ញា ក្នុងន័យនេះករណីចៅក្រមស៊ើបសួររកឃើញ បុគ្គលផ្សេងទៀតពាក់ព័ន្ធនឹងអង្គហេតុដែលត្រូវស៊ើបសួរ ចៅក្រមស៊ើបសួរមានសិទ្ធិពន្លាតការស៊ើបសួរទៅលើបុគ្គលនោះដោយមិនទាមទារឱ្យមានការចោទប្រកាន់ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមពីព្រះរាជអាជ្ញាឡើយ។

### **កថាខណ្ឌទី២៖ អំណាចនៃវិធីសាស្ត្រស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ**

#### **១. ការជូនដំណឹងអំពីការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ**

នៅពេលចូលបង្ហាញខ្លួនលើកដំបូង ចៅក្រមស៊ើបសួរពិនិត្យអត្តសញ្ញាណជនត្រូវចោទប្រាប់ជននេះឱ្យបានដឹងរឿងរ៉ាវដែលចោទប្រកាន់ និងប្រាប់អំពីឈ្មោះបទល្មើសដែលកំណត់ដោយច្បាប់។ ចៅក្រមស៊ើបសួរប្រាប់ជនត្រូវចោទថា ខ្លួនអាចឆ្លើយ ឬមិនឆ្លើយបានដោយសេរី។ និទ្ទេសស្តីពីការប្រាប់នេះត្រូវចុះនៅក្នុងកំណត់ហេតុនៅពេលចូលបង្ហាញខ្លួនលើកដំបូង។ ប្រសិនបើជនត្រូវចោទចង់ឆ្លើយនោះចៅក្រមស៊ើបសួរត្រូវទទួលចម្លើយនោះភ្លាម។ ចៅក្រមស៊ើបសួរប្រាប់ជនត្រូវចោទ ឱ្យបានដឹងអំពីសិទ្ធិរបស់ខ្លួនក្នុងការជ្រើសរើសមេធាវី ឬក្នុងការសុំឱ្យចាត់តាំងមេធាវីឱ្យខ្លួន ដោយអនុវត្តតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។ ចំពោះជនត្រូវចោទជាអនីតិជនត្រូវតែមានមេធាវីអមជានិច្ច។ បើគ្មានការជ្រើសរើសដោយជនត្រូវចោទទេមេធាវីត្រូវបានចាត់តាំងនៅក្នុងលក្ខខណ្ឌដែលចែងដោយច្បាប់ស្តីអំពីលក្ខន្តិកៈមេធាវី។ ក្រោយពីការចូលបង្ហាញខ្លួនលើកទីមួយ ជនត្រូវចោទដែលនៅក្រៅឃុំត្រូវប្រកាសប្រាប់ដល់ ចៅក្រមស៊ើបសួរអំពីអាសយដ្ឋានរបស់ខ្លួន។ ជនត្រូវចោទត្រូវប្រាប់ព័ត៌មាន ឬជូនដំណឹងដល់ចៅក្រមស៊ើបសួរដូចជា ៖

- ខ្លួនត្រូវតែជូនព័ត៌មានដល់ចៅក្រមស៊ើបសួរនៅពេលណាដែលខ្លួនផ្លាស់ប្តូរអាសយដ្ឋាន
- គ្រប់ការឱ្យដំណឹងដែលបានធ្វើឡើងតាមអាសយដ្ឋានចុងក្រោយដែលប្រកាសឡើង ដោយជនត្រូវចោទនោះ ត្រូវចាត់ទុកថាបានធ្វើឡើងដល់សាមីខ្លួនផ្ទាល់។

- ការឱ្យដំណឹងព្រមទាំងការប្រកាសស្ដីអំពីការផ្លាស់ប្ដូរអាសយដ្ឋាននោះត្រូវចុះនៅក្នុងកំណត់ហេតុនៅពេលចូលបង្ហាញខ្លួនលើកដំបូង[52] ។

ក្នុងករណីចាំបាច់ចៅក្រមស៊ើបសួរត្រូវហៅរកអ្នកបកប្រែ។ ហើយអ្នកបកប្រែត្រូវស្បថស្របតាមសាសនា ឬជំនឿរបស់ខ្លួនថានឹងជួយដល់តុលាការ និងបកប្រែឱ្យបានត្រឹមត្រូវតាមចម្លើយទាំងឡាយ។ ក្នុងករណីណាក៏ដោយអ្នកបកប្រែមិនអាចត្រូវជ្រើសរើសក្នុងចំណោម ចៅក្រម ក្រឡាបញ្ជី នគរបាល កងរាជអាវុធហត្ថ ភាគី ឬសាក្សីទេ។

**២.ការសួរចម្លើយជនត្រូវចោទ**[53]

កាលណាជនត្រូវចោទមានមេធាវីអម ចៅក្រមស៊ើបសួរត្រូវកោះហៅជនត្រូវចោទ និងអញ្ជើញមេធាវីយ៉ាងតិចបំផុត៥ (ប្រាំ) ថ្ងៃ មុនការសួរចម្លើយ។ ក្នុងចិរវេលានេះមេធាវីអាចពិនិត្យមើលសំណុំរឿងនៃនីតិវិធី។ ជនត្រូវចោទអាចត្រូវសួរចម្លើយបានតែនៅចំពោះមុខមេធាវីខ្លួនតែប៉ុណ្ណោះ។ ក្នុងករណីមេធាវីដែលត្រូវបានអញ្ជើញតាមលិខិតជាលាយលក្ខណ៍អក្សរត្រឹមត្រូវ ប៉ុន្តែមេធាវីមិនបានចូលបង្ហាញខ្លួននៅថ្ងៃ និងម៉ោងកំណត់ទេ ចៅក្រមស៊ើបសួរអាចសួរចម្លើយជនត្រូវចោទដោយគ្មានវត្តមានមេធាវីបាន។ និទ្ទេសស្ដីពីអវត្តមាននេះត្រូវចុះនៅក្នុងកំណត់ហេតុសួរចម្លើយជនត្រូវចោទ។

ក្នុងករណីពិសេស ចៅក្រមស៊ើបសួរ អាចសួរចម្លើយជនត្រូវចោទ ដោយពុំចាំបាច់កោះអញ្ជើញមេធាវី ប្រសិនបើជនត្រូវចោទបោះបង់ចោលយ៉ាងជាក់លាក់នូវអវត្តមានរបស់មេធាវីខ្លួន។ ការបោះបង់ចោលនេះត្រូវចុះនៅក្នុងកំណត់ហេតុផ្សេងពីកំណត់ហេតុសួរចម្លើយ និងត្រូវចុះហត្ថលេខា ឬផ្ដិតស្នាមម្រាមដៃដោយជនត្រូវចោទ។ ក្នុងករណីបន្ទាន់ខ្លះចៅក្រមស៊ើបសួរក៏អាចធ្វើការសួរចម្លើយជនត្រូវចោទដោយពុំចាំបាច់កោះអញ្ជើញមេធាវីក៏បានដែរ។ ភាពបន្ទាន់នេះ ជាកត្តាដែលបណ្ដាលមកពីមរណភាពនៃជនរងគ្រោះ ឬបណ្ដាលមកពីការភ័យខ្លាចបាត់បង់តម្រុយនៃភស្ដុតាង។ ប្រភេទនៃភាពបន្ទាន់នេះត្រូវតែចុះនិទ្ទេសនៅក្នុងកំណត់ហេតុ។ ចៅក្រមស៊ើបសួរអាចហៅរកអ្នកបកប្រែបាន[54] ។

នៅពេលសួរចម្លើយជនត្រូវចោទ ព្រះរាជអាជ្ញា និងមេធាវីក៏អាចលើកសំណួរបានដែរ ដោយមានការអនុញ្ញាតពីចៅក្រមស៊ើបសួរ។ នៅក្នុងករណីមិនអនុញ្ញាត ករណីនេះត្រូវចុះនិទ្ទេសនៅក្នុងកំណត់ហេតុ[55] ។

កំណត់ហេតុដែលត្រូវធ្វើនៅពេលសួរជនត្រូវចោទ ទំព័រនីមួយៗនៃកំណត់ហេតុសួរចម្លើយជនត្រូវចោទត្រូវតែចុះហត្ថលេខា ឬស្នាមម្រាមដៃរបស់ជនត្រូវចោទ និងជាយថាហេតុដោយអ្នកបកប្រែ[56] ។

[52] មាត្រា ១៤៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។
[53] ឧបសម្ព័ន្ធ
[54] មាត្រា ១៤៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។
[55] មាត្រា ១៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។
[56] មាត្រា ២៤២ កថាខណ្ឌទី៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។

កាលណាចិរវេលា ៤ (បួន) ខែ បានកន្លងផុតទៅ ចាប់ពីពេលសួរចម្លើយនៅពេលបង្ហាញខ្លួនលើកដំបូង ជនត្រូវចោទមិនត្រូវបានសួរចម្លើយ ឬសួរតទល់ទេ ចៅក្រមស៊ើបសួរត្រូវតែទទួលចម្លើយ ប្រសិនបើជនត្រូវចោទបានស្នើសុំ។ បើចៅក្រមស៊ើបសួរមិនព្រមកោះហៅជនត្រូវចោទក្នុងចិរវេលា ១ (មួយ) ខែ បន្ទាប់ពីការសុំទេនោះ ជនត្រូវចោទអាចប្ដឹងផ្ទាល់ទៅសភាស៊ើបសួរដែលទទួលចម្លើយនេះដោយខ្លួនឯង។ បន្ទាប់មកកំណត់ហេតុត្រូវបញ្ជូនទៅចៅក្រមស៊ើបសួរ[57] ។

មេធាវីរបស់ជនត្រូវចោទដែលជាប់ឃុំ អាចប្រាស្រ័យទាក់ទងដោយសេរីជាមួយកូនក្ដីរបស់ខ្លួននៅក្នុងពន្ធនាគារ ឬនៅក្នុងមណ្ឌលឃុំខ្លួន។ ការសន្ទនារវាងមេធាវី និងជនត្រូវចោទមិនអាចត្រូវបានគេស្ដាប់ ឬថតបានទេ។ មេធាវីអាចអានលិខិតនៃសំណុំរឿងឱ្យកូនក្ដីខ្លួនស្ដាប់ ប៉ុន្តែមេធាវីមិនអាចចម្លងលិខិតថតចម្លងពីលិខិតនៃសំណុំរឿងដល់កូនក្ដីរបស់ខ្លួនបានឡើយ[58] ។

**៣. ការស្ដាប់ចម្លើយ**

ការស្ដាប់ចម្លើយអាចឱ្យនិយមន័យបានថា ជាកិច្ចដែលចៅក្រមស៊ើបសួរស្ដាប់ដើមបណ្ដឹងរដ្ឋប្បវេណី និងសាក្សី៖

**៣.១. ការស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី**[59]

ការស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី អាចត្រូវបានអមដោយមេធាវី។ ក្នុងករណីនេះចៅក្រមស៊ើបសួរត្រូវកោះហៅមេធាវីរបស់ដើមបណ្ដឹងរដ្ឋប្បវេណីយ៉ាងតិចបំផុត ៥ (ប្រាំ) ថ្ងៃ មុនការស្ដាប់ចម្លើយ។ នៅក្នុងចិរវេលានេះ មេធាវីអាចពិនិត្យសំណុំរឿងនៃនីតិវិធីបាន។ ដើមបណ្ដឹងរដ្ឋប្បវេណីអាចត្រូវបានគេស្ដាប់ចម្លើយតែនៅចំពោះមេធាវីរបស់ខ្លួនប៉ុណ្ណោះ។ ប៉ុន្តែប្រសិនបើមេធាវីដែលត្រូវបានកោះហៅយ៉ាងត្រឹមត្រូវ ហើយមិនចូលបង្ហាញខ្លួននៅថ្ងៃ និងម៉ោងតាមកំណត់ទេ ចៅក្រមស៊ើបសួរ អាចស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណីដោយគ្មានវត្តមានមេធាវីបាន។ និទ្ទេសស្ដីពីអវត្តមាន ត្រូវចុះនៅក្នុងកំណត់ហេតុស្ដាប់ចម្លើយ។ ក្នុងករណីពិសេស ចៅក្រមស៊ើបសួរអាចស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណីបាន ដោយមិនចាំបាច់កោះហៅមេធាវី ប្រសិនបើដើមបណ្ដឹងរដ្ឋប្បវេណីបោះបង់ចោលយ៉ាងជាក់លាក់នូវអវត្តមានមេធាវីរបស់ខ្លួន។ ការបោះបង់ចោលនេះត្រូវចុះនិទ្ទេសនៅក្នុងកំណត់ហេតុមួយដោយឡែក ពីកំណត់ហេតុស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី និងត្រូវចុះហត្ថលេខា ឬផ្ដិតស្នាមម្រាមដៃដោយដើមបណ្ដឹងរដ្ឋប្បវេណី។ ក្នុងករណីបន្ទាន់ ចៅក្រមស៊ើបសួរក៏អាចស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី ដោយមិនចាំបាច់កោះហៅមេធាវីក៏បានដែរ។ ភាពបន្ទាន់នេះ ត្រូវបណ្ដាលមកពីគ្រោះថ្នាក់ដល់ស្លាប់ ឬបណ្ដាលមកពីភ័យខ្លាចបាត់បង់តម្រុយភស្ដុតាង។ ប្រភេទនៃភាពបន្ទាន់នេះត្រូវតែចុះនិទ្ទេសនៅក្នុងកំណត់ហេតុ[60] ។

[57] មាត្រា ១៤៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។
[58] មាត្រា ១៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។
[59] ឧបសម្ព័ន្ធ
[60] មាត្រា ១៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។

នៅពេលស្តាប់ចម្លើយ ព្រះរាជអាជ្ញា និងមេធាវីអាចលើកសំណួរមកសួរបាន ដោយមានការអនុញ្ញាតពីចៅក្រមស៊ើបសួរ។ ក្នុងករណីនេះត្រូវចុះនិទ្ទេសនៅក្នុងកំណត់ហេតុ[61] ។

### ៣.២. ការស្តាប់ចម្លើយរបស់សាក្សី[62]

សាក្សីអាចឱ្យនិយមន័យបានថា ជាបុគ្គលដែលស្ថិតនៅក្រៅអង្គហេតុដែលជាកម្មវត្ថុនៃការចោទប្រកាន់ និងអាចផ្តល់ព័ត៌មានដែលជាប្រយោជន៍ដល់ការបង្ហាញការពិតទៅចៅក្រមស៊ើបសួរ។ ប្រសិនបើចៅក្រមស៊ើបសួរយល់ឃើញថា សាក្សីមានសារៈសំខាន់គាត់អាចបញ្ជាឱ្យកោះហៅសាក្សីនោះបាន។

ចៅក្រមស៊ើបសួរ អាចស្តាប់ចម្លើយបុគ្គលគ្រប់រូបដែលចម្លើយនោះអាចមានប្រយោជន៍ នៅក្នុងការសម្តែងឱ្យឃើញការពិត។ ចៅក្រមស៊ើបសួរស្តាប់ចម្លើយសាក្សីដាច់ពីគ្នាដោយគ្មានវត្តមាន ជនត្រូវចោទ និងដើមបណ្តឹងរដ្ឋប្បវេណី។ ចៅក្រមស៊ើបសួរក៏អាចសួរតទល់គ្នារវាង ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីបានផងដែរ។ បុគ្គលគ្រប់រូប ដែលត្រូវបានចៅក្រមស៊ើបសួរកោះហៅក្នុងឋានៈជាសាក្សី ត្រូវតែមកបង្ហាញខ្លួនភ្លាម។ ក្នុងករណីរឹងទទឹងមិនព្រមចូលខ្លួន ចៅក្រមស៊ើបសួរអាចស្នើសុំទៅព្រះរាជអាជ្ញាដែលមានសមត្ថកិច្ចដែនដី ដើម្បីបញ្ជាឱ្យកងកម្លាំងសាធារណៈបង្ខំសាក្សីនេះឱ្យចូលមកបង្ហាញខ្លួនបាន។ ចៅក្រមស៊ើបសួរចេញបញ្ជាឱ្យចូលមកបង្ហាញខ្លួន។ បញ្ជានេះត្រូវមានអត្តសញ្ញាណរបស់សាក្សី ហើយត្រូវចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងមានបោះត្រាផង[63] ។

ប្រសិនបើសាក្សីបានបង្ហាញខ្លួនតាមការកោះហៅរបស់ចៅក្រមស៊ើបសួរហើយ សាក្សីមានកាតព្វកិច្ចធ្វើពាក្យសម្បថរបស់សាក្សី[64] មុននឹងឆ្លើយសំណួរសាក្សីម្នាក់ៗ ត្រូវស្បថស្របតាមសាសនា ឬជំនឿរបស់ខ្លួនថានិយាយតែការពិត។ ទម្រង់នៃសម្បថ ត្រូវធ្វើដូចមានកំណត់នៅក្នុងឧបសម្ព័ន្ធនៃក្រមនីតិវិធីព្រហ្មទណ្ឌ[65] ។ សាក្សីដែលអនុញ្ញាតឱ្យរួចពីសម្បថ ត្រូវបានស្តាប់ចម្លើយដោយមិនចាំបាច់ធ្វើសម្បថមានដូចជា៖

ក- ឪពុក-ម្តាយ និងបុព្វជនគ្រប់រូបរបស់ជនត្រូវចោទ។

ខ- កូនប្រុស-ស្រី និងបច្ឆាជនគ្រប់រូបផ្សេងទៀតរបស់ជនត្រូវចោទ។

គ- បងប្អូនប្រុស-ស្រីរបស់ជនត្រូវចោទ។

ឃ- បងប្អូនថ្លៃប្រុស-ស្រីរបស់ជនត្រូវចោទ។

ង- ប្តី ឬប្រពន្ធរបស់ជនត្រូវចោទ ទោះបីត្រូវបានលែងលះគ្នាហើយក៏ដោយ។

---

[61] មាត្រា ១៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។

[62] ឧបសម្ព័ន្ធ

[63] មាត្រា ១៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។

[64] ឧបសម្ព័ន្ធ

[65] មាត្រា ១៥៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។

ច- កុមារអាយុតិចជាង ១៤ ឆ្នាំ[66] ។

ដើម្បីគោរពសិទ្ធិការពារខ្លួន ចៅក្រមស៊ើបសួរមិនអាចស្ដាប់ចម្លើយក្នុងឋានៈជាសាក្សីនូវបុគ្គលណាមួយដែលមានតម្រុយពិរុទ្ធភាពថាបានប្រព្រឹត្តបទល្មើសនោះទេ។ ប្រសិនបើសាក្សីឈឺ ឬមិនអាចធ្វើដំណើរបាន ចៅក្រមស៊ើបសួរ និងក្រឡាបញ្ជី អាចចុះទៅកាន់លំនៅឋាន ឬទីកន្លែងដែលសាក្សីនោះរស់នៅដើម្បីទទួលចម្លើយ[67] ។ គួរកត់សំគាល់ផងដែរថាសាក្សីមិនមែនជាភាគីនៃការស៊ើបសួរគាត់មិនទទួលបាននូវសិទ្ធិការពារខ្លួនទេ ដូច្នេះគាត់ត្រូវបានស្ដាប់ចម្លើយតែម្នាក់ឯងដោយចៅក្រមស៊ើបសួរ។ ប៉ុន្តែគាត់អាចជាកម្មវត្ថុនៃការសួរតទល់គ្នាជាមួយនឹងភាគីក្នុងសំណុំរឿង។

**៤. ការសួរតទល់**

ការសួរតទល់គ្នាអាចឱ្យនិយមន័យបានថា ជាការសួរចម្លើយ ឬការស្ដាប់ចម្លើយបុគ្គលជាច្រើនព្រមគ្នាក្នុងគោលដៅធ្វើឱ្យលេចចេញនូវធាតុនៃការពិត តាមរយៈយោបល់ និងជំហររបស់បុគ្គលម្នាក់ៗដែលចៅក្រមស៊ើបសួរដាក់តទល់គ្នានោះ។ បទប្បញ្ញត្តិនេះដែលគ្រប់គ្រងការសួរចម្លើយ ជនត្រូវចោទត្រូវយកមកអនុវត្ត។ ការសួរចម្លើយ ការស្ដាប់ចម្លើយ ឬការសួរតទល់នីមួយៗ ត្រូវតែមានធ្វើកំណត់ហេតុ[68] ។ កំណត់ហេតុស្រង់យ៉ាងត្រឹមត្រូវនូវសំណួរចម្លើយ និងចម្លើយដែលឆ្លើយដោយឯកឯង។ ទំព័រនីមួយៗនៃកំណត់ហេតុសួរតទល់ត្រូវចុះហត្ថលេខា ឬផ្ដិតស្នាមម្រាមដៃដោយគ្រប់បុគ្គលទាំងអស់ដែលតទល់គ្នា និងដាយថាហេតុដោយអ្នកបកប្រែ។

នៅក្នុងនីតិវិធីនេះដែរ ព្រះរាជអាជ្ញាអាចមាននៅក្នុងគ្រប់កិច្ចស៊ើបសួរ ជាពិសេសក្នុងការសួរចម្លើយជនត្រូវចោទក្នុងការសួរតទល់ និងក្នុងការស្ដាប់ចម្លើយ[69] ។

**៥. ការចុះដល់ទីកន្លែងកើតហេតុ**

ការចុះដល់ទីកន្លែងកើតហេតុ គឺឆ្លើយតបទៅនឹងគោលដៅតែមួយដូចក្នុងក្របខណ្ឌនៃការស៊ើបអង្កេតរបស់នគរបាលយុត្តិធម៌ដែរ ដូចជាធ្វើការពិនិត្យកត់ត្រា ផ្គុំអង្គហេតុឡើងវិញ ឆែកឆេរ ឬបំពេញគ្រប់កិច្ចស៊ើបសួរផ្សេងទៀតទាំងអស់។ ក៏ប៉ុន្តែការចុះដល់ទីកន្លែងរបស់ចៅក្រមស៊ើបសួរ និងក្រឡាបញ្ជី អាចចុះដល់ទីកន្លែងរបស់ខ្លួនវិសាលភាពនៃសមត្ថកិច្ចដែនដីនៃតុលាការជាន់ដំបូង ដើម្បីបំពេញកិច្ចស៊ើបសួរដែលខ្លួនយល់ឃើញថាមានប្រយោជន៍ជាអាទិ៍ ការពិនិត្យសម្ភារៈ ការឆែកឆេរ និងការចាប់យកវត្ថុតាង។ ចៅក្រមស៊ើបសួរត្រូវជូនដំណឹងទៅព្រះរាជអាជ្ញាអំពីការចុះទៅពិនិត្យនេះ។ ក្នុងករណីនេះ ព្រះរាជអាជ្ញាអាចរួមដំណើរជាមួយចៅក្រមស៊ើបសួរនេះ។

---

[66] មាត្រា ១៥៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។

[67] មាត្រា ១៥៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។

[68] មាត្រា ២៤២ កថាខណ្ឌទី១ និងកថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។

[69] មាត្រា ១៣៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។

ប្រសិនបើមានការចាំបាច់សម្រាប់ការស៊ើបសួរ នោះចៅក្រមស៊ើបសួរអាចចុះទៅកាន់ទីកន្លែង ជាមួយក្រឡាបញ្ជី នៅលើវិសាលភាពដែនដីជាតិទាំងមូល។ ប៉ុន្តែចៅក្រមស៊ើបសួរត្រូវជូនដំណឹងជាមុនដល់ព្រះរាជអាជ្ញាអមតុលាការជាន់ដំបូងនៅក្នុងដែនដីដែលខ្លួនធ្វើដំណើរទៅកាន់នោះ ចៅក្រមស៊ើបសួរត្រូវធ្វើកំណត់ហេតុស្តីពីប្រតិបត្តិការរបស់ខ្លួននេះ[70]។

**៦. ការឆែកឆេរ និងការចាប់យកវត្ថុតាង**

ការឆែកឆេរ គឺអាចធ្វើឡើងផ្ទុយពីគំនិតដែលទទួលបានជារួមចំពោះការស៊ើបសួរមិនអនុញ្ញាត ឱ្យមានការឆែកឆេរគ្រប់កន្លែងដោយពុំមានលក្ខខណ្ឌនោះទេមិនដូចក្នុងករណីស៊ើបអង្កេត បទល្មើសជាក់ស្តែងនោះទេ។ ក្នុងក្របខណ្ឌនៃក្រមព្រហ្មទណ្ឌ ចៅក្រមស៊ើបសួរត្រូវឆែកឆេរនៅចំពោះមុខអ្នកកាន់កាប់ទីកន្លែង ឬបើគ្មានអ្នកកាន់កាប់ទេ ត្រូវធ្វើនៅចំពោះមុខសាក្សី២(ពីរ) នាក់ ដែលខ្លួនចាត់តាំង។ សាក្សីមិនអាចជានគរបាល ឬជាកងរាជអាវុធហត្ថ ដែលជាកងកម្លាំងរួមប្រតិបត្តិការក្នុងការឆែកឆេរនោះបានឡើយ។ ចៅក្រមស៊ើបសួរមិនអាចផ្តើមឆែកឆេរមុនម៉ោង ៦ (ប្រាំមួយ) ព្រឹក និងក្រោយម៉ោង ១៨ (ដប់ប្រាំបី) ល្ងាច បានទេ លើកលែងតែក្នុងករណី៖

- ក្នុងករណីឆែកឆេរនៅគ្រប់ទីកន្លែងដែលបើកចំហរដល់សាធារណៈជន
- ក្នុងករណីឆែកឆេរនៅគ្រប់កន្លែងដែលផលិត រក្សាទុក ជួញដូរ ចែកចាយ ឬប្រើប្រាស់គ្រឿងញៀន។

ចំពោះក្នុងករណីដែលធ្វើការឆែកឆេរនៅក្នុងការិយាល័យមេធាវី ត្រូវធ្វើនៅចំពោះមុខប្រធានគណៈមេធាវី ឬប្រតិភូរបស់ប្រធានគណៈមេធាវី។ ចៅក្រមស៊ើបសួរត្រូវធ្វើកំណត់ហេតុស្តីពីការឆែកឆេរដោយមានចុះហត្ថលេខារបស់ខ្លួន និងក្រឡាបញ្ជី រួមជាមួយអ្នកកាន់កាប់ទីកន្លែង ឬសាក្សី២ (ពីរ) នាក់។ កំណត់ហេតុត្រូវចុះនិទ្ទេស អំពីអត្តសញ្ញាណរបស់អ្នកកាន់កាប់ទីកន្លែង ឬសាក្សីនីមួយៗ។ កាលបើឆែកឆេរប្រព្រឹត្តទៅនៅក្នុងការិយាល័យមេធាវី កំណត់ហេតុត្រូវចុះនិទ្ទេស អំពីវត្តមានរបស់ប្រធានគណៈមេធាវី ឬរបស់ប្រតិភូនៃប្រធានគណៈមេធាវី[71] ។

ចៅក្រមស៊ើបសួរអាចចាប់យកវត្ថុតាង។ ចៅក្រមស៊ើបសួរត្រូវតែបិទស្លាកបោះត្រាលើវត្ថុតាង។ ក្រោយពីបានបង្ហាញវត្ថុដែលចាប់ដល់អ្នកកាន់កាប់ទីកន្លែង ឬដល់សាក្សីទាំង២ (ពីរ) នាក់ រួចមកចៅក្រមស៊ើបសួរធ្វើកំណត់ហេតុស្តីពីការចាប់ ដែលរួមមានបញ្ជីសារពើភ័ណ្ឌនៃវត្ថុដែលចាប់យក។ កំណត់ហេតុស្តីពីការចាប់នេះ ត្រូវមានចុះហត្ថលេខារបស់ចៅក្រមស៊ើបសួរ និងក្រឡាបញ្ជី រួមជាមួយអ្នកកាន់កាប់ទីកន្លែង ឬសាក្សី២ (ពីរ) នាក់។ កំណត់ហេតុត្រូវមានចុះនិទ្ទេសអំពីអត្តសញ្ញាណនៃអ្នកកាន់កាប់ទីកន្លែង ឬសាក្សីនីមួយៗ[72] ។

[70] មាត្រា ១៣០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។
[71] មាត្រា ១៥៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។
[72] មាត្រា ១៦០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។

នៅពេលដែលមិនទាន់ចេញដីកាដំណោះស្រាយរឿងនៅឡើយទេ ចៅក្រមស៊ើបសួរមានសមត្ថកិច្ចប្រគល់សងទៅម្ចាស់ដើមវិញនូវវត្ថុដែលចាប់បាន កាលណាកម្មសិទ្ធិនេះគ្មានជំទាស់អ្វីប្រាកដប្រជាទេ។ ចៅក្រមស៊ើបសួរសម្រេចតាមដីកាដែលមានសម្អាងហេតុ ក្រោយពីបានទទួលមតិពីព្រះរាជអាជ្ញា។ ដីកាសម្រេចត្រូវឱ្យដំណឹងជាបន្ទាន់ដល់អ្នកប្តឹង និងមេធាវីនៃអ្នកប្តឹងប្រសិនបើមាន។ មិនគួរប្រគល់សងទៅឱ្យអ្នកប្តឹងសុំទេ កាលណាវិធានការនេះអាចបង្កជាឧបសគ្គដល់ការសម្តែងឱ្យឃើញការពិត។ វត្ថុដែលមានគ្រោះថ្នាក់ដល់បុគ្គល ឬទ្រព្យសម្បត្តិដូចជាអាវុធ ឬជាតិផ្ទុះ ព្រមទាំងវត្ថុដែលកាន់កាប់មិនស្របច្បាប់ មិនអាចត្រូវប្រគល់សងទៅឱ្យសាមីខ្លួនបានទេ។ វត្ថុទាំងនេះត្រូវរឹបអូសជាកម្មសិទ្ធិរបស់រដ្ឋ[73] ។

### ៧. ការធ្វើកោសលវិច័យ

ការធ្វើកោសលវិច័យ គឺជាការពិនិត្យធ្វើឡើងដោយអ្នកជំនាញចាត់តាំងដោយចៅក្រមស៊ើបសួរ ដែលសុំយោបល់បំភ្លឺលើបញ្ហាបច្ចេកទេសសុទ្ធសាធលើវិស័យផ្សេងៗនៃវេជ្ជសាស្ត្រ ពេទ្យវិជ្ជានីត្យានុកូល ពិន្ទុវិទ្យា ជីវសាស្ត្រ ចិត្តវិទ្យា អង្គលីទស្សន៍ អង្គលីលេខ ព័ត៌មានវិទ្យា និងសវនករជាដើម... ។ល។

នៅក្នុងករណីដែលមានបញ្ហាបច្ចេកទេសចោទឡើង ចៅក្រមស៊ើបសួរអាចបង្គាប់ឱ្យធ្វើកោសលវិច័យដោយឯកឯង ឬតាមពាក្យសុំព្រះរាជអាជ្ញារបស់ជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណី។ កាលណាចៅក្រមស៊ើបសួរបដិសេធមិនព្រមធ្វើតាមពាក្យសុំធ្វើកោសលវិច័យចៅក្រមស៊ើបសួរត្រូវសម្រេចតាមដីកាដោយមានសំអាងហេតុ។ ដីកាត្រូវសម្រេចក្នុងរយៈពេល ៥ (ប្រាំ)ថ្ងៃ ប្រសិនបើពាក្យសុំនោះចេញមកពីព្រះរាជអាជ្ញា និង ១ (មួយ) ខែ ប្រសិនបើពាក្យនោះចេញពីជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណី។ ដីកាសម្រេចនេះត្រូវជូនដំណឹងឱ្យដល់អ្នកប្តឹងសុំជាបន្ទាន់[74] ។

ការធ្វើកោសលវិច័យក្នុងរឿងព្រហ្មទណ្ឌ ត្រូវបានបង្កើតឱ្យមានបញ្ជីថ្នាក់ជាតិមួយនៃអ្នកជំនាញ។ បញ្ជីនេះត្រូវបានរៀបចំឡើងដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ បែបបទនៃការចុះឈ្មោះ ឬលុបឈ្មោះចេញពីបញ្ជីត្រូវកំណត់ដោយប្រកាសរបស់ក្រសួងយុត្តិធម៌។ អ្នកជំនាញដែលត្រូវបានចុះឈ្មោះនៅក្នុងបញ្ជីថ្នាក់ជាតិ ត្រូវស្បថនៅសាលាឧទ្ធរណ៍ភ្នំពេញស្របតាមសាសនា ឬជំនឿរបស់ខ្លួនថានឹងផ្តល់ជំនួយដោយស្មោះត្រង់ក្នុងការស្វែងរកយុត្តិធម៌។ អ្នកជំនាញដែលត្រូវបានចុះឈ្មោះបញ្ជីមិនចាំបាច់ស្បថសារជាថ្មីទៀតទេ នៅពេលណាខ្លួនត្រូវបានគេចាត់តាំងឱ្យធ្វើកោសលវិច័យ[75] ។

ចៅក្រមស៊ើបសួរ តាមធម្មតាត្រូវជ្រើសរើសអ្នកជំនាញដែលត្រូវបានចុះឈ្មោះនៅក្នុងបញ្ជីថ្នាក់ជាតិនៃអ្នកជំនាញ។ ចៅក្រមស៊ើបសួរ តាមដីកាដោយមានសំអាងជាពិសេស អាចចាត់តាំងអ្នកជំនាញដែលគ្មានឈ្មោះ

[73] មាត្រា ១៦១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។

[74] មាត្រា ១៦២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។

[75] មាត្រា ១៦៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។

ថ្នាក់ជាតិបាន។ ក្នុងករណីនេះអ្នកជំនាញត្រូវស្បថតាម សាសនា ឬជំនឿរបស់ខ្លួនថា ខ្លួននឹងផ្តល់ជំនួយដោយស្មោះត្រង់ដល់ការស្វែងរកយុត្តិធម៌[76] ។ អ្នកជំនាញត្រូវបានចាត់តាំងតាមដីការបស់ចៅក្រមស៊ើបសួរ។ ដីកាត្រូវបញ្ជាក់អំពីបេសកកម្មរបស់អ្នកជំនាញព្រមទាំងរយៈពេលដែលត្រូវបំពេញនេះ។ បេសកកម្មអាចទាក់ទងទៅនឹងបញ្ហាដែលមានលក្ខណៈបច្ចេកទេសតែប៉ុណ្ណោះ។ ប្រសិនបើជាការគួរ ចៅក្រមស៊ើបសួរប្រគល់វត្ថុដែលចាប់បានមួយផ្នែក ឬទាំងអស់នោះជូនអ្នកជំនាញ។ ចៅក្រមស៊ើបសួរត្រូវធ្វើកំណត់ហេតុស្តីពីការប្រគល់វត្ថុដែលចាប់បាន។ អ្នកជំនាញអាចបំបែកស្លាកដែលបិទដើម្បីធ្វើកោសលវិច័យបាន។ ប្រសិនបើកោសលវិច័យនេះអាចធ្វើឱ្យខូចខាត ឬវិនាសដល់វត្ថុដែលចាប់បាននោះ អ្នកជំនាញត្រូវជូនព័ត៌មានដល់ចៅក្រមស៊ើបសួរ និងសុំអនុញ្ញាតពីចៅក្រមស៊ើបសួរនោះ មុននឹងផ្តើមប្រតិបត្តិការរបស់ខ្លួន[77] ។

ប្រសិនបើអ្នកជំនាញមិនគោរពរយៈពេលដែលកំណត់ដោយចៅក្រមស៊ើបសួរទេ ចៅក្រមស៊ើបសួរចាត់តាំងអ្នកជំនាញផ្សេងទៀតជំនួសអ្នកជំនាញនោះ។ ប៉ុន្តែប្រសិនបើកាលៈទេសៈតម្រូវនោះ ចៅក្រមស៊ើបសួរអាចអនុញ្ញាតតាមដីកាសម្រេចឱ្យធ្វើការពន្យារពេលបាន។ ដើម្បីបំពេញបេសកកម្មរបស់ខ្លួន អ្នកជំនាញអាចស្តាប់ចម្លើយបុគ្គលគ្រប់រូបក្រៅពីជនត្រូវចោទ។ ចម្លើយដែលអ្នកជំនាញបានទទួលនោះ មានតម្លៃត្រឹមតែជាព័ត៌មានធម្មតា។ បុគ្គលដែលអ្នកជំនាញស្តាប់នោះមិនបាច់ស្បថទេ។ ប្រសិនបើខ្លួនយល់ឃើញថា ចាំបាច់ត្រូវស្តាប់ចម្លើយជនត្រូវចោទ អ្នកជំនាញត្រូវសុំការអនុញ្ញាតចៅក្រមស៊ើបសួរ។ ជនត្រូវចោទអាចសុំឱ្យអ្នកជំនាញស្តាប់ចម្លើយរបស់ខ្លួននៅចំពោះមុខមេធាវី។ ប៉ុន្តែកាលណាចៅក្រមស៊ើបសួរចាត់តាំងគ្រូពេទ្យ ឬអ្នកចិត្តសាស្ត្រដើម្បីពិនិត្យជនត្រូវចោទនោះការពិនិត្យវេជ្ជសាស្ត្រ ឬចិត្តសាស្ត្រ ត្រូវធ្វើដោយគ្មានវត្តមានមេធាវី[78] ។

កាលណាប្រតិបត្តិការកោសលវិច័យបានបញ្ចប់ អ្នកជំនាញធ្វើរបាយកាណ៍ដែលនៅក្នុងនោះ ត្រូវពណ៌នាយ៉ាងច្បាស់លាស់អំពីប្រតិបត្តិការរបស់ខ្លួន ហើយនឹងធ្វើសេចក្តីសន្និដ្ឋាន។ អ្នកជំនាញត្រូវបញ្ជាក់ថាបានធ្វើដោយផ្ទាល់ខ្លួន នូវប្រតិបត្តិការដែលពណ៌នានៅក្នុងរបាយការណ៍។ របាយការណ៍កាលបរិច្ឆេទ និងចុះហត្ថលេខា។ កាលណាអ្នកជំនាញបានបំបែកស្លាកដើម្បីពិនិត្យវត្ថុដែលចាប់យក អ្នកជំនាញត្រូវចុះនិទ្ទេសអ្នកបញ្ហានេះនៅក្នុងរបាយការណ៍របស់ខ្លួន។ កាលណាអ្នកជំនាញប្រគល់របាយការណ៍របស់ខ្លួននោះ អ្នកជំនាញត្រូវប្រគល់ដល់ចៅក្រមស៊ើបសួរវិញនូវវត្ថុដែលចាប់យក។ ប្រសិនបើស្លាកត្រូវបានបំបែក ចៅក្រមស៊ើបសួរត្រូវបិទស្លាកជាថ្មីនៅលើវត្ថុនោះ។ កំណត់ហេតុស្តីពីការប្រគល់សងនូវវត្ថុ និងដោយយថាហេតុ ការបិទស្លាកជាថ្មីលើវត្ថុនោះត្រូវធ្វើឡើងវិញ។ កាលណាកោសលវិច័យធ្វើឱ្យខូចខាត ឬវិនាសនូវវត្ថុដែលចាប់បានអ្នកជំនាញត្រូវចុះនិទ្ទេសនៅក្នុង

[76] មាត្រា ១៦៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។
[77] មាត្រា ១៦៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។
[78] មាត្រា ១៦៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។

របាយការណ៍របស់ខ្លួនអំពីការអនុញ្ញាតរបស់ចៅក្រមស៊ើបសួរ។ ក្នុងករណីដែលអាចធ្វើបាននោះ អ្នកជំនាញត្រូវធ្វើសេចក្ដីចម្លងរបាយការណ៍ហើយជូនចៅក្រមស៊ើបសួរ[79] ។

ប្រសិនបើកាលៈទេសៈតម្រូវ ចៅក្រមស៊ើបសួរអាចចាត់តាំងអ្នកជំនាញច្រើននាក់។ នៅក្នុងករណីនេះ ប្រសិនបើអ្នកជំនាញនេះមានយោបល់ខុសគ្នានោះ ម្នាក់ៗត្រូវសរសេរអំពីយោបល់របស់ខ្លួនផ្ទាល់ ឬការមិនយល់ព្រមរបស់ខ្លួន[80] ។

កាលណារបាយការណ៍កោសលវិច័យត្រូវបានធ្វើរួចហើយ ចៅក្រមស៊ើបសួរត្រូវជូនព័ត៌មានដល់ព្រះរាជអាជ្ញា។ របាយការណ៍កោសលវិច័យត្រូវដាក់ចូលក្នុងសំណុំរឿងស៊ើបសួរ។ ចៅក្រមស៊ើបសួរកោះហៅជនត្រូវចោទ និងមេធាវី ដើម្បីប្រាប់ឱ្យដឹងពីសេចក្ដីសន្និដ្ឋាននៃកោសលវិច័យនេះ។ ចៅក្រមស៊ើបសួរអាចកោះហៅដើមបណ្ដឹងរដ្ឋប្បវេណី និងមេធាវីផងដែរដើម្បីប្រាប់ឱ្យដឹងពីសេចក្ដីសន្និដ្ឋាននៃកោសលវិច័យ។ ចៅក្រមស៊ើបសួរកំណត់រយៈពេលដែលអនុញ្ញាឱ្យព្រះរាជអាជ្ញាជនត្រូវចោទ ឬដើមបណ្ដឹងរដ្ឋប្បវេណីដាក់ពាក្យសុំធ្វើកោសលវិច័យបន្ថែម ឬប្រតិកោសលវិច័យ។ រយៈពេលនៃការអនុញ្ញាតដាក់ពាក្យបណ្ដឹងស្នើសុំធ្វើកោសលវិច័យ មិនអាចតិចជាង ១០(ដប់)ថ្ងៃទេ។ ក្នុងរយៈពេលនេះ សំណុំរឿងដែលរួមមានរបាយការណ៍កោសលវិច័យ អាចត្រូវបានពិនិត្យមើលដោយមេធាវី។ គ្រប់ពាក្យសំដីកោសលវិច័យបន្ថែម ឬប្រតិកោសលវិច័យ ត្រូវមានតែមានសំអាងហេតុ និងធ្វើឡើងជាលាយលក្ខណ៍អក្សរ។ កាលណាចៅក្រមស៊ើបសួរមិនព្រមធ្វើតាមពាក្យសុំធ្វើកោសលវិច័យបន្ថែម ឬប្រតិកោសលវិច័យទេ ចៅក្រមស៊ើបសួរត្រូវសម្រេចតាមដីកាដោយមានសំអាងហេតុ។ ដីកាត្រូវតែសម្រេចក្នុងរយៈពេល ៥(ប្រាំ) ថ្ងៃ ប្រសិនបើពាក្យសុំចេញមកពីព្រះរាជអាជ្ញា និង១(មួយ)ខែ ប្រសិនបើពាក្យនេះចេញពីជនត្រូវចោទ ឬដើមបណ្ដឹងរដ្ឋប្បវេណី។ ដីកាត្រូវឱ្យដំណឹងជាបន្ទាន់ទៅឱ្យអ្នកប្ដឹងសុំ។ គ្រប់ពាក្យសុំធ្វើកោសលវិច័យបន្ថែម ឬប្រតិកោសលវិច័យដែលធ្វើឡើងក្រោយផុតរយៈពេលដែលបានកំណត់ដោយចៅក្រមស៊ើបសួរ ត្រូវដាក់បញ្ចូលក្នុងសំណុំរឿង។ ប្រសិនបើចៅក្រមស៊ើបសួរដែលបានទទួលពាក្យសុំឱ្យធ្វើកោសលវិច័យ កោសលវិច័យបន្ថែម ឬប្រតិកោសលវិច័យ មិនព្រមសម្រេចក្នុងរយៈពេលដែលបានកំណត់នេះទេ អ្នកសុំអាចធ្វើពាក្យបណ្ដឹងដោយផ្ទាល់តាមរយៈពាក្យសុំដល់ សភាស៊ើបសួរដែលសម្រេចជំនួសចៅក្រមស៊ើបសួរ[81]។

សោហ៊ុយក្នុងការធ្វើកោសលវិច័យជាបន្ទុករបស់អ្នកស្នើសុំ។ កាលណាចៅក្រមស៊ើបសួរ ព្រះរាជអាជ្ញា ឬមន្ត្រីនគរបាលយុត្តិធម៌ ស្នើសុំឱ្យធ្វើកោសលវិច័យ កោសលវិច័យបន្ថែម ឬប្រតិកោសលវិច័យ សោហ៊ុយទាំងនេះជាបន្ទុករបស់រដ្ឋ[82] ។

**៨. ការស្ដាប់ចូរស័ព្ទ**

[79] មាត្រា ១៦៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។

[80] មាត្រា ១៦៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។

[81] មាត្រា ១៧០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។

[82] មាត្រា ១៧១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។

ការស្តាប់ទូរស័ព្ទ គឺជាការថតការសន្ទនាតាមទូរស័ព្ទ ការចាប់ និងការថតគ្រប់ការឆ្លើយឆ្លងតាមមធ្យោបាយទូរគមនាគមន៍ ការឆ្លើយឆ្លងជាសារជាដើម។ល។ តាមការចាំបាច់ដើម្បីសម្តែងឱ្យឃើញនូវការពិត ចៅក្រមស៊ើបសួរអាចបង្គាប់ឱ្យស្តាប់ និងថតការសន្ទនាតាមទូរស័ព្ទ។ ចៅក្រមស៊ើបសួរក៏អាចបង្គាប់ឱ្យចាប់ និងថតគ្រប់ការឆ្លើយឆ្លងគ្នាតាមមធ្យោបាយគមនាគមន៍ផងដែរដូចជា សារតាមទូរសារ ឬសារតាមអ៊ីនធើណែត។ ចៅក្រមស៊ើបសួរអាចសុំឱ្យគ្រប់អង្គភាពសាធារណៈ ឬគ្រប់មន្ត្រីជំនាញតាំងឧបករណ៍បច្ចេកទេស និងធ្វើការថត។ ចៅក្រមស៊ើបសួរបញ្ជាក់នៅក្នុងដីកាសម្រេចរបស់ខ្លួនអំពីប្រភេទនៃទំនាក់ទំនងដែលត្រូវចាប់ ព្រមទាំងអំពីរយៈពេលនៃបេសកកម្ម។

អង្គការសាធារណៈ មន្ត្រីរាជការដែលចាត់តាំង ត្រូវបំពេញតាមពាក្យសុំរបស់ចៅក្រមស៊ើបសួរ នៅក្នុងពេលអនុវត្តបេសកកម្ម អង្គភាពសាធារណៈ ឬគ្រប់មន្ត្រីរាជការដែលចាត់តាំងត្រូវជូនព័ត៌មានដល់ចៅក្រមស៊ើបសួរអំពីការប្រព្រឹត្តទៅនៃបេសកកម្មជាអាទិ៍ អំពីការលំបាកជាយថាហេតុ។ កាលណាបេសកកម្មត្រូវបំពេញរួចហើយ អង្គការសាធារណៈ ឬគ្រប់មន្ត្រីរាជការនោះត្រូវចម្លងជាលាយលក្ខណ៍អក្សរនូវសម្លេងដែលបានថត។ ការធ្វើឱ្យទៅជាលាយលក្ខណ៍អក្សរនេះ ត្រូវឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនូវសម្លេងដែលថតបាន។ សម្លេងដែលបានថតនេះត្រូវប្រគល់ជូនចៅក្រមស៊ើបសួរ និងបិទស្លាក។ គ្រប់ពេលវេលា ចៅក្រមស៊ើបសួរអាចចុះទៅកាន់កន្លែងដែលធ្វើការចាប់ និងថត។ ការចូលទៅក្នុងកន្លែងទាំងនេះ មិនអាចត្រូវបានហាមឃាត់ដល់ចៅក្រមស៊ើបសួរដោយសំអាងលើមូលហេតុអ្វីបានទេ ទោះបីជាទីកន្លែងយោធាក៏ដោយ។ ចៅក្រមស៊ើបសួរក៏អាចធ្វើកិច្ចការនេះតាមដីកាចាត់ឱ្យស៊ើបសួរជំនួសបានដែរ[83] ។

**កថាខណ្ឌទី៣ ៖ ការផ្ទេរអំណាចក្នុងការស៊ើបសួរ**

**១. ដីកាចាត់ឱ្យស៊ើបសួរជំនួស**[84]

ដីកាចាត់ឱ្យស៊ើបសួរជំនួសអាចឱ្យនិយមន័យបានថា ជាប្រតិភូកម្មនៃអំណាចដែលចៅក្រមស៊ើបសួរប្រគល់ឱ្យចៅក្រមផ្សេង ឬមន្ត្រីនគរបាល អង្គភាពនគរបាល ដើម្បីអនុវត្តកិច្ចស៊ើបសួរមួយ ឬច្រើនដែលគាត់កំណត់[85] ។

ដោយមានន័យថាជាប្រតិភូកម្មអំណាច ដីកាចាត់ឱ្យស៊ើបសួរជំនួសអាចចេញតែដើម្បីផ្ទេរអំណាចដែលចៅក្រមស៊ើបសួរមានប៉ុណ្ណោះ។ ដីកាចាត់ឱ្យសួរសាក្សីក៏ត្រូវបានគ្រប់គ្រងដោយគោលការណ៍មួយដែលចែងថា ដីកាមិនអាចមានលក្ខណៈទូទៅទេ ព្រោះក្នុងករណីនេះគឺវាជាការដោះបន្ទុករបស់ចៅក្រមស៊ើបសួរពីសំណុំរឿង។ ចៅក្រមស៊ើបសួរអាច បញ្ឈប់ដីកាចាត់ឱ្យស៊ើបសួរជំនួសបានគ្រប់ពេលវេលា និងមុនពេលដែលការអនុវត្តដីកានេះត្រូវបញ្ចប់។

---

[83] មាត្រា ១៧២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។

[84] ឧបសម្ព័ន

[85] មាត្រា ១៧៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។

ដីកាចាត់ឱ្យស៊ើបសួរជំនួសដែលត្រូវតែពិសេសជាដាច់ខាតត្រូវតែបញ្ជាក់ឱ្យបានច្បាស់លាស់នូវកិច្ចដែលអនុញ្ញាតព្រមទាំងថិរវេលានៃការធ្វើកិច្ចទាំងនេះ។ កិច្ចនោះត្រូវមានទំនាក់ទំនងដោយផ្ទាល់ជាមួយបទល្មើសដែលចោទប្រកាន់។ ដីកាចាត់ឱ្យស៊ើបសួរជំនួសមិនអាចមានលក្ខណៈជាទូទៅទេ ត្រូវណែនាំឱ្យបានច្បាស់លាស់។ ចៅក្រមស៊ើបសួរកំណត់ថិរវេលាដែលត្រូវអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស។ ដីកាចាត់ឱ្យស៊ើបសួរជំនួសត្រូវមានចុះកាលបរិច្ឆេទ ចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងមានបោះត្រាផងដែរ[86] ។ គួរឱ្យកត់សម្គាល់ផងដែរថា កាលណាភ្លេចនិទ្ទេសមួយក្នុងចំណោមនិទ្ទេសទាំងអស់ នៅក្នុងដីកាចាត់ឱ្យស៊ើបសួរជំនួសនោះអាចបណ្តាលឱ្យមានមោឃភាពនៃដីកាចាត់ឱ្យស៊ើបសួរជំនួស និងមោឃភាពនៃគ្រប់កិច្ចដែលបានធ្វើជាបន្តបន្ទាប់។ ហើយកាលណាដីកាចាត់ឱ្យស៊ើបសួរជំនួសត្រូវបានចេញឱ្យដល់ចៅក្រមណាម្នាក់ ចៅក្រមរូបនេះប្រើប្រាស់អំណាចទាំងអស់របស់ចៅក្រមស៊ើបសួរ[87] ។ ការប្រតិបត្តិដីកាចាត់ឱ្យស៊ើបសួរជំនួសដោយមន្ត្រីនគរបាលយុត្តិធម៌ បំពេញកិច្ចដែលមានចែងនៅក្នុងដីកាចាត់ឱ្យស៊ើបសួរជំនួស នៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួនតែប៉ុណ្ណោះ[88] ។ ក៏ប៉ុន្តែមានការលើកលែងដែលមាននៅក្នុងបទប្បញ្ញត្តិនៃកថាខណ្ឌទី២ ទី៣ និងទី៤ នៃមាត្រា ៦៨ ( ពន្លាតសមត្ថកិច្ចដែនដី) នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានចែងថា៖ ក្នុងក្របខណ្ឌនៃការស៊ើបសួរ កាលណាចៅក្រមស៊ើបសួរចេញដីកាចាត់ឱ្យស៊ើបសួរជំនួស ក្នុងករណីបន្ទាប់ចៅក្រមនេះអាចអនុញ្ញាតឱ្យមន្ត្រីនគរបាលយុត្តធម៌ធ្វើប្រតិបត្តិការនៅលើវិសាលភាពដែនដីទាំងមូល។ កាលណាធ្វើប្រតិបត្តិការនៅក្រៅមណ្ឌលរបស់ខ្លួននោះ មន្ត្រីនគរបាលយុត្តិធម៌ត្រូវសុំជំនួយពីមន្ត្រីនគរបាលយុត្តធម៌ដែលមានសមត្ថកិច្ចខាងដែនដី។ ចៅក្រមដែលបានអនុញ្ញាតឱ្យមានការពន្លាតសមត្ថកិច្ច ត្រូវជូនព័ត៌មានតាមគ្រប់មធ្យោបាយដល់ព្រះរាជអាជ្ញាដែលមានសមត្ថកិច្ចខាងដែនដី[89] ។

ចៅក្រមស៊ើបសួរអាចចាត់តាំងមន្ត្រីនគរបាលយុត្តិធម៌ដែលមានក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ព្រមទាំងគ្រប់មន្ត្រីនគរបាលយុត្តិធម៌លើដែនដីប្រទេសទាំងមូល មន្ត្រីនគរបាលយុត្តិធម៌នេះស្ថិតនៅក្រោមអំណាចដោយផ្ទាល់របស់ចៅក្រមស៊ើបសួរ ក្នុងក្របខណ្ឌនៃការអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស។

ប៉ុន្តែចៅក្រមស៊ើបសួរមិនអាចផ្ទេរអំណាចទាំងអស់របស់ខ្លួនបានទេ។ អំណាចដែលមិនអាចត្រូវបានផ្ទេរទៅឱ្យមន្ត្រីនគរបាលយុត្តិធម៌ គឺជាអំណាចចោទប្រកាន់បុគ្គលណាម្នាក់ អំណាចសួរចម្លើយជនត្រូវចោទ ឬស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី អំណាចសួរតទល់បុគ្គលខាងលើជាមួយនឹងមនុស្សផ្សេងទៀត ឬអំណាចចេញដីកា ឬធ្វើការឆែកឆេរក្នុងកន្លែងដែលការពារ។ អំណាចដែលចៅក្រមស៊ើបសួរអាចផ្ទេរបានមានដូចជា៖

[86] មាត្រា ១៧៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។
[87] មាត្រា ១៧៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។
[88] មាត្រា ១៧៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។
[89] មាត្រា ៦៨ កថាខណ្ឌទី១ ទី២ និងកថាខណ្ឌទី៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។

- ការឆែកឆេរ និងការចាប់យកវត្ថុតាង៖ មន្ត្រីនគរបាលអាចធ្វើការឆែកឆេរបាន។ ក្នុងករណីនេះត្រូវទទួលជាបឋមនូវការអនុញ្ញាតពីព្រះរាជអាជ្ញា ទោះបីជាការអនុញ្ញាតដោយផ្ទាល់មាត់ក៏ដោយ។ មន្ត្រីនគរបាល ត្រូវធ្វើការឆែកឆេរនៅចំពោះមុខអ្នកកាន់កាប់ទីកន្លែង ឬបើគ្មានអ្នកកាន់កាប់ទេត្រូវធ្វើនៅចំពោះមុខសាក្សីពីររូប។ សាក្សីមិនអាចជានគរបាល ឬជាកងរាជអាវុធហត្ថ ដែលជាកងកម្លាំងរួមប្រតិបត្តិការក្នុងការឆែកឆេរនេះបានឡើយ[90] ។

- ការឃាត់ខ្លួន ៖ អំណាចនៃការឃាត់ខ្លួនត្រូវត្រួតពិនិត្យធ្វើដោយព្រះរាជអាជ្ញាក្នុងក្របខណ្ឌនៃការស៊ើបអង្កេតតាមផ្លូវតុលាការត្រូវធ្វើដោយចៅក្រមស៊ើបសួរ នៅពេលឃាត់ខ្លួនក្នុងក្របខណ្ឌនៃដីកាចាត់ឱ្យស៊ើបសួរជំនួស។ នៅពេលដែលផុតវិធាននេះ បុគ្គលនោះត្រូវបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរ។

- ការស្តាប់ទូរស័ព្ទ ៖ កាលណាដីកាចាត់ឱ្យស៊ើបសួរជំនួសបានចែងអំពីការស្តាប់ និងការថតការសន្ទនាតាមទូរស័ព្ទឬការចាប់ និងការថតគ្រប់ការឆ្លើយឆ្លងតាមមធ្យោបាយទូរគមនាគមន៍ ដូចជាសារតាមទូរសារ ឬសារតាមអ៊ីនធើណែត មន្ត្រីនគរបាលយុត្តិធម៌ប្រើប្រាស់អំណាចដែលប្រគល់ឱ្យចៅក្រមស៊ើបសួរដោយវាក្យខណ្ឌទី២ កថាខណ្ឌទី១ និងកថាខណ្ឌទី២ មាត្រា១៧២ ( ការស្តាប់ទូរស័ព្ទជាអាទិ៍ដែលបង្គាប់ដោយចៅក្រមស៊ើបសួរ ) នៃក្រមនេះ[91] ។

- ការធ្វើកំណត់ហេតុ៖ កំណត់ហេតុដែលធ្វើឡើងដោយមន្ត្រីនគរបាលយុត្តិធម៌ នៅក្នុងក្របខណ្ឌនៃការអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួសត្រូវស្ថិតនៅក្រោមបទបញ្ញត្តិនៃ មាត្រា១០៨ ( និទ្ទេសដែលត្រូវចុះនៅក្នុងកំណត់ហេតុ ) នៃក្រមនីតិវិធីរដ្ឋប្បវេណី[92] ។

## កថាខណ្ឌទី៤ ៖ វិធានការនិរន្តរាយ

### ១. ដីកា

ដីកា ជាប្រភេទនៃសេចក្តីសម្រេចមុនអង្គសេចក្តីដែលត្រូវបានយកមកប្រើប្រាស់សម្រាប់ការសម្រេចសេចក្តីក្នុងដំណាក់កាលនីមួយៗនៃនីតិវិធីព្រហ្មទណ្ឌ។ នៅក្នុងនីតិវិធីព្រហ្មទណ្ឌដីកាមានច្រើនប្រភេទណាស់។ ដីកាទាំងនោះមានមុខងារ ខុសៗគ្នាទៅតាមអត្ថន័យនៃដីកានោះ។ គោលបំណងនៃការចេញដីកាទាំងនោះគឺដើម្បីជួយសម្រួលដល់នីតិវិធីអោយមានដំណើរការល្អ និងជម្រុញឱ្យនីតិវិធីមានភាពឆាប់រហ័សផងដែរ។ នៅក្នុងដំណាក់កាលនេះដែលចៅក្រមស៊ើបសួរអាចចេញដែលនៅក្នុងវិធានការនិរន្តរាយមាន ៤ ( បួន ) ដីកាដូចជា៖

#### ១.១. ដីកាបង្គាប់ឱ្យចូលខ្លួន[93]

[90] មាត្រា ៩១ កថាខណ្ឌទី១ និងកថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។
[91] មាត្រា ១៨៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។
[92] មាត្រា ១៨៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។
[93] ឧបសម្ព័ន្ធ

ដីកាបង្គាប់ឱ្យចូលខ្លួន សំដៅលើការបញ្ជាដល់បុគ្គលណាម្នាក់ ឱ្យចូលទៅបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរ។ ដីកានេះអាចចេញទៅលើជនត្រូវចោទ ឬទៅលើបុគ្គលណាម្នាក់ដែលមានតម្រុយពិរុទ្ធភាព[94] ។ ជាទូទៅដីកានេះដែរ ត្រូវគេបានប្រើប្រាស់នៅពេលណាដែលសាមីខ្លួនមិនបានរត់គេចខ្លួន ពុំឆ្លើយតបទៅនឹងដីកាកោះហៅរបស់រដ្ឋបាលនៅពេលចូលខ្លួនភ្លាម ចៅក្រមស៊ើបសួរត្រូវធ្វើការសួរចម្លើយបុគ្គលនោះ។ ដីកាត្រូវចុះនិទ្ទេសជាដាច់ខាតដូចជា អត្តសញ្ញាណនៃបុគ្គលដែលពាក់ព័ន្ធនឹងបទល្មើសចោទប្រកាន់ អត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស ថ្ងៃ ខែ ឆ្នាំ ម៉ោង និងទីកន្លែងដែលត្រូវចូលខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរ និងឈ្មោះ ឋានៈរបស់ចៅក្រមដែលចេញដីកា។ ដីកាបង្គាប់ឱ្យចូលខ្លួនត្រូវចុះកាលបរិច្ឆេទ និងចុះហត្ថលេខដោយចៅក្រមស៊ើបសួរ និងមានបោះត្រាផង[95] ។ បើតាមវិធាននៃការដាក់ពិរុទ្ធភាព សាមីខ្លួនអាចចេញពីការិយាល័យរបស់ចៅក្រមស៊ើបសួរដោយមានសេរីភាព ឬក៏អាចត្រូវបញ្ជូនទៅកន្លែងឃុំខ្លួនបើចៅក្រមស៊ើបសួរសម្រេចឃុំខ្លួនបណ្ដោះអាសន្នក្នុងករណីនេះ ចៅក្រមស៊ើបសួរចេញដីកាឃុំខ្លួនទៅលើបុគ្គលនេះ។ ដីកាបង្គាប់ឱ្យចូលខ្លួនពុំមានតម្លៃបង្ខំទេ ដូច្នេះការបដិសេធមិនចូលខ្លួន ទាំងចៅក្រមស៊ើបសួរចេញដីកាបង្គាប់ឱ្យនាំខ្លួន។ ដីកាបង្គាប់ឱ្យចូលខ្លួនត្រូវឱ្យដំណឹងដល់បុគ្គលដែលពាក់ព័ន្ធដោយមន្ត្រីនគរបាលយុត្តិធម៌ ភ្នាក់ងារនគរបាលយុត្តិធម៌ ឬអាជ្ញាសាលា។ បុគ្គលពាក់ព័ន្ធទទួលចុងដីកា ត្រូវហត្ថលេខានៅលើដើមដីកា ដែលត្រូវបង្វិលជូនចៅក្រមស៊ើបសួរ[96] ។

**១.២. ដីកាបង្គាប់ឱ្យនាំខ្លួន**[97]

ដីកាបង្គាប់ឱ្យនាំខ្លួន គឺជាបញ្ជាដល់កងកម្លាំងសាធារណៈឱ្យចាប់ខ្លួន និងនាំខ្លួនបុគ្គលណាម្នាក់ទៅចំពោះមុខចៅក្រមស៊ើបសួរ។ ដីកានេះអាចចេញទៅលើជនត្រូវចោទ ឬទៅលើបុគ្គលណាម្នាក់ដែលមានតម្រុយពិរុទ្ធភាព[98]។ ជាទូទៅដីកានេះ ត្រូវបានប្រើប្រាស់នៅពេលដែលសាមីខ្លួន ដែលមិនព្រមចូលខ្លួន មកឆ្លើយតបទៅនឹងដីកាកោះហៅរបស់ចៅក្រមស៊ើបសួរ នៅពេលមិនព្រមចូលខ្លួនភ្លាមលើកទី១។ ដីកាត្រូវចុះនិទ្ទេសជាដាច់ខាតដូចជាអត្តសញ្ញាណនៃបុគ្គលដែលពាក់ព័ន្ធបទល្មើសដែលចោទប្រកាន់ អត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស។ ដីកាបង្គាប់ឱ្យនាំខ្លួនត្រូវចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងមានបោះត្រាផង[99] ។ ប្រសិនបើដោយមូលហេតុនៃ កាលៈទេសៈបុគ្គលដែលពាក់ព័ន្ធមិនអាចត្រូវនាំទៅបង្ហាញខ្លួនដល់ចៅក្រមស៊ើបសួរក្រោយពេលចាប់ខ្លួនបានទេបុគ្គលនេះត្រូវតែនាំខ្លួនទៅក្នុងអង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ក្នុងមណ្ឌលឃុំខ្លួន ឬទៅក្នុងពន្ធនាគារ។ បុគ្គលនេះត្រូវតែនាំខ្លួនទៅបង្ហាញខ្លួនយ៉ាងយូរបំផុតថ្ងៃបន្ទាប់ដល់ចៅក្រមស៊ើបសួរ ឬ

---

[94] មាត្រា ១៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។
[95] មាត្រា ១៨៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។
[96] មាត្រា ១៨៨ កថាខណ្ឌទី១ និងកថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។
[97] ឧបសម្ព័ន្ធ ៦
[98] មាត្រា ១៩០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។
[99] មាត្រា ១៩១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។

ដល់អ្នកជំនួសចៅក្រមស៊ើបសួរ។ ប្រសិនបើការបង្ហាញខ្លួនមិនបានប្រព្រឹត្តទៅនៅថ្ងៃបន្ទាប់ទេបុគ្គលពាក់ព័ន្ធត្រូវបានដោះលែងឱ្យមានសេរីភាពវិញ[100] ។ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវជូនដំណឹងដល់ចៅក្រមស៊ើបសួរអំពីការលំបាកក្នុងការអនុវត្តបេសកកម្មរបស់ខ្លួន[101]។ នៅពេលដែលបុគ្គលដែលពាក់ព័ន្ធត្រូវជាប់ពន្ធនាគាររយៈពេលដាក់ពន្ធនាគារត្រូវគិតរួមបញ្ចូលទាំងពេលឃុំខ្លួនខាងលើ។

**១.៣. ដីកាបង្គាប់ឱ្យចាប់ខ្លួន**[102]

ដីកាបង្គាប់ឱ្យចាប់ខ្លួនគឺជាការបញ្ជាដល់កងកម្លាំងសាធារណៈ ឱ្យស្រាវជ្រាវរកចាប់ និងឱ្យនាំខ្លួនបុគ្គលនោះទៅក្នុងពន្ធនាគារ ឬមណ្ឌលឃុំខ្លួនដល់ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនឱ្យទទួល និងឃុំខ្លួនបុគ្គលនោះ[103] ។

ចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឱ្យចាប់ខ្លួនបាន លុះត្រាតែបានបំពេញលក្ខខណ្ឌដូចមានចែងក្នុងមាត្រា១៩៦ និងមាត្រា១៩៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖

- បង្គាប់ឱ្យចាប់ខ្លួនជនត្រូវចោទ ឬបុគ្គលណាដែលមានតម្រុយពិរុទ្ធភាព។
- បទល្មើសដែលចោទប្រកាន់ ជាបទឧក្រិដ្ឋ ឬបទមជ្ឈិមដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ។
- បុគ្គលដែលពាក់ព័ន្ធបានគេចខ្លួន មិនដឹងជាស្ថិតនៅទីកន្លែងណា ឬស្ថិតនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា។
- ចៅក្រមស៊ើបសួរបានទទួលយោបល់ព្រះរាជអាជ្ញាលើបញ្ហាឱ្យចាប់ខ្លួននេះ នៅមុនពេលចេញដីកាបង្គាប់ឱ្យចាប់ខ្លួន ចៅក្រមស៊ើបសួរចេញ ដីកាបញ្ជូនឱ្យឆ្លើយ ដើម្បីឱ្យព្រះរាជអាជ្ញាផ្តល់យោបល់ពីការបង្គាប់ឱ្យចាប់ខ្លួន ប៉ុន្តែយោបល់របស់ព្រះរាជអាជ្ញាពុំមានអានុភាពចងចៅក្រមស៊ើបសួរឱ្យធ្វើតាមនោះទេ។

ព្រះរាជអាជ្ញា ជាអ្នកធានារ៉ាប់រងការផ្សព្វផ្សាយដីកាបង្គាប់ឱ្យចាប់ខ្លួន[104] ហើយមន្ត្រីនគរបាលយុត្តិធម៌ជាអ្នកអនុវត្តដីកាបង្គាប់ឱ្យចាប់ខ្លួន។ មន្ត្រីនគរបាលយុត្តិធម៌ អាចចូលឆែកឆេរនៅក្នុងលំនៅឋានរបស់បុគ្គលពាក់ព័ន្ធបាន ដោយពុំចាំបាច់មានការអនុញ្ញាតឱ្យឆែកឆេរទេ ប៉ុន្តែមន្ត្រីនគរបាលយុត្តិធម៌មិនអាចចូលបានមុនម៉ោង៦ព្រឹក និងក្រោយម៉ោង ១៨ល្ងាចនោះឡើយ ដែលចំណុចនេះខុសប្លែកពីដីកាបង្គាប់ឱ្យនាំខ្លួន។ ដីកាបង្គាប់ឱ្យចាប់ខ្លួនមានតួនាទី៣ គឺស្វែងរក ចាប់ខ្លួន និងឃុំខ្លួន។ ការចេញដីកាបង្គាប់ឱ្យចាប់ខ្លួន គឺចេញទៅលើបុគ្គលដែលរត់គេចខ្លួន ឬក្នុងករណីដែលបុគ្គលនោះរស់នៅប្រទេសក្រៅប្រទេសកម្ពុជា ឬក៏រស់នៅកន្លែងមិនស្គាល់ ក្នុង

[100] មាត្រា ១៩៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។
[101] មាត្រា ១៩២ វាក្យខណ្ឌទី៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។
[102] ឧបសម្ព័ន្ធ
[103] មាត្រា ១៩៦ កថាខណ្ឌទី៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។
[104] មាត្រា ១៩៧ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។

លក្ខខណ្ឌដែលអំពីមានការស៊ើបអង្កេតទោសជាបទឧក្រិដ្ឋ ឬបទមជ្ឈិមដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ។ ដីកាបង្គាប់ឱ្យចាប់ខ្លួន អាចផ្សព្វផ្សាយជាអន្តរជាតិតាមរយៈក្រសួងយុត្តិធម៌បាន ដោយប្រើយន្តការនានាដែលមានប្រសិទ្ធិភាព[105] ។ យោងតាមមាត្រា២០១ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានបញ្ជាក់ថា ជនពាក់ព័ន្ធត្រូវនាំទៅបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរ ឬអ្នកជំនួស នៅក្នុងរយៈពេលយ៉ាងខ្លីបំផុតប្រសិនបើស្ថិតក្នុងដំណាក់កាលស៊ើបសួរនៅឡើយ។ ប្រសិនបើជននេះពុំអាចត្រូវបានគេនាំទៅបង្ហាញខ្លួនដល់ចៅក្រមស៊ើបសួរ ឬអ្នកជំនួសនៅថ្ងៃបន្ទាប់ពីការចាប់ខ្លួនទេនោះព្រះរាជអាជ្ញាដែលមានសមត្ថកិច្ចនៅទីកន្លែងឃុំខ្លួន ស្តាប់ចម្លើយដោយកំណត់ហេតុនៃការស្តាប់ចម្លើយត្រូវបញ្ជូនទៅចៅក្រមស៊ើបសួរ។ ការឃុំខ្លួនដោយសារការអនុវត្តដីកាបង្គាប់ឱ្យចាប់ខ្លួន ត្រូវរាប់បញ្ចូលទៅក្នុងថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នប្រសិនបើមាន[106] ។

**១.៤. ដីកាបង្គាប់ឱ្យឃុំខ្លួន**[107]

ដីកាបង្គាប់ឱ្យឃុំខ្លួន គឺជាបញ្ជាដល់ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនឱ្យទទួល និងឱ្យឃុំខ្លួនជនត្រូវចោទ។ ចៅក្រមស៊ើបសួរ អាចចេញដីកាបង្គាប់ឱ្យឃុំខ្លួនបានលុះត្រាតែជាកម្មវត្ថុនៃដីកាសម្រេចឱ្យឃុំខ្លួនបណ្តោះអាសន្នជាមុនសិន[108] ។ នៅក្នុងដីកាបង្គាប់ឱ្យឃុំខ្លួនត្រូវមានការចុះនិទ្ទេសដូចជា៖

- អត្តសញ្ញាណរបស់ជនត្រូវចោទ
- ប្រភេទនៃបទល្មើសដែលចោទប្រកាន់ អត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើសនេះ
- ឈ្មោះ និងឋានៈរបស់ចៅក្រមដែលចេញដីកា។

ដីកាបង្គាប់ឱ្យឃុំខ្លួនត្រូវមានចុះកាលបរិច្ឆេទ ចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងមានបោះត្រាផងដែរ[109]។ បន្ទាប់ពីតុលាការបានអនុវត្តនីតិវិធីមួយចំនួនដែលមានលក្ខណៈផ្សេងគ្នាទៅតាមស្ថានភាពនីមួយៗដែលចៅក្រមស៊ើបសួរយល់ឃើញថាសមស្រប និងលក្ខខណ្ឌដែលមានចែងក្នុងចំណុចនីមួយៗប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនបុគ្គលដែលមានដីកាបង្គាប់ឱ្យឃុំខ្លួន រហូតទទួលការឱ្យដំណឹងអំពីការដោះលែងឱ្យមានសេរីភាពវិញ[110] ។

ចៅក្រមស៊ើបសួរក៏មានសមត្ថកិច្ចមួយចំនួនទៀតដែលជាហេតុក្នុងការស្វែងរកនូវសច្ចភាព និងភាពយុត្តិធម៌ជូនជនដែលត្រូវបានទទួលនូវការពារដោយច្បាប់ឱ្យបានពិតប្រាកដ។ ក្នុងសមត្ថកិច្ចមានដូចជា ការឃុំខ្លួនបណ្តោះអាសន្ន និងការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការជាដើម។

---

105 មាត្រា ២០០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។

106 មាត្រា ២០២ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។

107 ឧបសម្ព័ន្ធ

108 មាត្រា ២២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។

109 មាត្រា ២២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។

110 មាត្រា ២២២ វាក្យខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។

**២. ការឃុំខ្លួនបណ្ដោះអាសន្ន**[111]

ការឃុំខ្លួនបណ្ដោះអាសន្ន គឺជាវិធានការមួយដែលផ្ដល់អំណាចធំបំផុតទៅឱ្យចៅក្រមស៊ើបសួរ។ តែដោយយោងទៅលើភាពចាំបាច់ ដើម្បីឱ្យការស៊ើបសួរប្រព្រឹត្តទៅបានល្អ ចៅក្រមស៊ើបសួរអាចចេញដីកាឃុំខ្លួនបណ្ដោះអាសន្នបាន។

ក្រោយពីជនត្រូវចោទត្រូវបានចៅក្រមស៊ើបសួរដាក់នៅស្ថិតនៅក្រោមការត្រួតពិនិត្យពីបទល្មើសណាមួយ ហើយចៅក្រមស៊ើបសួរពិចារណាទៅលើបញ្ហាឃុំខ្លួនជននេះជាបណ្ដោះអាសន្ន ឬអត់។ អនុលោមតាមមាត្រា ២០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានលើកឡើងពីគោលការណ៍នៃសេរីភាពរបស់ជនត្រូវចោទ មានន័យថាការឃុំខ្លួនជនត្រូវចោទបណ្ដោះអាសន្ន ត្រូវតែជាករណីពិសេស។ ការឃុំខ្លួនបណ្ដោះអាសន្នអាចអនុវត្តបានតែក្នុងករណីចោទប្រកាន់ពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ដែលច្បាប់កំណត់ផ្ដន្ទាទោសដាក់ពន្ធនាគារស្មើ ឬលើសពី១ឆ្នាំ[112]។

**២.១. លក្ខខណ្ឌ និងមូលហេតុការឃុំខ្លួនបណ្ដោះអាសន្ន**

ជាទូទៅសេរីភាពជនត្រូវចោទជាគោលការណ៍ ហេតុនេះការឃុំខ្លួនជនត្រូវចោទបណ្ដោះអាសន្នត្រូវតែជាករណីលើកលែងហេតុនេះហើយការឃុំខ្លួនបណ្ដោះអាសន្នអាចធ្វើទៅបានលុះត្រាតែគោរពទៅតាមលក្ខខណ្ឌ និងមូលហេតុដូចកំណត់ក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ពោលគឺ៖

- ជនត្រូវចោទ ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋ ឬមជ្ឈិមដែលច្បាប់បានកំណត់ផ្ដន្ទាទោសដាក់ពន្ធនាគារស្មើ ឬលើសពី១ឆ្នាំ[113] ហេតុនេះ ប្រសិនបើជនត្រូវចោទជាប់ចោទពីបទល្មើសប្រើប្រាស់គ្រឿងញៀនតាមមាត្រា ៩៨ថ្មី នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀនដែលផ្ដន្ទាទោសដាក់ពន្ធនាគារពី ៧ថ្ងៃ រហូតដល់ ១ខែ ជនត្រូវចោទនេះពុំអាចត្រូវឃុំខ្លួនបណ្ដោះអាសន្នដោយចៅក្រមស៊ើបសួរបានឡើយ។
- មូលហេតុចំនួន៦ នៃការឃុំខ្លួនជនត្រូវចោទបណ្ដោះអាសន្នរួមមាន៖

ក- ដើម្បីបញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឱ្យកើតជាថ្មី

ខ- ដើម្បីរារាំងកុំឱ្យមានការគាបសង្កត់លើសាក្សី ឬជនរងគ្រោះ ឬដើម្បីរារាំងកុំឱ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិត

គ- ដើម្បីរក្សាភស្តុតាង និងតម្រុយជាសម្ភារៈ

ឃ- ដើម្បីធានារក្សាជនត្រូវចោទទុកជូនតុលាការចាត់ការតាមនីតិវិធី

ង- ដើម្បីការពារសន្តិសុខឱ្យជនត្រូវចោទ និង

ច- ដើម្បីធានារក្សាសណ្ដាប់ធ្នាប់សាធារណៈកុំឱ្យមានការច្របូកច្របល់ដែលបណ្ដាលមកពីបទល្មើស។

---

[111] ឧបសម្ព័ន្ធ

[112] មាត្រា ២០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។

[113] មាត្រា ២០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។

នៅក្នុងការពិភាក្សាដេញដោលពីបញ្ហាឃុំខ្លួន ចៅក្រមស៊ើបសួរ ឱ្យក្រឡាបញ្ជីធ្វើកំណត់ហេតុមួយឈ្មោះថា កំណត់ហេតុស្តីពីការពិភាក្សាដេញដោលចំពោះមុខ ក្នុងគោលដៅឱ្យព្រះរាជអាជ្ញាធ្វើសេចក្តីសន្និដ្ឋានពីបញ្ហាឃុំខ្លួនជនត្រូវចោទ និងមេធាវីការពារជនត្រូវចោទ ផ្តល់ការកត់សម្គាល់ ឬសេចក្តីសន្និដ្ឋានពីបញ្ហាឃុំខ្លួន ដល់ចៅក្រមស៊ើបសួរ ដែលជាមូលហេតុឱ្យចៅក្រមស៊ើបសួរសម្រេចថា គួរឃុំខ្លួន ឬមិនឃុំខ្លួនជនត្រូវចោទ[114] ។

**២.២. ដីកាសម្រេចមិនឃុំខ្លួនបណ្តោះអាសន្ន**

ដីកាសម្រេចមិនឃុំខ្លួនបណ្តោះអាសន្ន ក្នុងករណីប្រសិនបើចៅក្រមស៊ើបសួរសម្រេចមិនឃុំខ្លួនជនត្រូវចោទជាបណ្តោះអាសន្ន ចៅក្រមស៊ើបសួរពុំចាំបាច់ចេញដីកាសម្រេចអ្វីនោះទេ គឺចៅក្រមស៊ើបសួរអនុញ្ញាតឱ្យជនត្រូវចោទត្រឡប់ទៅវិញ ក្រោយពីការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ ឬក្រោយពីការសួរចម្លើយរួចហើយ។ ប៉ុន្តែប្រសិនបើព្រះរាជអាជ្ញាបានស្នើសុំឱ្យចៅក្រមស៊ើបសួរឃុំខ្លួនជនត្រូវចោទបណ្តោះអាសន្ន (ការស្នើសុំដោយផ្ទាល់មាត់នៅពេលដែលមានការពិភាក្សាដេញដោលពីបញ្ហាឃុំខ្លួន ឬធ្វើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ) ហើយចៅក្រមស៊ើបសួរយល់ឃើញថាពុំត្រូវឃុំខ្លួនជនត្រូវចោទទេនោះ ចៅក្រមស៊ើបសួរត្រូវចេញ ដីកាសម្រេចមិនឃុំខ្លួនបណ្តោះអាសន្ន ដោយពុំចាំបាច់មានសម្អាងហេតុទេ[115] ។ ដីកានេះត្រូវឱ្យដល់ភ្លាមដល់ព្រះរាជអាជ្ញា ហើយប្រសិនបើចៅក្រមស៊ើបសួរពុំបានចេញដីកាសម្រេចនេះក្នុងរយៈពេល ៥ថ្ងៃ ទេនោះ ព្រះរាជអាជ្ញាអាចប្តឹងផ្ទាល់ទៅសភាស៊ើបសួរឱ្យសម្រេចជំនួសចៅក្រមស៊ើបសួរបាន[116] ។

**២.៣. ចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន**

ចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ចៅក្រមស៊ើបសួរសម្រេចអំពី ការឃុំខ្លួនជនត្រូវចោទជាបណ្តោះអាសន្ន ការឃុំខ្លួនជាបណ្តោះអាសន្ននេះត្រូវស្ថិតនៅក្នុងចិរវេលាដែលកំណត់ដោយច្បាប់។ ចិរវេលានេះប្រែប្រួលទៅតាមប្រភេទនៃបទល្មើសចោទប្រកាន់ និងអាយុរបស់ជនត្រូវចោទឃុំខ្លួន។

- ប្រសិនបើជាប់ចោទពីបទល្មើសឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ឬបទឧក្រិដ្ឋសង្គ្រាម ការឃុំខ្លួនមិនអាចលើសពី ១ឆ្នាំបានទេ ចំពោះបទល្មើសនីមួយៗ។ ប៉ុន្តែនៅពេលផុតចិរវេលានេះ ចៅក្រមស៊ើបសួរអាចពន្យារពេលឃុំខ្លួនបណ្តោះអាសន្នបាន ១ឆ្នាំ ដោយដីកាមានសំអាងហេតុ ហើយការពន្យារពេលនេះអាចធ្វើបានតែពីរដងគត់ប៉ុណ្ណោះ[117] ។

- ប្រសិនបើជាប់ចោទពីបទឧក្រិដ្ឋផ្សេងទៀតៈ

  • ជនត្រូវចោទជានីតិជន រយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្នគឺ ៦ខែ ហើយអាចពន្យាពេលបាន ៦ខែទៀត ចំនួន ២ដង (មាត្រា ២០៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

[114] មាត្រា ២០៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។
[115] មាត្រា ២០៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។
[116] មាត្រា ២០៧ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។
[117] មាត្រា ២១០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។

- ជនត្រូវចោទជាអនីតិជនដែលមានអាយុចាប់ពី ១៤ឆ្នាំ រហូតដល់ក្រោម ១៦ឆ្នាំ រយៈពេលនៃការឃុំខ្លួនបណ្ដោះអាសន្ន មិនអាចលើសពី ៤ខែ បានទេ (មាត្រា ២១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។
- ជនត្រូវចោទជាអនីតិជនដែលមានអាយុចាប់ពី ១៦ឆ្នាំ រហូតដល់ក្រោម ១៨ឆ្នាំ រយៈពេលនៃការឃុំខ្លួនបណ្ដោះអាសន្ន មិនអាចលើសពី ៦ខែ បានទេ (មាត្រា ២១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

- ប្រសិនបើជាប់ទោសពីបទមជ្ឈិមៈ

- ជនត្រូវចោទជានីតិជន រយៈពេលនៃការឃុំខ្លួនបណ្ដោះអាសន្នគឺ ៤ខែ ហើយអាចពន្យារពេលបាន ២ ខែទៀត ដែលការពន្យារពេលនេះអាចបានតែម្ដងគត់ ហើយទោះជាយ៉ាងណាក៏ដោយ រយៈពេលនៃការឃុំខ្លួនបណ្ដោះអាសន្ននេះ ពុំអាចលើសពីពាក់កណ្ដាលនៃអប្បបរមានៃទោសដែលច្បាប់បានកំណត់ទុកដែរ (មាត្រា ២០៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។
- ជនត្រូវចោទជាអនីតិជនដែលមានអាយុចាប់ពី ១៤ឆ្នាំ ដល់ក្រោម ១៦ឆ្នាំ រយៈពេលនៃការឃុំខ្លួនបណ្ដោះអាសន្ន មិនអាចលើសពី ២ខែបានទេ (មាត្រា ២១៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ) ហើយទោះជាយ៉ាងណារយៈពេលនៃការឃុំខ្លួនបណ្ដោះអាសន្ន មិនអាចលើសពីពាក់កណ្ដាលនៃអប្បបរមានៃទោសដែលច្បាប់បានកំណត់ឡើយ។
- ជនត្រូវចោទជាអនីតិជនដែលមានអាយុចាប់ពី ១៦ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ រយៈពេលនៃការឃុំខ្លួនបណ្ដោះអាសន្ន មិនអាចលើសពី ៤ខែបានទេ (មាត្រា ២១៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ) ហើយទោះជាយ៉ាងណារយៈពេលនៃការឃុំខ្លួនបណ្ដោះអាសន្ន មិនអាចលើសពីពាក់កណ្ដាលនៃអប្បបរមានៃទោសដែលច្បាប់បានកំណត់ឡើយ។

# គំនូសបំព្រួញនៃការឃុំខ្លួនបណ្ដោះអាសន្ន

**ការចាប់ខ្លួន / ការឃាត់ខ្លួន / ការបង្គាប់ឱ្យចូលខ្លួន**

↓

ការបដិសេធមិនឃុំខ្លួន → ព្រះរាជអាជ្ញាអាចប្ដឹងទៅសភាស៊ើបសួរ ( មាត្រា ២០៧ ) នៃក្រមនីតិវិធីព្រហ្មទណ្ឌ

↓

ការបដិសេធមិនឱ្យនៅក្រៅឃុំ → ជនត្រូវចោទអាចនឹងតវ៉ាទៅសភាស៊ើបសួរ ( មាត្រា ២១៧ ) នៃក្រមនីតិវិធីព្រហ្មទណ្ឌ

↓

ការឃុំខ្លួនមិនត្រូវលើសពី៖ ៦ខែ ចំពោះបទឧក្រិដ្ឋ → ត្រូវដោះលែងជនត្រូវចោទប្រសិនបើការឃុំខ្លួនលើសពី ៦ខែ

↓

រក្សាជនត្រូវចោទក្នុងឃុំរហូតដល់ បង្ហាញខ្លួនចំពោះមុខតុលាការ ( យ៉ាងយូរបំផុត ៤ខែ )

↓

ជំនុំជម្រះ

**<u>អនីតិជន</u> ៖**

- អាយុតិចជាង ១៤ឆ្នាំ មិនត្រូវជាប់ឃុំបណ្ដោះអាសន្នទេ ( មាត្រា២១២ ) នៃក្រមនីតិវិធីព្រហ្មទណ្ឌ

***ចំពោះបទឧក្រិដ្ឋ*** មាត្រា ( ២១៣ ) នៃក្រមនីតិវិធីព្រហ្មទណ្ឌ

-មិនលើសពី ៤ខែ ទេអាយុចាប់ពី ១៤ឆ្នាំ ដល់ ក្រោម ១៦ឆ្នាំ

-មិនលើសពី ៤ខែ ទេអាយុចាប់ពី ១៦ឆ្នាំ ដល់ ក្រោម ១៨ឆ្នាំ

***ចំពោះបទបដ្ឋិម*** ( មាត្រា ២១៤ ) នៃក្រមនីតិវិធីព្រហ្មទណ្ឌ

-មិនលើសពី ២ខែ ទេអាយុចាប់ពី ១៤ឆ្នាំ ដល់ ក្រោម ១៦ឆ្នាំ

-មិនលើសពី ៤ខែ ទេអាយុចាប់ពី ១៦ឆ្នាំ ដល់ ក្រោម ១៨ឆ្នាំ ( មិនត្រូវលើសពី ៥០% នៃអប្បរមានៃទោសសម្រាប់នីតិជនឡើយ ) ។

**<u>នីតិជន</u> ៖**

-***ចំពោះបទឧក្រិដ្ឋ៖*** អាចពន្យាការឃុំខ្លួនបណ្ដោះអាសន្ន ៦ខែ ហើយបានពីដង ( មាត្រា ២០៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ )

-***ចំពោះបទមជ្ឈឹម៖*** អាចពន្យាការឃុំខ្លួនបណ្ដោះអាសន្ន ២ខែ ទៀត តែមិនត្រូវលើសពីពាក់កណ្ដាល នៃអប្បបរិមានៃទោស ( មាត្រា ២០៩ ) នៃក្រមនីតិវិធីព្រហ្មទណ្ឌ

-***ចំពោះបទប្រឆាំងមនុស្សជាតិ*** មិនអាចឃុំខ្លួនបណ្ដោះអាសន្នលើស ១ឆ្នាំ បានតែអាចពន្យាការឃុំខ្លួនបណ្ដោះអាសន្នមួយដងបាន ១ឆ្នាំ បានពីរដង

**២.៤. ការដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំ**

ក្នុងករណីដែលជនត្រូវចោទជាប់ឃុំបណ្ដោះអាសន្ន ក្រមនីតិវិធីព្រហ្មទណ្ឌបានចែងពីការដោះលែងឱ្យនៅក្រៅឃុំវិញបានតាមវិធីបីយ៉ាងដូចខាងក្រោម៖

**២.៤.១. ការដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំដោយចៅក្រមស៊ើបសួរ**

តាមគំនិតផ្ដួចផ្ដើមរបស់ចៅក្រមស៊ើបសួរ ក្នុងករណីនេះចៅក្រមស៊ើបសួរចេញ ដីកាបញ្ជូនឱ្យឆ្លើយដើម្បីសុំយោបល់ពីព្រះរាជអាជ្ញា ទាក់ទិននឹងបំណងរបស់ចៅក្រមស៊ើបសួរក្នុងការដោះលែងជនត្រូវចោទឱ្យមានសេរីភាពវិញ។ ព្រះរាជអាជ្ញាត្រូវផ្ដល់យោបល់ក្នុងរយៈពេល ៥ថ្ងៃ បន្ទាប់ពីការបញ្ជូនសំណុំរឿងមកខ្លួន។ ជាទូទៅចៅក្រមស៊ើបសួរអាចបង្គាប់ឱ្យដោះលែងភ្លាមដោយចង្អុលប្រាប់ពីមូលហេតុនៃការបន្ទាន់នេះនៅក្នុង ដីកាសម្រេចដោះលែងឱ្យនៅក្រៅឃុំ របស់ខ្លួន (មាត្រា ២១៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

ឧទាហរណ៍៖ ជនត្រូវចោទត្រូវការបញ្ជូនទៅព្យាបាលនៅមន្ទីរពេទ្យដែលនៅក្រៅតំបន់ ឬឆ្លងខេត្តជាបន្ទាន់ដោយមិនអាចរងចាំបានផ្អែកលើស្ថានភាពជម្ងឺធ្ងន់ធ្ងររបស់ជនត្រូវចោទ ហើយពុំអាចព្យាបាលនៅក្នុងតំបន់ ឬក្នុងខេត្តបាន។

**២.៤.២. ការដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំតាមបណ្ដឹងរបស់ព្រះរាជអាជ្ញា**

តាមគំនិតផ្ដួចផ្ដើមរបស់ព្រះរាជអាជ្ញា (មាត្រា ២១៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ) ព្រះរាជអាជ្ញាធ្វើសេចក្ដីសន្និដ្ឋានសុំឱ្យដោះលែងជនត្រូវចោទ បញ្ជូនទៅចៅក្រមស៊ើបសួរ ហើយចៅក្រមស៊ើបសួរត្រូវសម្រេចសេចក្ដីក្នុងរយៈពេល ៥ថ្ងៃ ថាយល់ព្រមតាមការស្នើសុំរបស់ព្រះរាជអាជ្ញា ដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំ ឬមិនព្រមដោះលែងឱ្យនៅក្រៅឃុំ។ ប្រសិនបើចៅក្រមស៊ើបសួរពុំបានសម្រេចក្នុងរយៈពេលកំណត់នេះទេ នាំឱ្យព្រះរាជអាជ្ញាអាចប្ដឹងទៅសភាស៊ើបសួរ ដើម្បីសម្រេចជំនួសបាន។ ចៅក្រមស៊ើបសួរអាចចេញ៖ ដីកាសម្រេចដោះលែងឱ្យនៅក្រៅឃុំ ឬដីកាសម្រេចមិនព្រមដោះលែងឱ្យនៅក្រៅឃុំ ប៉ុន្តែប្រសិនបើចៅក្រមស៊ើបសួរចេញដីកាសម្រេចមិនព្រមដោះលែងឱ្យនៅក្រៅឃុំ ចៅក្រមស៊ើបសួរត្រូវបញ្ជាក់អំពីសំអាងហេតុឱ្យបានច្បាស់លាស់នៅក្នុងដីកាសម្រេចនោះ។

**២.៤.៣. ការដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំ តាមបណ្ដឹងរបស់ជនត្រូវចោទ**

តាមពាក្យសុំឱ្យដោះលែងឱ្យនៅក្រៅឃុំរបស់ជនត្រូវចោទ ឬមេធាវីរបស់ជនត្រូវចោទ (មាត្រា ២១៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ) ក្នុងករណីដែលទទួលបានពាក្យសុំនេះ ចៅក្រមស៊ើបសួរត្រូវបញ្ជូនពាក្យសុំនេះទៅព្រះរាជអាជ្ញាភ្លាម ដើម្បីសុំយោបល់ និងបញ្ជូនសំណុំរឿងឱ្យព្រះរាជអាជ្ញាពិនិត្យ និងផ្ដល់យោបល់ក្នុងរយៈពេលខ្លីបំផុត។ ចៅក្រមស៊ើបសួរត្រូវសម្រេចថាដោះលែង ឬមិនដោះលែងក្នុងរយៈពេល ៥ថ្ងៃ បន្ទាប់ពីពេលបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា។ ប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេល ៥ថ្ងៃនេះទេ ជនត្រូវចោទអាចប្ដឹងទៅសភាស៊ើបសួរឱ្យសម្រេចជំនួសបាន។ នៅពេលដែលចៅក្រមស៊ើបសួរចេញ ដីកាសម្រេចដោះលែងឱ្យនៅ

ក្រៅឃុំ ចៅក្រមស៊ើបសួរត្រូវជូនដំណឹងភ្លាមដល់ព្រះរាជអាជ្ញា និងដល់ប្រធានពន្ធនាគារ (មាត្រា ២១៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។ គួរកត់សម្គាល់ផងដែរថា ប្រសិនបើចៅក្រមស៊ើបសួរបានចេញដីកាសម្រេចមិនព្រមដោះលែងឱ្យនៅក្រៅឃុំម្តងហើយនោះ ជនត្រូវក៏អាចដាក់ពាក្យសុំឱ្យដោះលែងឱ្យនៅក្រៅឃុំសាជាថ្មីម្តងទៀតបានដែរក្នុងរយៈពេល ១ខែ បន្ទាប់ពីមានសេចក្តីសម្រេចមុន។

ទោះបីជាមានសេចក្តីសម្រេចរបស់ចៅក្រមស៊ើបសួរឱ្យដោះលែងក៏ដោយ ក៏ជនត្រូវចោទនៅមិនទាន់អាចត្រូវបានដោះលែងឱ្យ នៅក្រៅឃុំភ្លាមបានដែរ គឺគេត្រូវរក្សាជនត្រូវចោទទុកនៅក្នុងពន្ធនាគាររហូតដល់ផុតរយៈពេលសម្រាប់បណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា ៥ថ្ងៃ លើកលែងតែព្រះរាជអាជ្ញាបានយល់ព្រមជាលាយលក្ខណ៍អក្សរឱ្យដោះលែងជនត្រូវចោទភ្លាម (មាត្រា ២៧៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។ ហើយប្រសិនបើព្រះរាជអាជ្ញាប្តឹងឧទ្ធរណ៍លើដីកាសម្រេចដោះលែងឱ្យនៅក្រៅឃុំ ជនត្រូវចោទត្រូវរក្សាទុកក្នុងពន្ធនាគាររហូតដល់មានសេចក្តីសម្រេចពីសភាស៊ើបសួរ លើបណ្តឹងឧទ្ធរណ៍នេះ (មាត្រា ២៧៦ កថាខណ្ឌទី៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

ក្នុងរឿងឃុំខ្លួនបណ្តោះអាសន្ន សភាស៊ើបសួរត្រូវសម្រេចចេញសាលដីការបស់ខ្លួនក្នុងរយៈពេល១៥ថ្ងៃ បន្ទាប់ពីបានទទួលសំណុំរឿងនៅការិយាល័យសភាស៊ើបសួរ (មាត្រា ២៧៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។ ក្នុងករណីប្រសិនបើផុតកំណត់រយៈពេល ជនត្រូវចោទត្រូវបានដោះលែងឱ្យនៅក្រៅឃុំ លើកលែងតែក្នុងករណីដែលមានចេញបង្គាប់ឱ្យធ្វើការផ្ទៀងផ្ទាត់ ឬក្នុងករណីកាលៈទេសៈដែលមិនអាចមើលឃើញជាមុន ឬមិនអាចជំនះបានបង្កជាឧបសគ្គមិនឱ្យប្រកាសសាលដីកាបាននៅក្នុងរយៈពេលនេះ។ កាលណាសភាស៊ើបសួរសម្រេចឱ្យឃុំខ្លួនបណ្តោះអាសន្ន សភាស៊ើបសួរត្រូវចេញដីកាបង្គាប់ឱ្យឃុំខ្លួន និងមានសំអាងហេតុនៅក្នុងសាលដីការបស់ខ្លួន។

### ៣. ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការ

ចៅក្រមស៊ើបសួរត្រូវតែដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យនូវបុគ្គលដែលមានចង្អុលប្រាប់ឈ្មោះ នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ ចៅក្រមស៊ើបសួរមានអំណាចដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យនូវបុគ្គលគ្រប់រូបដែលមានតម្រុយច្បាស់លាស់ ហើយស៊ីសង្វាក់គ្នាយ៉ាងខ្លាំងថា បានចូលរួមប្រព្រឹត្តបទល្មើស ទោះបីជាគ្មានការចង្អុលប្រាប់ឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរក៏ដោយ។ ចៅក្រមស៊ើបសួរអាចដាក់បុគ្គលនោះឱ្យស្ថិតនៅក្រោមការពិនិត្យក្នុងឋានៈ ជាចារី សហចារី អ្នកផ្តើមគំនិត ឬជាអ្នកសមគំនិត[118] ។

#### ៣.១. បុគ្គលដែលអាចត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ

ចៅក្រមស៊ើបសួរ គឺជាអ្នកវាយតម្លៃអំពីកាលានុវត្តភាពនៃការជូនដំណឹងពីការដាក់ឱ្យស្ថិតក្រោមការពិនិត្យជាយថាហេតុ បន្ទាប់ពីបានធ្វើការស៊ើបសួរចាំបាច់ផ្សេងៗរួចមក។

[118] មាត្រា ១២៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។

ការប៉ុនប៉ងអាចទាំងចំពោះចៅក្រម និងមន្ត្រីនគរបាលយុត្តិធម៌ដែលអនុវត្តដីកាចាត់ឱ្យស៊ើបសួរ ក្នុងការបន្តការស្តាប់ចម្លើយក្នុងឋានៈជាសាក្សីនូវបុគ្គលដែលមានតម្រុយពិរុទ្ធភាពធ្ងន់ធ្ងរ និងស៊ីសង្វាក់គ្នាក្នុងគោលដៅពន្យារពេលការទទួលជំនួយពីមេធាវី និងដើម្បីទទួលភស្តុតាងដាក់បន្ទុក។ នៅក្នុងមាត្រា ១៥៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចែងពីគោលការណ៍ ដើម្បីគោរពសិទ្ធិការពារខ្លួន ចៅក្រមស៊ើបសួរមិនអាចស្តាប់ក្នុងឋានៈជាសាក្សីនូវបុគ្គលណាដែលមានតម្រុយពិរុទ្ធភាពនោះទេ។

លើសពីនេះ បុគ្គលដែលមានចង្អុលប្រាប់ឈ្មោះក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញាអាចត្រូវស្តាប់ដោយចៅក្រមស៊ើបសួរ ក្នុងឋានៈជាជនត្រូវចោទប៉ុណ្ណោះ ចៅក្រមមានកាតព្វកិច្ចដាក់ឱ្យស្ថិតក្រោមការពិនិត្យនូវបុគ្គលនោះ។

ទោះជាអត្ថបទច្បាប់មិនបានចែងពីផលវិបាកនៃការបំពានគោលកាណ៍ដែលមានក្នុងមាត្រា ១៥៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ក៏ដោយការមិនគោរព នឹងអាចបណ្តាលឱ្យមានមោឃភាពដោយមូលហេតុសណ្តាប់ធ្នាប់សាធារណៈ ដែលគ្របដណ្តប់ទៅលើគ្រប់កិច្ចទាំងអស់ដែលបានបំពេញចាប់តាំងពីពេលដែលជនសង្ស័យត្រូវចោទប្រកាន់។ មោឃភាពដោយសារតែការចោទប្រកាន់យឺត ទាក់ទងតែបុគ្គលដែលត្រូវបានសួរចម្លើយដោយខុសច្បាប់ប៉ុណ្ណោះហើយវាមិនទាក់ទងនឹងជនត្រូវចោទជាមួយគ្នានោះទេ។

### ៣.២. បែបបទនៃការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ

ការដាក់ឱ្យស្ថិតក្រោមការពិនិត្យធ្វើឡើងនៅពេលដែលជនពាក់ព័ន្ធ ចូលបង្ហាញខ្លួនដំបូងនៅចំពោះមុខចៅក្រមស៊ើបសួរ ហើយបែបបទនៃការដាក់ឱ្យស្ថិតក្រោមការពិនិត្យ។ ចៅក្រមស៊ើបសួរត្រូវពិនិត្យអត្តសញ្ញាណរបស់បុគ្គលពាក់ព័ន្ធ និងប្រាប់គាត់ឱ្យបានច្បាស់លាស់អំពីរឿងរ៉ាវដែលចោទប្រកាន់ព្រមទាំងឈ្មោះបទល្មើសតាមច្បាប់។ និទ្ទេសនៃរឿងរ៉ាវ និងឈ្មោះបទល្មើសត្រូវបានចុះក្នុងកំណត់ហេតុ។ ម្យ៉ាងទៀតចៅក្រមស៊ើបសួរត្រូវប្រាប់ជនត្រូវចោទថាគាត់មានសេរីភាពមិនឆ្លើយ។ ការឱ្យដំណឹងនេះក៏ត្រូវមានចុះនិទ្ទេសក្នុងកំណត់ហេតុដែរ។ ជនត្រូវចោទត្រូវទទួលដំណឹងពីសិទ្ធិទទួលជំនួយពីមេធាវីដែលជ្រើសរើសដោយខ្លួនឯងផ្ទាល់ ឬមេធាវីចាត់តាំងដោយការស្នើសុំទៅគណៈប្រតិភូមេធាវីដែលប្រចាំការនៅតាមសាលាដំបូងរាជធានី/ខេត្ត និងសាលាឧទ្ធរណ៍។ គួរបញ្ជាក់ថាបើជនត្រូវចោទជាអនីតិជន ត្រូវតម្រូវឱ្យមានមេធាវីអមនៅគ្រប់ដំណាក់កាលជាដាច់ខាត។

បើជនត្រូវចោទយល់ព្រមផ្តល់ចម្លើយចៅក្រមស៊ើបសួរត្រូវទទួលចម្លើយទាំងនេះភ្លាម។ ក្នុងករណីចាំបាច់ចៅក្រមស៊ើបសួរអាចហៅអ្នកបកប្រែ មកដើម្បីជំនួយក្នុងការស៊ើបសួរ។ អ្នកបកប្រែតម្រូវឱ្យស្បថតាមសាសនា ឬជំនឿរបស់ខ្លួនថាខ្លួននឹងជួយដល់តុលាការ និងបកប្រែឱ្យបានត្រឹមត្រូវតាមចម្លើយទាំងឡាយ។ ក្នុងករណីណា

ក៏ដោយ អ្នកបកប្រែមិនអាចត្រូវជ្រើសរើសក្នុងចំណោម ចៅក្រម ក្រឡាបញ្ជី នគរបាល កងរាជអាវុធហត្ថ ភាគី ឬ សាក្សីទេ[119] ។

### ៣.៣. អានុភាពនៃការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ

ជនត្រូវចោទក្លាយជាភាគីនៃសំណុំរឿងព្រហ្មទណ្ឌ។ សិទ្ធិរបស់គាត់មានសិទ្ធិការពារខ្លួនដែលស្តែងឡើង ដោយសិទ្ធិទទួលជំនួយពីមេធាវី សិទ្ធិចូលរួមក្នុងការការពារខ្លួនដោយឆ្លើយ ឬមិនឆ្លើយ សិទ្ធិត្រូវបានស្តាប់ដោយ ចៅក្រម និងមិនមែនដោយមន្ត្រីនគរបាលយុត្តិធម៌សិទ្ធិទទួលព័ត៌មានពីសកម្មភាពខាងផ្នែកតុលាការរបស់ចៅក្រម (ការជូនដំណឹងពីដីការបស់តុលាការអនុញ្ញាតឱ្យជនត្រូវចោទប្តឹងឧទ្ធរណ៍សិទ្ធិសុំមោឃភាពនីតិវិធី សិទ្ធិចូល រួម) យ៉ាងសកម្មក្នុងដំណើរការស៊ើបសួរដែលសុំទៅចៅក្រមឱ្យធ្វើការស្រាវជ្រាវមួយចំនួន។ ជាអាទិ៍ជនត្រូវចោទ អាច សុំឱ្យចៅក្រមស៊ើបសួរធ្វើការសួរចម្លើយខ្លួន ស្តាប់ចម្លើយភាគីដើមបណ្តឹងរដ្ឋប្បវេណី ឬសាក្សី ធ្វើការសួរ ចម្លើយតទល់ ឬចុះទៅទីកន្លែង (មាត្រា ១២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ )។ ការស្នើសុំនេះ ត្រូវធ្វើជាលាយលក្ខណ៍ អក្សរ និងត្រូវមានសំអាងហេតុដែលអនុញ្ញាតឱ្យបញ្ជាក់ពីប្រយោជន៍របស់វា។ គួរកត់ចំណាំថា ក្រមនីតិវិធីព្រហ្ម ទណ្ឌបានកំណត់ពីកិច្ចដែលអាចស្នើសុំបានដោយ ជនត្រូវចោទបើប្រៀបធៀបទៅ នឹងព្រះរាជអាជ្ញាដែលអាចស្នើ សុំឱ្យ ចៅក្រមស៊ើបសួរធ្វើគ្រប់កិច្ចស៊ើបសួរដែលគាត់គិតថាមានប្រយោជន៍។ បើចៅក្រមបដិសេធសំណើសុំនេះ គាត់ត្រូវចេញដីកាបដិសេធដោយមានសំអាងហេតុ ក្នុងចិរវេលាមួយខែបន្ទាប់ពីពេលទទួលពាក្យសុំ។ ដីកានេះត្រូវ ជូនដំណឹងដល់ព្រះរាជអាជ្ញា និងជនត្រូវចោទក្នុងរយៈពេលយ៉ាងខ្លីបំផុត។ បើចៅក្រមស៊ើបសួរមិនសម្រេចក្នុងរយៈ ពេលមួយខែ ជនត្រូវចោទប្រើបណ្តឹងសុំ អាចប្តឹងដោយផ្ទាល់ទៅសភាស៊ើបសួរដែលត្រូវសម្រេចជំនួសចៅក្រម ស៊ើបសួរ។

ម្យ៉ាងទៀត ជនត្រូវចោទអាចប្តឹងឧទ្ធរណ៍ពីដីកាមួយចំនួនរបស់ចៅក្រមស៊ើបសួរដែលបានកំណត់ក្នុង ជាអាទិ៍សិទ្ធិនេះសំដៅតែទៅលើដីកាដែលទាក់ទងនឹងការឃុំខ្លួន បណ្តោះអាសន្ន ការត្រួតពិនិត្យតាមផ្លូវតុលាការ ដីកាដែលបដិសេធពាក្យសុំធ្វើកិច្ចស៊ើបសួរ និងដីកាបដិសេធការប្រគល់វត្ថុដែលចាប់យក[120] ។

ជាចុងក្រោយ កាលណាចិរវេលា ៤ខែបានកន្លងផុតទៅចាប់ពីពេលចូលមកបង្ហាញខ្លួនដំបូង ជនត្រូវចោទ មិនត្រូវបានសួរចម្លើយឬសួរតទល់ទេ ចៅក្រមស៊ើបសួរត្រូវតែទទួលចម្លើយ ប្រសិនបើជនត្រូវចោទបានស្នើសុំ។ ក្នុង ករណីដែលចៅក្រមស៊ើបសួរ មិនព្រមកោះហៅជនត្រូវចោទក្នុងចិរវេលាមួយខែបន្ទាប់ពីការសុំជនត្រូវចោទអាច ប្តឹងដោយផ្ទាល់ទៅសភាស៊ើបសួរដែលទទួលចម្លើយនេះដោយខ្លួនឯងផ្ទាល់។ បន្ទាប់មកកំណត់ហេតុដែលជន ត្រូវចោទបានឆ្លើយរួចហើយ ត្រូវបញ្ជូនទៅចៅក្រមស៊ើបសួរ។

---

[119] មាត្រា ១៤៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។

[120] មាត្រា ២៦៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។

## ផ្នែកទី ៣ ៖ អំណាចការស្រាវជ្រាវតាមការស្នើសុំ

### កថាខណ្ឌទី១ ៖ ការស្នើសុំឱ្យបំពេញកិច្ចដោយព្រះរាជអាជ្ញា

នៅក្នុងដំណាក់កាលស៊ើបសួរព្រះរាជអាជ្ញាអាចសុំឱ្យចៅក្រមស៊ើបសួរធ្វើកិច្ចស៊ើបសួរណាមួយ ដែលខ្លួនយល់ឃើញថាមានប្រយោជន៍សម្រាប់រឿងក្ដីទាំងមូល ព្រោះចៅក្រមស៊ើបសួរជាអ្នកស្រាវជ្រាវរកភស្តុតាងបន្ថែមទាំងភស្តុតាងដោះបន្ទុក និងភស្តុតាងដាក់បន្ទុក ដើម្បីរកយុត្តិធម៌សម្រាប់ដើម្បីបណ្ដឹងរដ្ឋប្បវេណី និងជនដែលត្រូវបានចោទប្រកាន់។ ប្រសិនបើចៅក្រមស៊ើបសួរមិនព្រមធ្វើតាមការស្នើសុំរបស់ព្រះរាជអាជ្ញាទេ ចៅក្រមស៊ើបសួរត្រូវចេញដីកាបដិសេធជាលាយលក្ខណ៍អក្សរនៅក្នុងរយៈពេល ១៥ថ្ងៃ ដោយមានសម្អាងហេតុ ហើយត្រូវជូនដំណឹងទៅព្រះរាជអាជ្ញាក្នុងចិរវេលាយ៉ាងឆាប់បំផុតតាមដែលអាចធ្វើទៅបាន។

ក្នុងករណីដែលព្រះរាជអាជ្ញាមិនសុខចិត្តនឹងការសម្រេចរបស់ចៅក្រមស៊ើបសួរ ព្រះរាជអាជ្ញាអាចប្ដឹងទៅសភាស៊ើបសួរបាន។ ប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេល ១៥ថ្ងៃទេ ព្រះរាជអាជ្ញាអាចប្ដឹងដោយផ្ទាល់តាមរយៈពាក្យសុំ ទៅសភាស៊ើបសួរបានដែលជាអ្នកសម្រេចជំនួសចៅក្រមស៊ើបសួរ[121] ។

### កថាខណ្ឌទី២៖ ការស្នើសុំឱ្យបំពេញកិច្ចដោយជនត្រូវចោទ

នៅគ្រប់ពេលនៃការស៊ើបសួរ ជនត្រូវចោទអាចសុំឱ្យចៅក្រមស៊ើបសួរធ្វើការសួរចម្លើយខ្លួន ស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី សាក្សី សួរតទល់គ្នា ឬចុះទៅដល់ទីកន្លែង។ ពាក្យស្នើសុំនេះត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងដោយមានសំអាងហេតុ។

នៅក្នុងករណីចៅក្រមស៊ើបសួរ មិនព្រមធ្វើតាមការស្នើសុំរបស់ជនត្រូវចោទទេ ចៅក្រមស៊ើបសួរត្រូវចេញដីកាបដិសេធជាលាយលក្ខណ៍អក្សរនៅក្នុងចិរវេលា ១ខែ បន្ទាប់ពីពេលទទួលពាក្យសុំដោយជនត្រូវចោទ។ ដីកាបដិសេធជាលាយលក្ខណ៍អក្សរនេះត្រូវមានសំអាងហេតុ និងត្រូវជូនដំណឹងជាបន្ទាន់ដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ លឿនរហ័សតាមដែលអាចធ្វើទៅបានស្របតាម[122] ។ ប្រសិនបើចៅក្រមស៊ើបសួរមិនសម្រេចក្នុងរយៈពេល ១ខែទេ ជនត្រូវចោទអាចប្ដឹងដោយផ្ទាល់តាមរយៈពាក្យស្នើសុំដល់សភាស៊ើបសួរដើម្បីសម្រេចជំនួសបាន[123]។

### កថាខណ្ឌទី៣៖ ការស្នើសុំឱ្យបំពេញកិច្ចដោយដើមបណ្ដឹងរដ្ឋប្បវេណី

នៅគ្រប់ពេលនៃការស៊ើបសួរ ដើមបណ្ដឹងរដ្ឋប្បវេណីអាចសុំឱ្យចៅក្រមស៊ើបសួរធ្វើការស្ដាប់ចម្លើយខ្លួន ស្ដាប់ចម្លើយសាក្សី សួរចម្លើយជនត្រូវចោទ សួរតទល់គ្នា ឬចុះទៅដល់ទីកន្លែងបាន។ ពាក្យស្នើសុំនេះត្រូវជាលាយលក្ខណ៍អក្សរ និងដោយមានសំអាងហេតុ។

---

[121] មាត្រា ១៣២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។

[122] ប្រការ ២៩ នៃច្បាប់ស្ដីពីក្រមសីលធម៌ចៅក្រម ២២ កុម្ភៈ ២០០៧។

[123] មាត្រា ១៣៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។

នៅក្នុងករណីចៅក្រមស៊ើបសួរមិនព្រមធ្វើតាមការស្នើសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណីទេ ចៅក្រមស៊ើបសួរត្រូវចេញដីកាបដិសេធជាលាយលក្ខណ៍អក្សរនៅក្នុងចិរវេលា ១ខែ បន្ទាប់ពីពេលទទួលពាក្យស្នើសុំនេះ។ ដោយដីកានេះត្រូវមានសំអាងហេតុ និងត្រូវជូនដំណឹងជាបន្ទាន់ដល់ព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណី។

ប្រសិនបើចៅក្រមស៊ើបសួរមិនសម្រេចក្នុងចិរវេលា ១ខែទេ ដើមបណ្តឹងរដ្ឋប្បវេណីអាចប្តឹងដោយផ្ទាល់តាមរយៈពាក្យស្នើសុំដល់សភាស៊ើបសួរដើម្បីសម្រេចជំនួសបាន[124] ។

# ផ្នែកទី៤៖ ការបិទបញ្ចប់នីតិវិធីស៊ើបសួរនៅសាលាដំបូងរាជធានី/ខេត្ត

កាលណាចៅក្រមស៊ើបសួរយល់ឃើញ ចៅក្រមស៊ើបសួរបានបញ្ចប់ហើយ ចៅក្រមស៊ើបសួរ និងមានចំណាត់ការដូចជា ៖

**កថាខណ្ឌទី១៖ ដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញា**

ដីកាសន្និដ្ឋានស្ថាពរ គឺសំដៅទៅលើដីកាជាលាយលក្ខណ៍អក្សរដែលចេញដោយព្រះរាជអាជ្ញាស្នើសុំទៅចៅក្រមស៊ើបសួរ ដើម្បីសម្រេចអំពីដីកាដំណោះស្រាយ។

នៅពេលដែលចៅក្រមស៊ើបសួរយល់ឃើញថា ការស៊ើបសួរត្រូវបញ្ចប់នោះចៅក្រមស៊ើបសួរត្រូវធ្វើការជូនដំណឹងដល់ព្រះរាជអាជ្ញា ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីរបស់គូភាគី (ប្រសិនបើមាន)។ នៅក្នុងរយៈពេល ២ថ្ងៃ បន្ទាប់ពីបានជូនដំណឹង ចៅក្រមស៊ើបសួរត្រូវបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញាដើម្បីត្រួតពិនិត្យហើយបន្ទាប់ពីត្រួតពិនិត្យហើយបើព្រះរាជអាជ្ញាយល់ឃើញថា សំណុំរឿងនៅមានភាពចាំបាច់ត្រូវធ្វើកិច្ចស៊ើបសួរថ្មីទៀត នោះព្រះរាជអាជ្ញាត្រូវជូនដំណឹងទៅចៅក្រមស៊ើបសួរ ដើម្បីស្នើសុំឱ្យបំពេញកិច្ចស៊ើបសួរស្របតាមមាត្រា ១៣២ ដល់មាត្រា ១៣៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

នៅក្នុងរយៈពេល ១៥ថ្ងៃ ប្រសិនបើជនត្រូវចោទត្រូវឃុំខ្លួន និងរយៈពេល ១ខែ ករណីជនត្រូវចោទនៅក្រៅឃុំព្រះរាជអាជ្ញា ត្រូវបង្វិលសំណុំរឿងទៅចៅក្រមស៊ើបសួរវិញដោយមាន ដីកាសន្និដ្ឋានស្ថាពរភ្ជាប់ជាមួយផងដែរ។ សេចក្តីសន្និដ្ឋានស្ថាពរនេះអាចជា ការស្នើសុំទៅចៅក្រមស៊ើបសួរឱ្យបញ្ជូនទៅជំនុំជម្រះ ឬក៏លើកលែងការចោទប្រកាន់។

**កថាខណ្ឌទី២ ៖ ដីកាដំណោះស្រាយ**[125]

[124] មាត្រា ១៣៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។

[125] ឧបសម្ព័ន្ធ

ដីកាដំណោះស្រាយ គឺសំដៅទៅលើការបិទការស៊ើបសួរតាមរយៈដីកាជាលាយលក្ខណ៍អក្សរដែលចេញដោយចៅក្រមស៊ើបសួរដែលត្រូវជូនដំណឹងក្នុងរយៈពេលដ៏ខ្លីបំផុតដល់ព្រះរាជអាជ្ញា ជនត្រូវចោទ និងដើមបណ្តឹងរដ្ឋប្បវេណី។ ដីកានេះអាចជាដីកាបញ្ជូនទៅជំនុំជម្រះ ឬដីកាលែកលែងចោទប្រកាន់។

❖ ចំណាំៈ ក្នុងដំណាក់កាលស៊ើបសួរនេះចៅក្រមស៊ើបសួរមិនត្រូវជាប់កាតព្វកិច្ចធ្វើតាមដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញានោះទេ។ នេះក៏ដោយសារតែមុខពេលដែលចៅក្រមស៊ើបសួរសម្រេចអំពីការបញ្ចប់ការស៊ើបសួរ ចៅក្រមស៊ើបសួរមានកាតព្វកិច្ចត្រូវបញ្ជូនសំណុំរឿងអោយព្រះរាជអាជ្ញាពិនិត្យដើម្បីសុំយោបល់ពីព្រះរាជអាជ្ញា ថាខ្លួនគួរតែសម្រេចយ៉ាងដូចម្តេចលើសំណុំរឿង។ ពេលដែលព្រះរាជអាជ្ញាពិនិត្យហើយព្រះរាជអាជ្ញានឹងចេញដីកាមួយដែលមានឈ្មោះថា “ដីកាសន្និដ្ឋានស្ថាពរ” ដែលក្នុងអត្ថន័យនៃដីកានេះព្រះរាជអាជ្ញាអាចធ្វើការស្នើសុំអោយចៅក្រមស៊ើបសួរ បញ្ជូនរឿងទៅជំនុំជម្រះ និងលើកលែងការចោទប្រកាន់តាមដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរបាន។ នេះគួរបញ្ជាក់ដូចខាងលើផងដែរថាក្នុងករណីនេះ ចៅក្រមស៊ើបសួរមិនត្រូវជាប់កាតព្វកិច្ចក្នុងការធ្វើតាមដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញានោះទេ។ ការសម្រេចដីកាបញ្ជូនទៅជំនុំជម្រះ ឬដីកាលើកលែងការចោទប្រកាន់ជាស្វ័យភាពនៃការសម្រេចរបស់ចៅក្រមស៊ើបសួរ។

ក្នុងករណីដែលសំណុំរឿងស៊ើបសួរពាក់ព័ន្ធនឹងអង្គហេតុច្រើន ចៅក្រមស៊ើបសួរ អាចចេញដីកាដំណោះស្រាយចំពោះអង្គហេតុដែលការស៊ើបសួរបានចប់សព្វគ្រប់ និងបន្តការស៊ើបសួរចំពោះអង្គហេតុផ្សេងទៀតបាន។ ចៅក្រមស៊ើបសួរ ក៏អាចចេញដីកាលើកលែងចោទប្រកាន់ចំពោះជនត្រូវចោទដែលត្រូវបានស៊ើបសួររកឃើញថាមិនមានការពាក់ព័ន្ធនឹងការប្រព្រឹត្តបទល្មើស ឬការចូលរួមប្រព្រឹត្តបទល្មើស និងធ្វើការស៊ើបសួររកអត្តសញ្ញាណជនល្មើសបន្តទៀតបាន[126] ។ មួយវិញទៀតដែលការចេញដីកាដំណោះស្រាយ ត្រូវបានទាក់ទងទៅនឹងការឃុំខ្លួនបណ្តោះអាសន្ន(១) ការត្រួតពិនិត្យតាមផ្លូវតុលាការ(២) ដីកាលើកលែងចោទប្រកាន់ (៣) និងដីកាបញ្ជូនទៅជំនុំជម្រះ(៤) ។

ក្នុងករណីដែលមានការលើកលែងចោទប្រកាន់ដោយមូលហេតុអត្តសញ្ញាណរបស់ ជនត្រូវចោទមិនត្រូវបានស្គាល់ ឬក្នុងករណីដែលជនត្រូវចោទទទួលមរណភាព ចៅក្រមស៊ើបសួរអាចប្តឹងសុំទៅតុលាការព្រហ្មទណ្ឌតាមដីកាបញ្ជូនឲ្យសម្រេចរឹបអូសឧបករណ៍ សម្ភារៈ មូលនិធិ ផលទុន ឬទ្រព្យសម្បត្តិ ប្រសិនបើមានការសង្ស័យដោយសមហេតុផលថាឧបករណ៍ សម្ភារៈ មូលនិធិ ផលទុន ឬទ្រព្យសម្បត្តិទាំងនោះពាក់ព័ន្ធនឹងបទល្មើស។ ក្នុងករណីនេះ តុលាការព្រហ្មទណ្ឌត្រូវសម្រេចអំពីការរឹបអូសដោយសាលក្រមក្នុងសវនាការជាសាធារណៈដោយមានការចូលរួមពីតំណាងអយ្យការ និងបុគ្គលពាក់ព័ន្ធ ប្រសិនបើមាន។ សាលក្រមដែលសម្រេចអំពីការ

[126] មាត្រា ២៤៧ថ្មី កថាខណ្ឌទី៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។

រឹបអូសត្រូវបិទផ្សាយនៅទីកន្លែងដែលតុលាការបានចេញ សាលក្រម និងផ្សាយជាសាធារណៈតាមសារព័ត៌មាន ឬមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ ។

**១. ដីកាសម្រេចឱ្យរក្សាទុកជនត្រូវចោទក្នុងឃុំខាងបណ្ដោះអាសន្ន**[127]

ការឃុំខ្លួនបណ្ដោះអាសន្ន គឺជាការចាំបាច់ដើម្បីឱ្យដំណើរការនៃការស៊ើបសួរប្រព្រឹត្តទៅបានល្អ។ នៅពេលបិទការស៊ើបសួរត្រូវបញ្ឈប់ការឃុំខ្លួនបណ្ដោះអាសន្នដែរ គឺមានន័យថាដីកាដំណោះស្រាយបញ្ចប់ការឃុំខ្លួនបណ្ដោះអាសន្ន។ ក្នុងករណីនេះត្រូវដោះលែងជនត្រូវចោទឱ្យមានសេរីភាព។ ប៉ុន្តែចៅក្រមស៊ើបសួរអាចរក្សាជនត្រូវចោទឱ្យនៅជាប់ឃុំរហូតដល់ពេលបង្ហាញខ្លួននៅមុខតុលាការ (មូលហេតុនៃការឃុំខ្លួនបណ្ដោះអាសន្ន) ដោយស្របតាមមាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ហើយការឃុំខ្លួនបណ្ដោះអាសន្ននេះមានអានុភាពក្នុងរយៈពេល ៤ខែ។ ប្រសិនបើជនត្រូវចោទមិនបានចូលទៅបង្ហាញខ្លួននៅមុខតុលាការក្នុងរយៈពេល ៤( បួន ) ខែនោះទេ ជនត្រូវចោទនេះត្រូវបានដោះលែងឱ្យនៅក្រៅឃុំបណ្ដោះអាសន្នដោយឯកឯង[128] ។

**២. ដីកាសម្រេចឱ្យត្រួតពិនិត្យតាមផ្លូវតុលាការ**

ដីកាដំណោះស្រាយគឺជាសេចក្ដីសម្រេចមួយមានអានុភាពបញ្ចប់ការត្រួតពិនិត្យតាមផ្លូវតុលាការ។ ប៉ុន្តែចៅក្រមស៊ើបសួរអាចរក្សាទុកជនត្រូវចោទនោះឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ រហូតដល់ពេលជនត្រូវចោទចូលបង្ហាញខ្លួននៅចំពោះមុខតុលាការ។ មួយវិញទៀតដែរ កាលណាចៅក្រមស៊ើបសួរបានដាក់កំហិតដល់ជនត្រូវចោទ ឱ្យបង់ប្រាក់ធានាឱ្យប្រគល់ឯកសារបញ្ជាក់អំពីអត្តសញ្ញាណ ឬឱ្យប្រគល់អាវុធដែលមិនទាក់ទងនឹងបទល្មើស ប្រាក់ធានាឯកសារបញ្ជាក់អំពីអត្តសញ្ញាណ ឬអាវុធនោះត្រូវប្រគល់សងសាមីខ្លួនវិញ ដោយក្រឡាបញ្ជី ដោយមានបង្កាន់ដៃទទួលដែលចុះហត្ថលេខា ឬផ្ដិតស្នាមម្រាមដៃ ដោយជនត្រូវចោទទុកជាសម្គាល់[129]។

**៣. ដីកាលើកលែងចោទប្រកាន់**

នៅក្នុងចំណុចមួយវិញទៀតដែលចៅក្រមស៊ើបសួរអាចចេញដីកាលើកលែងចោទប្រកាន់បាននៅក្នុងករណីដូចជា[130] ៖

**៣.១. អំពើប្រព្រឹត្តមិនមែនជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ**

នៅក្នុងចំណុចនេះដែលជាគោលការណ៍ ដើម្បីចោទប្រកាន់អំពើណាមួយជាបទល្មើសបាននោះលុះត្រាអំពើនោះត្រូវមាននៅធាតុផ្សំ៣ គឺធាតុនីត្យានុកូលភាព( ធាតុច្បាប់ ) ធាតុសត្យានុម័ត( ធាតុសម្ភារៈ ) ធាតុអត្តនោម័ត

---

127 ឧបសម្ព័ន្ធ

128 មាត្រា ២៤៩ កថាខណ្ឌទី៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។

129 មាត្រា ២៤៩ កថាខណ្ឌទី៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។

130 មាត្រា ២៤៧ថ្មី កថាខណ្ឌទី៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។

(ធាតុចេតនា)។ ក្នុងករណីដែលចៅក្រមបានស៊ើបសួរទៅស្រាប់តែឃើញថា ជនត្រូវចោទដែលព្រះរាជអាជ្ញាបញ្ជូនមកនោះពុំបានប្រព្រឹត្តអំពើដែលជាបទល្មើសនោះចៅក្រមស៊ើបសួរមិនអាចដាក់បន្ទុកបាននោះឡើយ។ គួរចំណាំផងដែរថា ចៅក្រមស៊ើបសួរស៊ើបសួរក្នុងគោលបំណងដើម្បីដាក់បន្ទុក និងដោះបន្ទុក ដូច្នេះការដាក់បន្ទុកនៃចៅក្រមស៊ើបសួរគឺដើម្បីបញ្ជូនទៅជំនុំជម្រះ រីឯការស៊ើបសួរដោះបន្ទុកគឺដើម្បីលើកលែងការចោទប្រកាន់។ ហេតុដូច្នេះហើយទើបចៅក្រមស៊ើបសួរមានសិទ្ធិ ក្នុងការបញ្ជូនរឿងទៅជំនុំជម្រះ និងលើកលែងការចោទប្រកាន់។

**៣.២. ជនដែលប្រព្រឹត្តអំពើនោះនៅតែមិនស្គាល់អត្តសញ្ញាណ**

ចំណែកចំណុចដោយសារតែគោលការណ៍នៃការចោទប្រកាន់របស់ព្រះរាជអាជ្ញាគឺអាចចោទប្រកាន់ចំពោះអញ្ញាតជនបាន។ ហើយការបើកការស៊ើបសួរក៏អាចប្រឆាំង នឹងអញ្ញាតជនបានដែរ ដូច្នេះបើនៅតែពុំអាចស្វែងរកអំពីអត្តសញ្ញាណរបស់ជនត្រូវចោទបាននោះទេ ចៅក្រមស៊ើបសួរត្រូវតែចេញដីកាលើកលែងការចោទប្រកាន់។

**៣.៣. គ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនត្រូវចោទ**

ចំណុចទី៣ នេះកើតឡើងដោយសារគោលការណ៍វិមតិសង្ស័យដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលជាច្បាប់កំពូល។ គោលការណ៍វិមតិសង្ស័យនេះមានចែងក្នុងមាត្រា ៣៨ កថាខណ្ឌទី៦ នៃរដ្ឋធម្មនុញ្ញ។ មាត្រានេះបានចែងថា គោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ជនជាប់ចោទ។

**៣.៤. ករណីដែលបណ្តឹងអាជ្ញារលត់**

ក្នុងករណីនេះដែរ កាលណាបណ្តឹងអាជ្ញារលត់ ការចោទប្រកាន់ខាងបទល្មើសព្រហ្មទណ្ឌពុំអាចធ្វើបានឡើយ។ មូលហេតុនៃការរលត់បណ្តឹងអាជ្ញាមានដូចតទៅ៖

- មរណៈភាពនៃជនល្មើស
- ផុតអាជ្ញាយុកាល
- ការលើកលែងទោសជាទូទៅ
- និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ
- អាជ្ញាអស់ជំនុំ ។

ចៅក្រមស៊ើបសួរអាចចេញដីកាលើកលែងការចោទប្រកាន់បានលុះត្រាតែលក្ខខណ្ឌណាមួយខាងលើនេះបានបំពេញទើបចៅក្រមស៊ើបសួរអាចធ្វើទៅបាន។ ការចេញដីកាដំណោះស្រាយជាគោលការណ៍ចៅក្រមស៊ើបសួរត្រូវតែមានសំអាងហេតុ។

ក្នុងករណីដែលមានការលើកលែងចោទប្រកាន់ដោយមូលហេតុអត្តសញ្ញាណរបស់ ជនត្រូវចោទមិនត្រូវបានស្គាល់ ឬក្នុងករណីដែលជនត្រូវចោទទទួលមរណភាព ចៅក្រមស៊ើបសួរអាចប្តឹងសុំទៅតុលាការព្រហ្មទណ្ឌតាមដីកាបញ្ជូនឱ្យសម្រេចរឹបអូសឧបករណ៍ សម្ភារៈ មូលនិធិ ផលទុន ឬទ្រព្យសម្បត្តិ ប្រសិនបើមានការសង្ស័យដោយសមហេតុផលថា ឧបករណ៍ សម្ភារៈ មូលនិធិ ផលទុន ឬទ្រព្យសម្បត្តិទាំងនោះពាក់ព័ន្ធនឹងបទល្មើស។ ក្នុងករណីនេះ តុលាការព្រហ្មទណ្ឌ ត្រូវសម្រេចអំពីការរឹបអូសដោយសាលក្រមក្នុងសវនាការជាសាធារណៈ

ដោយមានការចូលរួមពីតំណាងអយ្យការ និងបុគ្គលពាក់ព័ន្ធ ប្រសិនបើមាន។ សាលក្រមដែលសម្រេចអំពីការរឹបអូសត្រូវបិទផ្សាយនៅទីកន្លែងដែលតុលាការបានចេញ សាលក្រម និងផ្សាយជាសាធារណៈតាមសារព័ត៌មាន ឬមធ្យោបាយទូរគមនាគមន៍សោតទស្សន៍[131]។

**៤.ដីកាបញ្ជូនរឿងទៅជំនុំជម្រះ**

ចៅក្រមស៊ើបសួរចេញដីកាបញ្ជូនទៅជំនុំជម្រះ ប្រសិនបើយល់ឃើញថាអំពើនោះជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ។ អំពើដែលត្រូវចោទប្រកាន់ និងឈ្មោះបទល្មើសតាមច្បាប់។ ដីកាបញ្ជូនទៅជំនុំជម្រះ ក៏ដូចជាដីកាលើកលែងការចោទប្រកាន់ដែរ ដោយដកសមត្ថកិច្ច របស់ចៅក្រមស៊ើបសួរ ទៅឱ្យតុលាការដែលសំណុំរឿងត្រូវបានបញ្ជូនទៅចៅក្រមជំនុំជម្រះដើម្បីជំនុំជម្រះ។ ដីកាបញ្ជូនទៅជំនុំជម្រះនេះ បញ្ចប់ការត្រួតពិនិត្យតាមផ្លូវតុលាការ និងការឃុំខ្លួនបណ្ដោះអាសន្ន។ ប៉ុន្តែយោងតាមសេចក្ដីសម្រេចដោយឡែកនៃដីកាដំណោះស្រាយ និងក្រោមលក្ខខណ្ឌមួយចំនួនចៅក្រមស៊ើបសួរអាចរក្សាជនត្រូវចោទ ឱ្យនៅជាប់ឃុំរហូតដល់ពេល ចូលបង្ហាញខ្លួននៅមុខតុលាការនៃចៅក្រមជំនុំជម្រះ។ ក្នុងករណីនេះចៅក្រមស៊ើបសួរត្រូវមានសំអាងហេតុ ទៅលើសេចក្ដីសម្រេចរក្សាជនត្រូវចោទឱ្យនៅក្នុងឃុំ ដោយមូលហេតុណាមួយក្នុងចំណោមមូលហេតុទាំងអស់ដូចជា៖ ដើម្បីបញ្ចប់បទល្មើស ឬដើម្បីបង្ការ និងទប់ស្កាត់បទល្មើសកុំឱ្យកើតឡើងជាថ្មី រារាំងកុំឱ្យមានការគាបសង្កត់លើសាក្សី ឬជនរងគ្រោះ ឬរារាំងកុំឱ្យមានការត្រូវរូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិត ដើម្បីធានារក្សាទុកជនត្រូវចោទជូនតុលាការចាត់ការតាមនីតិវិធីច្បាប់ ដើម្បីការពារជនត្រូវចោទ ដើម្បីរក្សាសណ្ដាប់ធ្នាប់សាធារណៈកុំឱ្យមាន ភាពច្របូកច្របល់ដែលបណ្ដាលមកពីបទល្មើស[132] ។

ប្រសិនបើចៅក្រមស៊ើបសួរសម្រេចចេញដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះ ចៅក្រមត្រូវបញ្ជូនសំណុំរឿងជាបន្ទាន់ទៅប្រធានតុលាការ ដើម្បីកំណត់ពេលសវនាការបើកការជំនុំជម្រះ។

**កថាខណ្ឌទី៣៖ ការប្រគល់វត្ថុដែលចាប់បានឱ្យទៅម្ចាស់ដើមវិញ**

នៅក្នុងដីកាដំណោះស្រាយ ចៅក្រមស៊ើបសួរសម្រេចអំពីការប្រគល់សងទៅឱ្យម្ចាស់ដើមវិញនូវវត្ថុដែលចាប់យក។ ក្នុងករណីដែលមិនទាន់ចេញដីកាដំណោះស្រាយរឿងនៅឡើយទេ ចៅក្រមស៊ើបសួរមានសមត្ថកិច្ចប្រគល់សងទៅម្ចាស់ដើមវិញនូវវត្ថុដែលចាប់បាន កាលណាវត្ថុនេះលែងមានផលប្រយោជន៍សម្រាប់រឿងក្ដី។ ចៅក្រមស៊ើបសួរសម្រេចតាមដីកាដែលមានសំអាងហេតុ ក្រោយពីបានទទួលមតិពីព្រះរាជអាជ្ញា។ ដីកាសម្រេចត្រូវឱ្យដំណឹងជាបន្ទាន់ដល់អ្នកប្ដឹង និងមេធាវីនៃអ្នកប្ដឹង (ប្រសិនបើមាន)។ មិនគួរប្រគល់វត្ថុនោះទៅឱ្យអ្នកប្ដឹងសុំទេ កាលណាវិធានការនេះអាចបង្កជាឧបសគ្គដល់ការរកឃើញការពិត ឬវត្ថុដែលមានគ្រោះថ្នាក់ដល់បុគ្គល ឬ

[131] មាត្រា ២៤៧ថ្មី កថាខណ្ឌទី៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។

[132] មាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។

ទ្រព្យសម្បត្តិដូចជាអាវុធ ឬជាតិផ្ទុះ ព្រមទាំងវត្ថុដែលការកាន់កាប់មិនស្របច្បាប់ មិនអាចត្រូវប្រគល់សងទៅឱ្យសាមីខ្លួនបានទេ។ វត្ថុនេះត្រូវរឹបអូសជាកម្មសិទ្ធិរបស់រដ្ឋ។

# សេចក្ដីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវទៅលើប្រធានបទស្តីពី **កិច្ចស៊ើបសួរក្នុងរឿងព្រហ្មទណ្ឌ** រួចមក យើងខ្ញុំទាំងពីរយល់ឃើញថានីតិវិធីនេះទាមទារ ការអនុវត្តនីតិវិធីប្រព្រឹត្តទៅប្រកបដោយភាពហ្មត់ចត់ និងការទទួលខុសត្រូវខ្ពស់បំផុតនៅក្នុងនោះដែរ មុននឹងធ្វើការបញ្ជូនរឿងទៅស៊ើបសួរ ចាំបាច់ត្រូវតែមានការចោទប្រកាន់ពីព្រះរាជអាជ្ញាជាមុនសិន។ ដោយនៅក្នុងដំណាក់កាលនៃការចោទប្រកាន់នេះដែរព្រះរាជអាជ្ញាត្រូវតែពិនិត្យទៅលើលក្ខខណ្ឌនៃបទល្មើសព្រហ្មទណ្ឌជាមុនសិន ថាតើបទល្មើសជាប្រភេទនៃបទល្មើសអ្វី បទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ទៅតាមការកំណត់របស់នីតិវិធីច្បាប់នីមួយៗទើបព្រះរាជអាជ្ញាមានសិទ្ធិក្នុងការសម្រេចចិត្តចោទប្រកាន់ ឬមិនចោទប្រកាន់នៃបទល្មើសព្រហ្មទណ្ឌបាន។ ក្នុងករណីនោះដែរព្រះរាជអាជ្ញាមិនធ្វើការចោទប្រកាន់ទេគឺព្រះរាជអាជ្ញាត្រូវអនុវត្តនីតិវិធីនៃការតម្កល់រឿងទុកឥតចាត់ការ ប៉ុន្តែប្រសិនបើព្រះរាជអាជ្ញាយល់ឃើញថា សម្រេចចោទប្រកាន់វិញនោះព្រះរាជអាជ្ញាត្រូវជ្រើសរើស អនុវត្តនូវលំហូរនីតិវិធីចំនួនបីគឺ នីតិវិធីនៃការបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ ការបង្ហាញខ្លួនភ្លាម និងនីតិវិធីនៃការបើកការស៊ើបសួរ។ ចំពោះការបើកការស៊ើបសួរគឺព្រះរាជអាជ្ញាធ្វើឡើងតាមរយៈ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ទៅកាន់ស្ថាប័ននៃចៅក្រមស៊ើបសួរ។

ក្រោយពីចៅក្រមស៊ើបសួរ ទទួលបានសំណុំរឿងពីការចាត់តាំង និងការបែងចែកសំណុំរឿងរួចរាល់ ចៅក្រមស៊ើបសួរត្រូវតែពិនិត្យទៅលើបទល្មើសជាមុនសិន ទើបគាត់ត្រូវបើកការស៊ើបសួរ។ ការបើកការស៊ើបសួរជំហានបន្ទាប់នេះគឺ ធ្វើការស្រាវជ្រាវទៅលើបទល្មើស ដែលការស្រាវជ្រាវនោះគឺស្រាវជ្រាវទាក់ទងនឹងបុគ្គលដែលមានដូចជា ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី សាក្សីជាដើម។ ហើយការស៊ើបសួរទាក់ទងនឹងភស្តុតាងវិញគឺ មានការស្វែងរកភស្តុតាង វាយតម្លៃនៃភស្តុតាង ការធ្វើកោសល្យវិច័យ និងការស្តាប់ទូរស័ព្ទ រហូតដល់ដំណាក់កាលនៃការចេញនូវវិធានការនិរន្តរាយរបស់ចៅក្រមស៊ើបសួរ។ ក្នុងកិច្ចនៃនីតិវិធីនេះ តុលាការអាចឃុំ ខ្លួនជនត្រូវចោទតាមការកំណត់បទល្មើសរបស់ច្បាប់ ឬដាក់ជននោះឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ទើបអាចឈានដល់ដំណាក់កាលនៃការបិទការស៊ើបសួរ។ នៅពេលបិទការស៊ើបសួរនេះ ចៅក្រមស៊ើបសួរត្រូវជូនដំណឹងជាបឋមដល់ ព្រះរាជអាជ្ញា ដើមបណ្តឹងរដ្ឋប្បវេណី និងជនត្រូវចោទអំពីការបិទការស៊ើបសួររបស់ខ្លួន។ ចៅក្រមស៊ើបសួរ ធ្វើការបញ្ចប់នីតិវិធីរបស់ខ្លួនដោយសម្រេចសេចក្តីក្នុងការលើកលែងបទចោទប្រកាន់នៃបទល្មើស ឬបញ្ជូនរឿងទៅជំនុំជម្រះ ទៅចៅក្រមជំនុំជម្រះនៃតុលាការមានសមត្ថកិច្ច។

យើងខ្ញុំសង្កេតឃើញថានីតិវិធីនេះ វាហាក់បីដូចជាមានភាពស្មុគស្មាញបន្តិចមែន ប៉ុន្តែវាបានបង្ហាញឱ្យយើងឃើញកាន់តែច្បាស់លាស់ពី ការអនុវត្តនៃនីតិវិធីរបស់តុលាការមុននឹងធ្វើការជំនុំជម្រះថាជនណាម្នាក់មានទោស ឬគ្មានទោសនៃបទល្មើសព្រហ្មទណ្ឌ ពីព្រោះថាគ្រប់ដំណាក់កាលដែលច្បាប់នៃប្រទេសយើងបាន

បញ្ញត្តិឡើង គឺដើម្បីធ្វើកិច្ចនីតិវិធីនីមួយៗ ឱ្យមានតម្លាភាព សច្ចធម៌ យុត្តិធម៌ ក្នុងការដោះស្រាយ និងទទួលយកបានទាំងគ្រប់ភាគីនៃវិវាទដែលកើតឡើង។ មិនត្រឹមតែប៉ុណ្ណោះទេសំណុំរឿងព្រហ្មទណ្ឌបានអនុញ្ញាតឱ្យតុលាការស្វែងរកជនណាដែលបង្កបញ្ហាដល់សង្គមយ៉ាងពិតប្រាកដ និងចាប់ជននោះមកផ្តន្ទាទោសតាមច្បាប់ជាធរមាន។ ជាក់ស្តែងណាស់ចំពោះនីតិវិធីនៃការបញ្ជូនរឿងទៅស៊ើបសួរ នេះមានស្ថាប័នចៅក្រមស៊ើបសួរជាចម្បងមកចូលរួមក្នុងការដោះស្រាយ និងស៊ើបសួរតាមរយៈការស្រាវជ្រាវព្រមទាំងបានធ្វើឱ្យសំណុំរឿងនៃរឿងក្តីព្រហ្មទណ្ឌត្រូវបានតុលាការធ្វើការជំនុំជម្រះបានដោយមិនខុសនឹងនីតិវិធីជាធរមាន។ ជាការពិតណាស់ការអនុវត្តនូវនីតិវិធីដើម្បីទទួលបានយុត្តិធម៌ព្រហ្មទណ្ឌគឺតម្រូវឱ្យមានការដោះស្រាយដោយត្រឹមត្រូវទៅតាមច្បាប់ជាធរមាន ហើយមិនអាចឱ្យជនណាម្នាក់ទទួលរងនូវការឈឺចាប់ ឬភាពអយុត្តិធម៌នោះទេ ពោលគឺព្យាយាមក្នុងស្វែងរក និងអនុវត្តច្បាប់ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គល ត្រូវបានធ្វើឡើងដោយមិនមានការប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ។

សរុបសេចក្តីជារួមមក កិច្ចស៊ើបសួរក្នុងរឿងព្រហ្មទណ្ឌ នេះពិតជាមានសារៈសំខាន់ខ្លាំងណាស់ ដែលអាចឱ្យរឿងក្តីមួយមានភាពពេញលេញនៃដំណោះស្រាយ ហើយឱ្យបង្ហាញពីការពិតចំពោះអំពើល្មើស ដើម្បីស្វែងរកចាប់ជននោះមកដាក់ទោសតាមច្បាប់ និងមានភាពយុត្តិធម៌ក្នុងសង្គមក៏ដូចជា ជនរងគ្រោះផងដែរ។ កាលណារឿងមួយត្រូវបានបញ្ជូនទៅកាន់ស្ថាប័ននៃចៅក្រមស៊ើបសួរបាន វាចាំបាច់ណាស់ត្រូវតែមានការឯកភាពពីព្រះរាជអាជ្ញាតាមរយៈ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរជាមុនសិន ហើយចំពោះការអនុវត្តការងាររបស់ព្រះរាជអាជ្ញា និងចៅក្រមស៊ើបសួរគឺធ្វើឡើងយ៉ាងយកចិត្តទុកដាក់ និងអត់ធ្មត់បំផុតពីបុគ្គលទាំងនោះជាពិសេសគឺចៅក្រមស៊ើបសួរ។ ម្យ៉ាងវិញទៀត ក៏ត្រូវមានការប្រុងប្រយ័ត្នខ្ពស់ផងដែរ ចំពោះការស៊ើបសួរខ្លះអាចធ្វើឱ្យមានភាពលំបាកដល់អ្នកស៊ើបសួរ ប៉ុន្តែដើម្បីមានជំនឿលើប្រព័ន្ធតុលាការ និងបង្ហាញពីភាពច្បាស់លាស់របស់ខ្លួនបានចាំបាច់ណាស់ត្រូវធ្វើតាមនីតិវិធីដែលមានចែងជាធរមាន។ ទោះបីជាយ៉ាងណាក៏ដោយ យើងខ្ញុំសូមធ្វើការគាំទ្រឱ្យមានកិច្ចនីតិវិធីនៃការបញ្ជូនរឿងទៅស៊ើបសួរនេះ ដែលត្រូវបានអនុវត្តឡើងដោយព្រះរាជអាជ្ញា និងចៅក្រមស៊ើបសួរមុនធ្វើការបញ្ជូនរឿងក្តីនោះទៅសវនាការ។

# អនុសាសន៍

# អនុសាសន៍

ឆ្លងកាត់តាមការសិក្សាស្រាវជ្រាវអំពីដំណើរការនៃនីតិវិធី "**កិច្ចស៊ើបសួរក្នុងរឿងព្រហ្មទណ្ឌ**" ដែលធ្វើឡើងដោយព្រះរាជអាជ្ញា ទៅកាន់ចៅក្រមស៊ើបសួរ យើងខ្ញុំសង្កេតឃើញថា ដំណើរការនៃនីតិវិធីពិតជាមានលក្ខណៈល្អសមស្របមួយដែលភាគីអាចទទួលយកបាន ពីព្រោះថាបទល្មើសព្រហ្មទណ្ឌខ្លះ មានការផ្តន្ទាទោសដាក់ពន្ធនាគារធ្ងន់ធ្ងរ (បទឧក្រិដ្ឋ) នេះជាហេតុធ្វើឱ្យមានការប៉ះពាល់ដល់សិទ្ធិសេរីភាពជាមូលដ្ឋានរបស់បុគ្គលដែលបានប្រព្រឹត្តបទល្មើសជាដើម។ មិនត្រឹមតែប៉ុណ្ណោះ ដំណើរការនៃនីតិវិធីនេះបានផ្តល់លទ្ធភាពសមស្របដល់គូភាគីនៃរឿងក្តីឱ្យចូលរួមស្វែងរកការពិតជាមួយស្ថាប័នតុលាការ ដោយឆ្លុះបញ្ចាំងពីឯករាជភាពនៃការអនុវត្តនីតិវិធីរបស់ខ្លួនដោយតាងនាមប្រជារាស្ត្រខ្មែរទាំងមូល ហើយផ្តល់នូវយុត្តិធម៌សម្រាប់ប្រជាជននៃប្រទេសកម្ពុជា ដែលជារដ្ឋឯករាជ្យពិតប្រាកដ។ ចំពោះការបញ្ជូនរឿងទៅស៊ើបសួរនេះ បានផ្តល់សមត្ថកិច្ចយ៉ាងពេញលេញដល់ចៅក្រមស៊ើបសួរក្នុងការស្វែងរកឱ្យឃើញការពិតជូនជនរងគ្រោះ ជូនសង្គមជាតិ និងជូនដល់ជនដែលប្រព្រឹត្តខុសច្បាប់ព្រហ្មទណ្ឌជាដើម។ ពីព្រោះថាឆ្លងកាត់ដំណើរការនីតិវិធីស៊ើបសួរស្រាវជ្រាវបទល្មើសរួចហើយនោះវាបាន បង្ហាញឱ្យកាន់តែច្បាស់ថែមមួយកម្រិតទៀតថា តុលាការបានយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើតួនាទីរបស់ខ្លួនក្នុងការជំនុំជម្រះថាជនណាម្នាក់មានទោស ឬគ្មានទោសនៃច្បាប់ក្នុងសង្គមជាធរមាន។

ម្យ៉ាងវិញទៀតការស្រាវជ្រាវនៃបទល្មើសទាំងឡាយចៅក្រមស៊ើបសួរមិនអាចស៊ើបសួរ រឿងក្តីព្រហ្មទណ្ឌដោយគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរពីព្រះរាជអាជ្ញាបានឡើយ ហើយរាល់ការស៊ើបសួរត្រូវតែស៊ើបសួរនូវកម្មវត្ថុដែលមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរមកនេះតែប៉ុណ្ណោះ ពោលគឺមិនអាចធ្វើការស៊ើបសួរទៅលើអង្គហេតុផ្សេងបានឡើយ។ នេះមានន័យថា ប្រសិនបើចៅក្រមស៊ើបសួរបានអនុវត្តផ្ទុយពីនីតិវិធីនេះការស៊ើបសួរនោះពុំមានអានុភាពហើយក៏មិនមានភាពយុត្តិធម៌សម្រាប់ភាគីពាក់ព័ន្ធឡើយ។ ហេតុនេះដើម្បីឱ្យមានភាពច្បាស់លាស់ និងអាចទទួលយកបាន ព្រះរាជអាជ្ញា និងចៅក្រម មិនអាចធ្វើតាមតែចិត្តនឹកឃើញរបស់ខ្លួនបានទេ គឺត្រូវអនុវត្តតាមច្បាប់ដែលបានចែងពិតប្រាកដច្បាស់លាស់ ដោយឥតលម្អៀងឡើយ។ បន្ថែមពីលើនេះទៅទៀត ដើម្បីទទួលបានភាពយុត្តិធម៌ទាំងអស់គ្នា ប្រជាពលរដ្ឋគួរតែចូលរួមសហការជាមួយមន្ត្រីរាជការនានា ឬអ្នកអនុវត្តច្បាប់ពាក់ព័ន្ធតាមរយៈការកោះហៅធ្វើជាសាក្សី ដោយការផ្តល់នូវព័ត៌មានអំពីបទល្មើសណាមួយដែលខ្លួនបានដឹងដល់អាជ្ញាធរមានសមត្ថកិច្ច ដើម្បីឱ្យពួកគាត់ចូលអន្តរាគមន៍បានទាន់ពេលវេលា។ ប្រជាពលរដ្ឋកម្ពុជាយើងបច្ចុប្បន្ននេះ ក្រមនីតិវិធីព្រហ្មទណ្ឌ ឬច្បាប់នានាផ្សេងទៀត ពួកគាត់នៅមានការយល់ដឹងមានកម្រិតនៅឡើយ ហេតុដូច្នេះហើយទើបក្រសួងយុត្តិធម៌ និងស្ថាប័នតុលាការត្រូវតែធ្វើការផ្សព្វផ្សាយ តាមបណ្តាញសង្គមបច្ចេកវិទ្យាឱ្យមានភាពទូលំទូលាយ ព្រមទាំងកាត់បន្ថយ និងលុបបំបាត់នូវរាល់អំពើពុករលួយគ្រប់រូបភាព និងគ្រប់ទម្រង់ដើម្បីឱ្យមានភាពជឿជាក់លើប្រព័ន្ធតុលាការក្នុងការ ស្វែងរកដំណោះស្រាយដោយសន្តិវិធី ពីព្រោះថាប្រសិនបើមិនមានភាពជឿជាក់លើប្រព័ន្ធតុលាការក្នុងការដោះស្រាយរឿងក្តីនោះទេ គឺអាចនឹង

ធ្វើឱ្យសង្គមមានភាពរឹករវចលាចល ប្រជាពលរដ្ឋពោរពេញទៅដោយភាពច្របូកច្របល់ ដោយមិនគិតស្វែងរកដំណោះស្រាយតាមច្បាប់ជាដើម។

ដូច្នេះហើយក្នុងនាមយើងខ្ញុំជាបញ្ញាវ័ន្តផ្នែកច្បាប់ ត្រូវតែចូលរួមចំណែកក្នុងការផ្សព្វផ្សាយឱ្យប្រជាពលរដ្ឋមានការយល់ដឹងអំពីច្បាប់ដោយត្រូវធ្វើខ្លួនឯងជាគំរូក្នុងការអនុវត្តច្បាប់ជាមុនសិន មុននឹងទៅពន្យល់ណែនាំតាមរយៈប្រជាពលរដ្ឋឱ្យពួកគាត់មានការយល់ដឹងកាន់តែច្បាស់ថែមមួយកម្រិតទៀត ដែលទាក់ទងទៅនឹងជីវភាពរស់នៅរបស់ពួកគាត់ប្រចាំថ្ងៃ។ ទោះបីជានីតិវិធីនៃការបញ្ជូនរឿងទៅស៊ើបសួរ នេះជាកិច្ចនីតិវិធីរបស់ស្ថាប័នតុលាការតាមរយៈ ព្រះរាជអាជ្ញា និងចៅក្រមស៊ើបសួរក៏ដោយ ក៏ប្រជាពលរដ្ឋគប្បីមានការយល់ដឹងដែរ ព្រោះនីតិវិធីនេះពាក់ព័ន្ធប្រជាពលរដ្ឋនៅត្រង់ចំណុចនៃការចូលរួមដើម្បីធ្វើការដាក់ពាក្យបណ្តឹង រហូតដល់ចំណុចដែលចៅក្រមស៊ើបសួរធ្វើការកោះហៅប្រជាពលរដ្ឋ ឬភាគីពាក់ព័ន្ធឱ្យចូលខ្លួនមកបំភ្លឺក្នុងឋានៈជា សាក្សី ជនរងគ្រោះ ជនជាប់ចោទ តាមភាពចាំបាច់នៃនីតិវិធីព្រហ្មទណ្ឌ។

# ឯកសារយោង

# ឯកសារយោង

## ១. ក្រុមឯកសារច្បាប់

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ២៤ កញ្ញា ១៩៩៣។
- ក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២ ៣០ វិច្ឆិកា ២០០៩។
- ក្រមនីតិវិធីព្រហ្មទណ្ឌ លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។
- ច្បាប់ស្តីពីវិសោធនកម្ម មាត្រា២៤៧ មាត្រា៣៦៨ មាត្រា៣៧២ និងមាត្រា៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ១១ មិថុនា ២០១៣។
- ច្បាប់ស្តីពីក្រមសីលធម៌ចៅក្រម ២២ កុម្ភៈ ឆ្នាំ២០០៧។
- ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ លេខ១៤៩/០០៣/២០១៤ កបធ.ច ០២ កក្កដា ២០១៤។
- ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា លេខ១៤៧/០០១/២០១៤ កបធ.ច ០២ កក្កដា ឆ្នាំ២០១៤។

## ២. ក្រុមឯកសារមេរៀន

- សៀវភៅមេរៀនស្តីពី នីតិវិធីព្រហ្មទណ្ឌ រៀបរៀងដោយលោកសាស្ត្រាចារ្យ **មីន សំអុល** ឆ្នាំសិក្សា ២០២០ - ២០២១ ។
- សៀវភៅមេរៀនស្តីពី នីតិវិធីព្រហ្មទណ្ឌ រៀបរៀងដោយលោកសាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ** និង លោកស្រីសាស្ត្រាចារ្យ **ចាំង ស៊ីណាត** ។
- សៀវភៅមេរៀនស្តីពី នីតិវិធីព្រហ្មទណ្ឌ រៀបរៀងដោយលោកសាស្ត្រាចារ្យ **សុខ ឿន** ឆ្នាំសិក្សា ២០១០-២០១១ ។
- សៀវភៅមេរៀនស្តីពី នីតិវិធីព្រហ្មទណ្ឌ រៀបរៀងដោយលោកស្រី **ឌី លីហ្សា** និង លោក **ខាន់ សុខា**
- សៀវភៅមេរៀនស្តីពី ដំណើរការរឿងក្តីព្រហ្មទណ្ឌនៅកម្ពុជាបច្ចុប្បន្ន រៀបរៀងដោយលោកវរសេនីយ៍ឯក **អាន សុវិជា** ។
- សន្ធានុក្រមពាក្យច្បាប់ផ្នែកព្រហ្មទណ្ឌ ខ្មែរ-អង់គ្លេស-បារាំង ឆ្នាំ២០១១ ។

# បញ្ជីឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

| ល.រ ឧបសម្ព័ន្ធ | ឈ្មោះឯកសារ | ចំនួនទំព័រ |
|---|---|---|
| ឧបសម្ព័ន្ធទី១ | ដីកាសន្និដ្ឋានសុំឱ្យឃុំខ្លួនបណ្ដោះអាសន្ន | ២ |
| ឧបសម្ព័ន្ធទី២ | ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ | ២ |
| ឧបសម្ព័ន្ធទី៣ | ដីកាសម្រេចចាត់តាំងចៅក្រមស៊ើបសួរ | ១ |
| ឧបសម្ព័ន្ធទី៤ | ដីកាបង្គាប់ឱ្យចូលខ្លួន | ១ |
| ឧបសម្ព័ន្ធទី៥ | ដីកាបង្គាប់ឱ្យនាំខ្លួន | ១ |
| ឧបសម្ព័ន្ធទី៦ | ដីកាបង្គាប់ឱ្យចាប់ខ្លួន | ១ |
| ឧបសម្ព័ន្ធទី៧ | ដីកាបញ្ជូន ផ្ញើជូនលោកអធិការនគរបាលស្រុកកៀនស្វាយ ខេត្តកណ្ដាល | ១ |
| ឧបសម្ព័ន្ធទី៨ | ដីកាបញ្ជូន ផ្ញើជូនលោកមេបញ្ជាការកងរាជអាវុធហត្ថស្រុកកៀនស្វាយ | ១ |
| ឧបសម្ព័ន្ធទី៩ | ដីកាបញ្ជូន ផ្ញើជូនលោកព្រះរាជអាជ្ញាអមសាលាដំបូងខេត្តកណ្ដាល | ១ |
| ឧបសម្ព័ន្ធទី១០ | ដីកាកោះ ដើមបណ្ដឹងរដ្ឋប្បវេណី | ១ |
| ឧបសម្ព័ន្ធទី១១ | លិខិតអញ្ជើញ មេធាវី | ១ |
| ឧបសម្ព័ន្ធទី១២ | ដីកាបញ្ជូន ផ្ញើជូនលោកអធិការនគរបាលស្រុករមាសហែក ខេត្តស្វាយរៀង | ១ |
| ឧបសម្ព័ន្ធទី១៣ | ដីកាបញ្ជូន ផ្ញើជូនលោកអធិការនគរបាលខណ្ឌចំការមន រាជធានីភ្នំពេញ | ១ |
| ឧបសម្ព័ន្ធទី១៤ | របាយការណ៍ស្តីពីការបញ្ជូន ប្រអប់ខាងក្រោមត្រូវបំពេញដោយក្រឡាបញ្ជី | ១ |
| ឧបសម្ព័ន្ធទី១៥ | កំណត់ហេតុស្តីពីការបង្ហាញខ្លួនលើកដំបូង | ៣ |
| ឧបសម្ព័ន្ធទី១៦ | កំណត់ហេតុស្តីពីការពិភាក្សាដេញដោលចំពោះមុខ | ២ |
| ឧបសម្ព័ន្ធទី១៧ | កំណត់សហេតុស្តីពីការសួរចម្លើយជនត្រូវចោទ | ២ |
| ឧបសម្ព័ន្ធទី១៨ | កំណត់ហេតុស្តីពីការស្តាប់ចម្លើយជនរងគ្រោះដើមបណ្ដឹង | ២ |
| ឧបសម្ព័ន្ធទី១៩ | ដីកាសម្រេចឱ្យឃុំខ្លួនបណ្ដោះអាសន្ន | ២ |
| ឧបសម្ព័ន្ធទី២០ | លិខិតបញ្ជូន | ១ |
| ឧបសម្ព័ន្ធទី២១ | ដីកាបង្គាប់ឱ្យឃុំខ្លួនបណ្ដោះអាសន្ន | ២ |
| ឧបសម្ព័ន្ធទី២២ | ដីកាបញ្ជូនឱ្យឆ្លើយ | ១ |
| ឧបសម្ព័ន្ធទី២៣ | ដីកាសម្រេចអនុញ្ញាតឱ្យនៅក្រៅឃុំបណ្ដោះអាសន្ន | ២ |

| | | |
|---|---|---|
| ឧបសម្ព័ន្ធទី២៤ | ដីកាសម្រេចដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ | ២ |
| ឧបសម្ព័ន្ធទី២៥ | ដីកាបង្គាប់ឱ្យដោះលែង ដោយចៅក្រមស៊ើបសួរ | ១ |
| ឧបសម្ព័ន្ធទី២៦ | កំណត់ហេតុស្ដីពីការធ្វើសច្ចាប្រណិធាន | ១ |
| ឧបសម្ព័ន្ធទី២៧ | ដីកាបង្គាប់ឱ្យស្រាវជ្រាវ និងបំពេញសាវតាជាតិ | ១ |
| ឧបសម្ព័ន្ធទី២៨ | ដីកាបញ្ជូន ផ្ញើជូនលោកអធិការនគរបាលស្រុកកោះធំ ខេត្តកណ្ដាល | ១ |
| ឧបសម្ព័ន្ធទី២៩ | ដីកាបង្គាប់ឱ្យនាំខ្លួនជនត្រូវចោទទៅតុលាការ | ១ |
| ឧបសម្ព័ន្ធទី៣០ | លិខិតអញ្ជើញ ប្រធានការិយាល័យគ្រឿងញៀននៃស្នងការនគរបាលខេត្តកណ្ដាល | ១ |
| ឧបសម្ព័ន្ធទី៣១ | ដីកាបញ្ជូន គោរពផ្ញើជូនលោកស្នងការនគរបាលខេត្តកណ្ដាល | ១ |
| ឧបសម្ព័ន្ធទី៣២ | កំណត់ហេតុបើក ធ្វើតេស្ដ ដកសំណាក និងវេចខ្ចប់សំណាកគ្រឿងញៀន | ១ |
| ឧបសម្ព័ន្ធទី៣៣ | ដីកាចាត់តាំងអ្នកជំនាញ | ២ |
| ឧបសម្ព័ន្ធទី៣៤ | ដីកាបញ្ជូន ផ្ញើជូនឯកឧត្ដមអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន | ១ |
| ឧបសម្ព័ន្ធទី៣៥ | ដីកាសម្រេចឱ្យឃុំខ្លួនបណ្ដោះអាសន្នបន្ត | ១ |
| ឧបសម្ព័ន្ធទី៣៦ | ដីកាបង្គាប់ឱ្យឃុំខ្លួនបណ្ដោះអាសន្នបន្ត | ២ |
| ឧបសម្ព័ន្ធទី៣៧ | ពាក្យស្នើសុំម៉ូតូ | ១ |
| ឧបសម្ព័ន្ធទី៣៨ | ដីកាបញ្ជូនឱ្យឆ្លើយ | ១ |
| ឧបសម្ព័ន្ធទី៣៩ | ដីកាសម្រេចប្រគល់វត្ថុចាប់យក | ១ |
| ឧបសម្ព័ន្ធទី៤០ | ដីកាសម្រេច | ២ |
| ឧបសម្ព័ន្ធទី៤១ | លិខិតជូនដំណឹងអំពីការបិទការស៊ើបសួរ របស់ដើមបណ្ដឹង | ១ |
| ឧបសម្ព័ន្ធទី៤២ | លិខិតជូនដំណឹងអំពីការបិទការស៊ើបសួរ របស់ជនត្រូវចោទ | ១ |
| ឧបសម្ព័ន្ធទី៤៣ | ដីកាបញ្ជូនព័ត៌មាន | ១ |
| ឧបសម្ព័ន្ធទី៤៤ | ដីកាបញ្ជូនសំណុំរឿងឱ្យពិនិត្យ | ១ |
| ឧបសម្ព័ន្ធទី៤៥ | ដីកាសន្និដ្ឋានស្ថាពរ | ៥ |
| ឧបសម្ព័ន្ធទី៤៦ | ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះ | ២ |
| ឧបសម្ព័ន្ធទី៤៧ | ដីកាដំណោះស្រាយ | ២ |
| ឧបសម្ព័ន្ធទី៤៨ | ដីកាបង្គាប់រក្សាទុកជនត្រូវចោទឱ្យនៅពន្ធនាគារជាបណ្ដោះអាសន្ន | ២ |

| | | |
|---|---|---|
| ឧបសម្ព័ន្ធទី៥០ | លិខិតជូនដំណឹងពីការសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះ របស់ជនត្រូវចោទ | ១ |
| ឧបសម្ព័ន្ធទី៥១ | លិខិតជូនដំណឹងពីការសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះរបស់ដើមបណ្តឹងរដ្ឋប្បវេណី | ១ |